**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ: កញ្ញា **ម៉ាក់ ណាមប៊ុន**

កញ្ញា **ហ៊ុំ ស្រីណុច**

សាស្ត្រាចារ្យណែនាំ

លោក **ញឹក ឌុធ្ធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ កញ្ញា **ម៉ាក់ ណាមប៊ុន**

កញ្ញា **ហ៊ុំ ស្រីណុច**

សាស្ត្រាចារ្យណែនាំ

លោក **ញ៉ឹក ឧត្តរី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២៤ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច សូមថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ចំពោះ៖ លោកឪពុកអ្នកម្តាយ ដែលជាអ្នកមានគុណ និងជាអ្នកដែលបានផ្តល់កំណើតនិងចិញ្ចឹមបីបាច់ថែរក្សា អប់រំប្រៀនប្រដៅ រហូតដល់បានចម្រើនវ័យ និងមានចំណេះដឹង ហើយបានក្លាយជាពលរដ្ឋល្អនៅក្នុងសង្គមដល់សព្វថ្ងៃនេះ។

យើងខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងខ្ពង់ខ្ពស់ដល់ ឯកឧត្តមបណ្ឌិត **លុយ ចន្ណា** សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់ឱកាសឱ្យយើងខ្ញុំទាំងពីរបានពង្រីកនូវចំណេះដឹងទូទៅក្នុងសាលា ក៏ដូចជាផ្សព្វផ្សាយប្រធានបទខាងលើដល់អ្នកសិក្សាផ្នែកច្បាប់ តាមរយៈសារណាបញ្ចប់ការសិក្សាដ៏មានតម្លៃមួយនេះ។ ហើយក៏សូមថ្លែងអំណរគុណដល់ សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោកសាស្ត្រាចារ្យ ប្រធានដេប៉ាតឺម៉ង់ ប្រធានការិយាល័យ មន្ត្រីរាជការ និង បុគ្គលិក ដែលបម្រើការងារនៅក្នុងសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ទាំងអស់។

ជាពិសេសទៅទៀតនោះ សូមគោរពដល់ សាស្ត្រាចារ្យណែនាំ លោក **ញឹក ឧុឆ្មី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្រៀន បង្ហាត់បង្ហាញ និង ណែនាំលើកិច្ចការសារណានេះដល់យើងខ្ញុំ ចាប់តាំងពីពេលអនុវត្តដំបូងរហូតដល់កិច្ចការមួយនេះត្រូវបានបញ្ចប់ជាស្ថាពរ។ និស្សិតច្បងទាំងអស់ដែលបានខិតខំចងក្រងទុកជាឯកសារ ដ៏មានតម្លៃដល់ពួកយើងខ្ញុំជំនាន់ក្រោយ ដើម្បីបានទុកជាទុនក្នុងការសិក្សាស្រាវជ្រាវបន្ថែម និង បណ្ណាលគ្រឹះស្ថានមួយចំនួនទៀតដែលបានចងក្រង និង រៀបចំ ជាឯកសារពាក់ព័ន្ធ ហើយផ្តល់មកឱ្យយើងខ្ញុំ។ មិត្តរួមថ្នាក់ និង ញាតិមិត្តទាំងអស់ដែលបានស្រឡាញ់រាប់អាន ហើយបានជួយជាកម្លាំងចិត្តដល់យើងខ្ញុំទាំងអស់គ្នាក៏ដូចជាមិត្តៗទាំងអស់គ្នា ដែលទាំងអស់នេះជាកត្តាមួយដែលបាន ជួយជំរុញឱ្យការសិក្សាស្រាវជ្រាវ យើងខ្ញុំកាន់តែមានសន្ទុះឡើង។

ជាចុងបញ្ចប់ យើងខ្ញុំសូមទុកស្នាដៃនេះជូនដល់មិត្តនិស្សិតជំនាន់ក្រោយ ដើម្បីទុកជាឯកសារ និង សូមថ្លែងអំណរគុណយ៉ាងក្រៃលែង។ យើងខ្ញុំសូមគោរពជូនពរអ្នកទាំងអស់គ្នាឱ្យជួបប្រទះតែនឹងសេចក្តីសុខ សេចក្តីចម្រើន និងសុភមង្គលក្នុងក្រុមគ្រួសារព្រមទាំងការរីកចម្រើន ហើយសូមឱ្យជួបប្រទះនឹងពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ជាទូទៅ យើងសង្កេតឃើញថានៅក្នុងស្ថានភាពបច្ចុប្បន្នរបស់ប្រជាពលរដ្ឋនៅក្នុងប្រទេសកម្ពុជាមានតម្រូវការខ្ចីប្រាក់ដើម្បីប្រកបមុខរបរចិញ្ចឹមជីវិត ក៏ប៉ុន្តែចំពោះការប្រកបអាជីវកម្មនីមួយៗមិនមែនការងាយស្រួលនោះទេគឺតែងតែមានបញ្ហា និងមានផលលំបាក ដោយហេតុថាចំពោះការរកស៊ីតែងតែមានការចំណេញ និងការខាតបង់។ ដូច្នេះហើយបានជាធ្វើឱ្យមានការជាប់បំណុល និងអ្នកឱ្យខ្ចី និងធ្វើឱ្យអ្នកដែលឱ្យខ្ចីមានការព្រួយបារម្ភនិងមានកង្វល់ទៅនឹងលុយដែលខ្លួនបានឱ្យទៅគេខ្ចី ទើបឈានដល់ការប្ដឹងទៅតុលាការទាមទារអោយកូនបំណុលប្រគល់ទាមទារនូវប្រាក់ដែលខ្លួនឱ្យគេខ្ចីមកវិញ។ បន្ថែមលើសពីនេះទៅទៀត នៅក្នុងករណីដែលតុលាការសម្រេចហើយនៅតែមិនទទួលបានការសងប្រាក់ត្រឡប់មកវិញទេ នោះម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំចំពោះកូនបំណុលបានដោយការធ្វើការបង្ខំឱ្យកូនបំណុលបំពេញកាតព្វកិច្ចតាមសាលក្រម។

យោងតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងទៅនឹងការអនុវត្តដោយបង្ខំត្រូវបានបែងចែកជា ៣ប្រភេទធំៗគឺ ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់ និងការអនុត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជានីតិវិធីមួយដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់ពាក្យសុំរឹបអូសយកសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្តដើម្បីទូទាត់ប្រាក់ដែលបានជំពាក់ខ្លួន។ ចំពោះសិទ្ធិលើបំណុល ដែលម្ចាស់បំណុលអាចធ្វើការអនុវត្តដោយបង្ខំបានមានដូចជា លុយដែលបានផ្ញើទុកក្នុង ធនាគារ ប្រាក់ខែ សិទ្ធិលើបំណុលដែលកូនបំណុលមានលើកូនបំណុលទី៣។

ដោយយោងទៅតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានពីរប្រភេទគឺ ការអនុវត្តជាក់ស្តែងនៅក្នុងដំណើរការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ ទៀតសោតដោយហេតុកង្វះផ្នែកចំណេះដឹងអំពីវិស័យច្បាប់ បែបនេះបានធ្វើឱ្យប្រជាពលរដ្ឋមួយចំនួនបានបាត់បង់នៅផលប្រយោជន៍របស់ខ្លួន។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជាសមត្ថកិច្ចរបស់តុលាការក្នុងការអនុវត្ត ហើយការអនុវត្តនេះត្រូវបានចាប់ផ្ដើមដោយការដាក់ពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ចំណែកឯនីតិវិធីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលត្រូវចាប់ផ្ដើមពីការដាក់ពាក្យសុំ ការពិនិត្យពាក្យសុំ ការរឹបអូសសិទ្ធិលើបំណុល ការប្ដូរជាប្រាក់នៃសិទ្ធិលើបំណុល និងការប្រមូលបំណុល។ ហើយនីតិវិធីនេះមានពន្យល់លំអិតនៅក្នុងសារណា ដោយក្នុងនាមយើងខ្ញុំជាអ្នករៀបចំសារណានេះ។ ដោយហេតុនេះហើយទើបធ្វើឱ្យយើងខ្ញុំបានចំណាយពេលវេលា និងថវិកាក្នុងការចងក្រងជាឯកសារមួយនេះឡើង ដោយប្រើប្រាស់រយៈពេលមួយយ៉ាងលំបាកក្នុងការស្រាវជ្រាវ។

យើងខ្ញុំសង្ឃឹមថាឯកសារនេះនឹងក្លាយជាប្រយោជន៍ និងជាវិភាគទានព្រមទាំងផ្ដល់ចំណេះដឹងបន្ថែមសម្រាប់ជាគន្លឹះក្នុងការយល់ដឹងនូវប្រធានបទដែលយើងបានខិតខំស្រាវជ្រាវដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗទៀតឱ្យបានសិក្សាស្រាវជ្រាវបន្ត។

# មាតិកា

**ទំព័រ**

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........................................ ១
២.ចំណោទបញ្ហា ........................................ ១
៣.គោលបំណងនៃការស្រាវជ្រាវ ........................................ ២
៤.ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ ........................................ ២
៥.សារៈសំខាន់នៃការស្រាវជ្រាវ ........................................ ២
៦.វិធីសាស្ត្រនៃការស្រាវជ្រាវ ........................................ ៣
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................ ៣

## ជំពូកទី១
## សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

**ផ្នែកទី១. ការអនុវត្តដោយបង្ខំ** ........................................ ៤
**កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំ** ........................................ ៤
**កថាភាគទី២. ប្រភេទនៃការអនុវត្តដោយបង្ខំ** ........................................ ៦
១. ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ........................................ ៦
២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ ........................................ ៨
៣. ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់ ........................................ ៨
**ផ្នែកទី២. គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល** ........................................ ១០
**កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល** ........................................ ១០
**កថាភាគទី២. ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល** ........................................ ១០
១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងឱ្យសងជាប្រាក់ ........................................ ១០
២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងឱ្យប្រគល់ចលនវត្ថុ ........................................ ១១
**ផ្នែកទី៣. ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច** ........................................ ១១
**កថាភាគទី១. តុលាការអនុវត្ត** ........................................ ១២
១. សមត្ថកិច្ច ........................................ ១២
២. នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត ........................................ ១២

**កថាភាគទី២. អាជ្ញាសាលា**..........................................................................................១៣
១. សមត្ថកិច្ចរបស់អាជ្ញាសាលា..............................................................................១៤
២. នីតិវិធីនៃការអនុវត្តដោយអាជ្ញាសាលា .............................................................. ១៦
**ផ្នែកទី២. វិធីឧបាស្រ័យចំពោះការអនុវត្តខុសច្បាប់** .........................................................១៧
**កថាភាគទី១. បណ្ដឹងជំទាស់**...........................................................................................១៧
១. មូលហេតុនៃការប្ដឹងជំទាស់ ............................................................................១៧
២. បុគ្គលដែលមានសិទ្ធិដាក់ពាក្យបណ្ដឹងជំទាស់......................................................១៧
**កថាភាគទី២. ការតវ៉ាចំពោះការអនុវត្ត**.............................................................................. ១៨
១. មូលហេតុនៃការប្ដឹងតវ៉ាចំពោះការអនុវត្ត ............................................................. ១៨
២. បុគ្គលដែលមានសិទ្ធិធ្វើការប្ដឹងតវ៉ាចំពោះការអនុវត្ត ................................................ ១៨

## ជំពូកទី២

## លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

**ផ្នែកទី១. ការដាក់ពាក្យសុំ** ...........................................................................................២០
**កថាភាគទី១. ការពិនិត្យពាក្យសុំ**......................................................................................២០
**កថាភាគទី២. លិខិតអនុវត្ត**............................................................................................២១
១. អត្ថន័យនៃលិខិតអនុវត្ត....................................................................................២១
២. អត្ថន័យនៃលិខិតអនុវត្ត.................................................................................... ២២
**ផ្នែកទី២. រូបមន្តអនុវត្ត**....................................................................................................២៤
**កថាភាគទី១. អត្ថន័យនៃរូបមន្តអនុវត្ត** ..............................................................................២៤
១. ពាក្យសុំឱ្យផ្ដល់រូបមន្តអនុវត្ត ............................................................................២៥
២. ស្ថាប័នផ្ដល់រូបមន្តអនុវត្ត.................................................................................២៥
**កថាភាគទី២. ប្រភេទនៃរូបមន្តអនុវត្ត**..................................................................................២៦
១. នីតិវិធីផ្ដល់រូបមន្តអនុវត្ត ..................................................................................២៦
២. ពាក្យសុំតវ៉ាអំពីការផ្ដល់រូបមន្តអនុវត្ត ................................................................... ២៧
**ផ្នែកទី៣. សោហ៊ុយ** ......................................................................................................២៨
**កថាភាគទី១. អត្ថន័យសោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី** ២៨
១. ការបង់ពន្ធដាក់ពាក្យសុំ ....................................................................................២៨

២. សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ....... ២៨
៣. សោហ៊ុយភាគី ....... ២៩

## ជំពូកទី៣
## នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

**ផ្នែកទី១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងសងប្រាក់** .. ៣២
**កថាភាគទី១. ការដាក់ពាក្យសុំ** ....... ៣២
**កថាភាគទី២. ការពិនិត្យពាក្យសុំ** ....... ៣៤
**ផ្នែកទី២. ការរឹបអូសសិទ្ធិលើបំណុល** ....... ៣៥
**កថាភាគទី១. នីតិវិធីនៃការរឹបអូសសិទ្ធិលើបំណុល** ....... ៣៥
**កថាភាគទី២. អានុភាពនៃការរឹបអូសសិទ្ធិលើបំណុល** ....... ៣៧
១. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះម្ចាស់បំណុលនៃការអនុវត្ត ....... ៣៧
២. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះកូនបំណុលនៃការអនុវត្ត ....... ៣៨
៣. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះកូនបំណុលទី៣នៃការអនុវត្ត ....... ៣៨
៤. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក ....... ៣៩
**ផ្នែកទី៣. ការប្តូរជាប្រាក់** ....... ៤០
**កថាភាគទី១. ការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស** ....... ៤០
**កថាភាគទី២. ការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស** ....... ៤១
១. ល័ក្ខខ័ណ្ឌនៃការអនុវត្តនីតិវិធីលក់សិទ្ធិលើបំណុល ....... ៤២
២. ល័ក្ខខ័ណ្ឌនៃការចេញដីកាសម្រេចបង្គាប់ឱ្យលក់ ....... ៤២
៣. ខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យលក់ ....... ៤២
**កថាភាគទី៣. ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តដីកាសម្រេចបង្គាប់ឱ្យលក់** ....... ៤២
១. កាលបរិច្ឆេទនៃការលក់ដោយអាជ្ញាសាលា ....... ៤២
២. បុគ្គលដែលមិនអាចក្លាយជាអ្នកទិញ ....... ៤៣
៣. ការចាត់ចែងក្រោយការរត់សិទ្ធិលើបំណុល ....... ៤៣
**ផ្នែកទី៤. ការផ្ញើប្រាក់ទុក ដោយកូនបំណុលទី៣** ....... ៤៤
**កថាភាគទី១. ការផ្ញើដោយមានសិទ្ធិ** ....... ៤៤
**កថាភាគទី២. ការផ្ញើដោយមានករណីយកិច្ច** ....... ៤៤

**ផ្នែកទី៥. ការចែកចំណែក** ........................................................ ៤៤
**កថាភាគទី១. បុគ្គលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក** .................................. ៤៥
**កថាភាគទី២. វិធីទាមទារឱ្យចែកចំណែក** .................................................. ៤៥
១. អំឡុងពេលអត្ថិភាពនៃការទាមទារឱ្យចែកចំណែក .......................................... ៤៥
២. វិសាលភាពនៃម្ចាស់សិទ្ធិដែលត្រូវទទួលបានចំណែក ........................................ ៤៧
**កថាភាគទី៣. នីតិវិធីចែកចំណែក** ........................................................ ៤៧
១. ការចែកចំណែកដោយការព្រមព្រៀង ........................................................ ៤៧
២. ការចែកចំណែកដោយតុលាការ ........................................................... ៤៨
**ផ្នែកទី៦. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុ** ........................................................ ៤៨
**កថាភាគទី១. ការប្រគល់ចលនវត្ថុ** ........................................................ ៤៨
១. ការដាក់ពាក្យសុំ ........................................................................ ៤៩
២. ការពិនិត្យពាក្យសុំ ...................................................................... ៥០
**កថាភាគទី២. ការស្នើសុំកម្លាំង** ........................................................... ៥១
**កថាភាគទី៣. នីតិវិធីនៃការប្រគល់ចលនវត្ថុ** ............................................... ៥២
**កថាភាគទី៤. ការបិទបញ្ចប់ការប្រគល់** .................................................... ៥២
**សេចក្តីសន្និដ្ឋាន** ......................................................................... ៥៣
**អនុសាសន៍** ................................................................................. ៥៥
**ឯកសារយោង** ............................................................................... ៥៧
**ឧបសម្ព័ន្ធ** .................................................................................. ៥៩

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រព័ន្ធច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបានបាត់បង់ស្ទើរតែទាំងស្រុង ដោយសារសង្គ្រាមស៊ីវិល ដែលក្នុងនោះ ច្បាប់ និងលិខិតបទដ្ឋានរួមទាំងច្បាប់នានា សម្រាប់អនុវត្តទៅលើរឿងក្តីរដ្ឋប្បវេណី ក៏មានភាពខ្វះខាត និងទន់ខ្សោយផងដែរ។ ដោយសារតែភាពមិនច្បាស់លាស់នៃវិធាននានាសម្រាប់យន្តការនៃការដោះស្រាយវិវាទរដ្ឋប្បវេណីជាឧបសគ្គមួយក្នុងចំណោមឧបសគ្គនានា ដែលរារាំងដំណើរការអភិវឌ្ឍប្រទេសជាតិ ការកាត់បន្ថយភាពក្រីក្រ និង ការរំលោភលើសិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ ដែលក្នុងនោះរួមមាន សិទ្ធិផ្នែករដ្ឋប្បវេណីផងដែរ។

ក្រមនីតិវិធីរដ្ឋប្បវេណីបានប្រកាសឱ្យប្រើ នៅថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០៦ ហើយដែលត្រូវបានដាក់ឱ្យអនុវត្តចាប់ពី ខែកក្កដា ឆ្នាំ២០០៧ ក្រោមកិច្ចសហការជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នារវាងក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា និង ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន។ ក្រមនីតិវិធីថ្មីនេះ គឺជាមូលដ្ឋានគ្រឹះនៃអ្នកច្បាប់ និង អ្នកវិជ្ជាជីវៈជាច្រើនដូចជា ចៅក្រម ព្រះរាជអាជ្ញា អាជ្ញាសាលា ក្រឡាបញ្ជី សារការី និង មេធាវីដែលជាស្ថាប័នមានសមត្ថកិច្ច និងអ្នកដែលធ្វើការក្នុងវិស័យច្បាប់ជាច្រើនទៀតសម្រាប់យកទៅអនុវត្តក្នុងគោលដៅធ្វើឱ្យសង្គមមួយមានយុត្តិធម៌។ ដើម្បីការពារដល់សិទ្ធិទាមទារ និង សិទ្ធិប្រាតិភោគដែលបានកំណត់នៅក្នុងនីតិឯកជន៖ ការកំណត់ដោយតុលាការ អំពីអត្ថិភាពនៃសិទ្ធិទាំងនោះនៅក្នុងសាលក្រម ឬ សាលដីកា នៅមិនទាន់គ្រប់គ្រាន់ទេ។ បន្ថែមពីលើនេះទៅទៀត ត្រូវតែមានការផ្តល់តាវកាលិកជាអាទិ៍ ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ។ ឧទាហរណ៍៖ ដូចជាការបង់ប្រាក់តាមចំនួនកំណត់ណាមួយ ការប្រគល់ចលនវត្ថុណាមួយជាក់លាក់ជាដើម ឬការផ្តល់តាវកាលិកជាប្រាក់ដែលមានគោលបំណងនៃសិទ្ធិទាមទារឱ្យសងជាការប្រាក់ដែលត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ដើម្បីអនុវត្តបានម្ចាស់បំណុលនៃការអនុវត្តត្រូវដាក់ពាក្យសុំអនុវត្តទៅស្ថាប័នអនុវត្ត។

## ២. ចំណោទបញ្ហា

ការសិក្សាអំពីប្រធានបទ **ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល** គឺនិងធ្វើការសិក្សាអំពីនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។ ចំណោទបញ្ហាសំខាន់ៗនៅក្នុងប្រធានបទនេះមានដូចជា៖

- តើសញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានលក្ខណៈដូចម្តេចខ្លះ?
- តើត្រូវបំពេញល័ក្ខខ័ណ្ឌច្បាប់អ្វីខ្លះដើម្បីអាចធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល?
- នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានប្រភេទអ្វីខ្លះ?
- តើនីតិវិធីនៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានដំណើរការយ៉ាងដូចម្តេចខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវសារណាទៅលើប្រធានបទ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មកធ្វើការសិក្សានៅពេលនេះគឺ យើងខ្ញុំមានគោលបំណងពង្រីកចំណេះដឹងឱ្យកាន់តែច្បាស់ និងដើម្បីឱ្យមានការរីកចម្រើននូវវិស័យច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា និងចង់យល់ដឹងបន្ថែមអំពីក្របខណ្ឌច្បាប់ដែលកំពុងនៅជាធរមាន ដែលរួមមាន នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដើម្បីឱ្យកាន់តែច្បាស់លាស់នៅក្នុងការអនុវត្ត។

លើសពីនេះទៅទៀត គោលបំណងនៅក្នុងការសរសេរនេះគឺ ដើម្បីស្វែងយល់អំពី៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល របៀបនៃការសរសេរពាក្យសុំនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល របៀបពិនិត្យពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល សិទ្ធិលើបំណុលដែលអាចរឹបអូសបាន និង មិនអាចរឹបអូសបាន កម្រិតពីទំហំនៃការរឹបអូស និងប្តូរទំហំនៃការរឹបអូសចំពោះសិទ្ធិលើបំណុល តវ៉ាការផ្អាក និងការលុបចោលការរឹបអូសដោយបង្ខំចំពោះសិទ្ធិលើបំណុល អានុភាពនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងនីតិវិធីជាច្រើនទៀតដែលមាននៅក្នុងការស្រាវជ្រាវមួយនេះឱ្យកាន់តែមានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល។

បន្ថែមលើសពីនេះទៅទៀតនៅក្នុងគោលបំណងដែលសំខាន់ចំពោះប្រធានបទមួយនេះ គឺដើម្បីធ្វើការសិក្សាស្វែងយល់អំពីចំណុចដែលមានសារៈសំខាន់ខ្លាំង និងចំណុចដែលមិនសូវមានសារៈសំខាន់ រួមទាំងបញ្ហាដែលមានការប្រឈមបានកើតឡើង។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ការសិក្សាទៅលើប្រធានបទនេះ គឺយើងធ្វើការសិក្សាតែទៅលើនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលតែប៉ុណ្ណោះ ចំណែកនីតិវិធីផ្សេងៗទៀតពុំបានលើកយកមកធ្វើការបកស្រាយនោះទេ។ បន្ថែមលើសពីនេះទៅទៀត យើងខ្ញុំសិក្សាតែទៅលើទ្រឹស្តីនៃការអនុវត្ត នីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលប៉ុណ្ណោះ ចំពោះនីតិវិធីនៃការអនុវត្តជាក់ស្តែងដែលកើតមាននៅតាមបណ្តាស្ថាប័នអនុវត្ត យើងខ្ញុំក៏មិនបានលើកយកមកសិក្សាលម្អិតនោះទេ។

ទៀតសោតការសិក្សានេះ គឺស្ថិតតែក្នុងក្របខណ្ឌដែលច្បាប់ធរមានប៉ុណ្ណោះ ដែលមានក្រមនីតិវិធីរដ្ឋប្បវេណី ជាច្បាប់គោល រីឯចំពោះច្បាប់ដែលនិរាករណ៍ ឬបទបញ្ញត្តិច្បាប់បរទេសដែលពាក់ពន្ធ័ទៅនឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺមិនយកមកធ្វើការសិក្សានោះទេ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការអនុវត្តនាពេលបច្ចុប្បន្ននេះ ដោយសារតែនីតិវិធីនេះមិនមានភាពងាយស្រួលនោះទេចំពោះការអនុវត្ត ត្បិតការអនុវត្តនេះគឺអនុវត្ត

ដោយបង្ខំទៅលើទ្រព្យរបស់បុគ្គលណាម្នាក់ ទើបយើងខ្ញុំសម្រេចចិត្តស្រាវជ្រាវលើប្រធានបទមួយនេះ។ លើសពីនេះទៅទៀត គឺយើងត្រូវការចំណាយពេលវេលា ថវិកាផ្ទាល់ខ្លួន កម្លាំងកាយ និងកម្លាំងចិត្ត ការយកចិត្តទុកដាក់ក្នុងការសរសេរប្រធានបទមួយនេះឡើងមក ដើម្បីទុកជាស្នាដៃសម្រាប់សិស្សប្អូននៅជំនាន់ក្រោយឱ្យបានធ្វើការសិក្សាបង្កើនចំណេះដឹងបន្ថែមនៅក្នុងវិស័យមួយនេះ។ ទៀតសោតយើងខ្ញុំ នឹងខិតខំប្រឹងប្រែងស្រាវជ្រាវប្រធានបទមួយនេះឱ្យជោគជ័យទោះមិនល្អគ្រប់គ្រាន់តែយើងនឹងធ្វើការខិតខំឱ្យអស់ពីសមត្ថភាពនៅក្នុងការស្រាវជ្រាវ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរអំពីអត្ថបទសារណានេះ យើងខ្ញុំទាំងពីររូបបានធ្វើការរៀបចំ និង តាក់តែងធ្វើការស្រាវជ្រាវក្រោមការសិក្សា អានអត្ថបទ មេរៀន សិក្ខាសាលា។ បន្ថែមលើសពីនេះទៅទៀតអត្ថបទសារណានេះ គឺផ្តោតសំខាន់ទៅលើក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១៖ សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល
- ជំពូកទី២៖ ល័ក្ខខ័ណ្ឌនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល
- ជំពូកទី៣៖ នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្ត
# ដោយបង្ខំចំពោះសិទ្ធិលើបំណុល

# ជំពូកទី១

# សញ្ញាណទូទៅនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

តាមបញ្ញត្តិនៃច្បាប់ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺត្រូវបានបែងចែកជា ៣ ធំៗ គឺការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់ និងការអនុត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។ ជារួមមក នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបង្កើតឡើងក្នុងគោលបំណងដើម្បីសម្រេចនូវសិទ្ធិទាមទារជាស្ថាពររបស់ម្ចាស់បំណុលនៃការអនុវត្ត។ មានន័យថា ប្រសិនបើគ្មាននីតិវិធីនៃការអនុវត្តដោយបង្ខំទេនោះ សេចក្តីសម្រេចរបស់តុលាការនឹងគ្មានអំណាចចាប់បង្ខំទៅលើអ្នកចាញ់ក្តីអ្វីនោះទេ ប្រសិនបើអ្នកចាញ់ក្តីមិនព្រមអនុវត្តតាមខ្លឹមសារនៃសេចក្តីសម្រេចនោះដោយស្ម័គ្រចិត្ត។

ចំពោះរចនាសម្ព័ន្ធនៃនីតិវិធីអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់មានការលំបាក និងមានភាពស្មុគស្មាញជាពិសេស។ នីតិវិធីនៃការអនុវត្តដោយបង្ខំប្រភេទនេះ មានគោលដៅបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុមួយថ្មី រវាងភាគីទាំងពីរឬ ក្នុងករណីខ្លះរវាងភាគី និងតតិយជន ក្នុងខណៈដែលនីតិវិធីចេះតែដំណើរការទៅមុខហើយចុងក្រោយ នឹងសម្រេចនូវសិទ្ធិទាមទារដោយការរួមបញ្ចូលនូវនីតិវិធីទាំងនោះ។ ចំពោះសកម្មភាពនានានៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ មិនមានន័យត្រឹមជាដំណាក់កាលនៃនីតិវិធីប៉ុណ្ណោះទេ តែវាក៏មានអានុភាពក្នុងការបង្កើតទំនាក់ទំនងគតិយុត្តជាសារធាតុបែបនេះផងដែរ។ នីតិវិធីអនុវត្តដោយបង្ខំនេះទៀតសោតជានីតិវិធីឯករាជ្យ និងពិសេសមួយ ហេតុនេះហើយបានជាបទបទប្បញ្ញត្តិជាច្រើន ដែលបញ្ញត្តិពាក់ព័ន្ធទៅនឹងនីតិវិធីនៃការអនុវត្តដោយបង្ខំក៏ ដូចជាពាក់ព័ន្ធទៅនឹងស្ថាប័នអនុវត្តត្រូវបានចងក្រងជាផ្នែកមួយនៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា គឺស្ថិតនៅក្នុងគន្ថីទី៦ ស្តីពីការអនុវត្តដោយបង្ខំ និងគន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ។

## ផ្នែកទី១. ការអនុវត្តដោយបង្ខំ

### កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំ

ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបានកំណត់នៅក្នុងនីតិឯកជន ដោយប្រើអំណាចរដ្ឋ[1]។ មានន័យថា ល័ក្ខខ័ណ្ឌដើម្បីសម្រេចការទាមទារ ព្រមទាំងបែបបទនៃការអនុវត្តដោយបង្ខំ ត្រូវបានចែងក្នុងច្បាប់ជាក់លាក់ ដែលដំណើរការនៃការសម្រេចពីសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ ការសម្រេចពីអត្ថិភាពនៃសិទ្ធិទាមទារដែលកើតមាន គឺស្ថិតក្នុងក្របខណ្ឌនៃនីតិឯកជន។ ហើយនីតិឯកជនក្នុងន័យនេះ សំដៅដល់សំណុំវិធានគតិយុត្តិទាំងឡាយណា ដែលបង្កើតឡើងដើម្បីដោះស្រាយ និងសម្របសម្រួលនូវទំនាក់ទំនងនៃបុគ្គលឯកជន និងបុគ្គលឯកជន ទីដៅដើម្បីបម្រើផលប្រយោជន៍ឯកជន សំណុំ

[1] មាត្រា ៣៣៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

វិធាននោះមានដូចជា នីតិវិធីរដ្ឋប្បវេណី នីតិពាណិជ្ជកម្ម នីតិការងារ នីតិកិច្ចសន្យា នីតិកម្មសិទ្ធិបញ្ញាជាអាទិ៍។ ប្រព័ន្ធនីតិវិធីរដ្ឋប្បវេណី គឺជាប្រព័ន្ធមេមួយដែលមានសារៈសំខាន់ណាស់ក្នុងរង្វង់នៃនីតិឯកជន ប្រព័ន្ធនេះមានគោលបំណងផ្តល់ឱ្យភាគីឯកជនដែលមានសិទ្ធិដែលបានកំណត់ដោយច្បាប់នូវសិទ្ធិការពារ។ យ៉ាងណាមិញ ដើម្បីការពារនូវផលប្រយោជន៍របស់ម្ចាស់សិទ្ធិ នៅក្នុងប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីដែលមានគោលបំណងការពារសិទ្ធិរបស់បុគ្គលឯកជនចាំបាច់ត្រូវមានការរៀបចំនូវនីតិវិធីសម្រាប់អនុវត្តដោយបង្ខំក្នុងករណីដែលបុគ្គលជាប់កាតព្វកិច្ចផ្តល់តាវកាលិក ឬកូនបំណុលដែលមិនព្រមអនុវត្តកាតព្វកិច្ចរបស់ខ្លួនដោយស្ម័គ្រចិត្ត ក្នុងគោលដៅសម្រេចឱ្យបាននូវការអនុវត្តកាតព្វកិច្ច ដែលជាកម្មវត្ថុនៃសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគ តាមរយៈការប្រើប្រាស់អំណាចអាជ្ញាបញ្ញារបស់រដ្ឋ[2]។

ការអនុវត្តដោយបង្ខំ គឺជាផ្នែកមួយដ៏សំខាន់ នៃប្រព័ន្ធនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦។ ទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តដោយបង្ខំ គឺជានីតិវិធីឯករាជ្យមួយ ដោយមិនមែនជានីតិវិធីបន្ទាប់ ឬបន្តពីនីតិវិធីបណ្តឹងនោះទេ ពោលគឺ នីតិវិធីនេះត្រូវចាប់ផ្តើមដោយការដាក់ពាក្យសុំរបស់ភាគី ហើយត្រូវអនុវត្តដោយស្ថាប័នអនុវត្ត[3]។ ជាក់ស្តែង យើងមើលឃើញថា នីតិវិធីនៃការអនុវត្តដោយបង្ខំនេះ ជានីតិវិធីមួយដែលបង្ខំ ឬការដាក់បន្ទុកក្នុងការអនុវត្តទៅលើកូនបំណុលដើម្បីឱ្យសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគរបស់ម្ចាស់បំណុល។ ជាការសន្មតម្ចាស់បំណុលគឺជាអ្នកមានសិទ្ធិ ឬ បុគ្គលដែលមានសិទ្ធិទាមទារ ចំណែកកូនបំណុលគឺជាអ្នកមានកាតព្វកិច្ច ឬអ្នកត្រូវបំពេញកិច្ចជូនម្ចាស់បំណុល ដោយនីតិវិធីនេះអនុវត្តទៅលើកូនបំណុល នៅពេលកូនបំណុលនោះមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួន។

នីតិវិធីនៃការអនុវត្តដោយបង្ខំជាដំណាក់កាលចុងក្រោយ ហើយពិសេសដោយបញ្ញត្តិនេះបានផ្តល់សិទ្ធិអំណាចដល់ស្ថាប័នអនុវត្តក្នុងការដកហូតទ្រព្យសម្បត្តិ ឬ សិទ្ធិផ្សេងទៀតរបស់កូនបំណុលដោយបង្ខំដើម្បីប្រគល់ឱ្យម្ចាស់បំណុល ឬអនុវត្តនីតិវិធីលក់យកប្រាក់ ហើយសងទៅម្ចាស់បំណុលតាមផ្លូវតុលាការ។ ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត គឺរាល់ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្តឬ រាល់ទ្រព្យសម្បត្តិដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់កូនបំណុលនៃការអនុវត្ត។ ជាគោលការណ៍ ទ្រព្យទាំងឡាយដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត ត្រូវក្លាយជាទ្រព្យសម្បត្តិទទួលខុសត្រូវ។ ក៏ប៉ុន្តែ តាមប្បញ្ញត្តិច្បាប់ វត្ថុ និងសិទ្ធិមួយចំនួនត្រូវបានដកចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវដូចជា៖ ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក គ្រឿង

[2] ទំព័រ ១ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៩

[3] ទំព័រ ២ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៩

បរិភោគ ទាហានវត្ថុ របបឧបត្ថម្ភជីវភាព បៀវត្ស ប្រាក់ឈ្នួលជាដើម ត្រូវបានហាមឃាត់មិនឱ្យរឹបអូស។ គ្រប់ប្រភេទនៃនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺម្ចាស់បំណុលនៃការអនុវត្ត ត្រូវដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ ទៅស្ថាប័នអនុវត្តដែលត្រូវបានកំណត់សមត្ថកិច្ចទៅតាមប្រភេទនៃទ្រព្យសម្បត្តិ។ ម្លោះហើយ ម្ចាស់បំណុលនៃការអនុវត្តចាំបាច់ត្រូវជ្រើសរើសទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត ហើយដាក់ពាក្យសុំទៅតុលាការអនុវត្តដែលមានសមត្ថកិច្ច។ ត្រង់នេះ មានន័យថាដើម្បីអាចដំណើការនីតិវិធីអនុវត្តដោយបង្ខំបានម្ចាស់បំណុលត្រូវសកម្មក្នុងការដាក់ពាក្យសុំ និងជ្រើសរើសទ្រព្យសម្បត្តិដើម្បីអនុវត្ត មិនមែនស្ថាប័នអនុវត្តធ្វើការជ្រើសរើសទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីធ្វើការអនុវត្ត ដោយឆន្ទានុសិទ្ធិរបស់ខ្លួននោះទេ។ តាមក្រមនីតិវិធីរដ្ឋប្បវេណី នីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបានបែងចែកជា ៣ ប្រភេទធំៗ គឺការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងសងជាប្រាក់ និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ។

**កថាភាគទី ២. ប្រភេទនៃការអនុវត្តដោយបង្ខំ**

**១. ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់**

ការអនុវត្តដើម្បីប្រមូលប្រាក់ដោយបង្ខំលើទ្រព្យសម្បត្តិរបស់កូនបំណុល ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្ត ហៅថាការអនុវត្តចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់[4]។ ជាគោលការណ៍ ការអនុវត្តដោយបង្ខំដែលមានគោលបំណងសងជាប្រាក់ ធ្វើឡើងដើម្បីរឹបអូសទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ហើយបំប្លែងទ្រព្យទាំងនោះទៅជាប្រាក់ រួចចែកឱ្យទៅម្ចាស់បំណុលនៃការអនុវត្តដែលបានដាក់ពាក្យសុំ ហើយក៏អាចកើតឡើងនូវករណី ដែលមានម្ចាស់បំណុលច្រើន ដូច្នេះក៏ត្រូវចែកឱ្យម្ចាស់បំណុលទាំងអស់ដែលបានដាក់ពាក្យស្នើសុំចែកចំណែកផងដែរ។

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្តប៉ុណ្ណោះ លើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេស។ ទ្រព្យសម្បត្តិដែលអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ ហៅថាទ្រព្យសម្បត្តិទទួលខុសត្រូវ។ ទ្រព្យសម្បត្តិទទួលខុសត្រូវនេះ សំដៅដល់ទ្រព្យសម្បត្តិដែលអាចយកមកបំប្លែង ឬ អាចរឹបអូសបាន ដែលមិនបានកំណត់ហាមឃាត់ដោយច្បាប់ បើសិនជាចលនវត្ថុ ឬ សិទ្ធិលើបំណុលមួយចំនួន ដែលត្រូវបានហាមឃាត់ដោយច្បាប់នោះ ត្រូវដាត់ចេញពីទ្រព្យសម្បត្តិទទួលខុសត្រូវ។ ដើម្បីសម្រេចនូវសិទ្ធិទាមទារតាមរយៈ ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំទៅលើទ្រព្យសម្បត្តិរបស់កូនបំណុលដែលអាចជា ការអនុវត្តចំពោះ

[4] ទំព័រ ៨០ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៩

ចលនវត្ថុ ការអនុវត្តចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ការអនុវត្តចំពោះអចលនវត្ថុ និង ការអនុវត្តចំពោះនាវាជាដើម។

ការអនុវត្តចំពោះចលនវត្ថុ៖ គឺជាការអនុវត្តដោយបង្ខំដែលត្រូវបានធ្វើឡើង តាមវិធីដែលអាជ្ញាសាលារឹបអូសយកចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។ ចលនវត្ថុត្រង់ចំណុចនេះ សម្តៅដល់វត្ថុទាំងឡាយដែលក្រៅពីអចលនវត្ថុ (ម៉ូតូ រថយន្ត គ្រឿងសង្ហារឹម គ្រឿងអលង្ការ...) ទ្រព្យសម្បត្តិទាំងឡាយដែលគ្មានរូបរាង ប៉ុន្តែអាចគ្រប់គ្រងបាន (ឧស្ម័ន ថាមពលអគ្គិសនី,...), រួមបញ្ចូលទាំង ផលធម្មជាតិដែលមិនទាន់បំបែកពីដីនៅឡើយ ហើយអាចទទួលផលបានយ៉ាងច្បាស់លាស់នៅក្នុងអំឡុងពេល ១ ខែ។

ការអនុវត្តចំពោះសិទ្ធិលើបំណុល ឬសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត៖ គឺជាការអនុវត្តដោយបង្ខំដើម្បីសម្រេចនូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល តាមរយៈការរឹបអូសសិទ្ធិលើបំណុល។ សិទ្ធិលើបំណុល ឬសិទ្ធិទ្រព្យសម្បត្តិ សំដៅដល់សិទ្ធិ ឬ ទ្រព្យសម្បត្តិទាមងឡាយដែលជារបស់កូនបំណុលនៃការអនុវត្ត មានចំពោះតតិយជន។ កម្មវត្ថុនៃការរឹបអូសសិទ្ធិលើបំណុលនេះ គឺសិទ្ធិទាមទារឱ្យសងជាប្រាក់ និង សិទ្ធិទាមទារឱ្យប្រគល់វត្ថុ។

ការអនុវត្តចំពោះអចលនវត្ថុ៖ គឺជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ការគ្រប់គ្រងលើទីកន្លែង ឬទីទំនេរណាមួយឱ្យទៅម្ចាស់បំណុលនៃការអនុវត្ត ឬតតិយជន។ យ៉ាងណាមិញចំពោះអចលវត្ថុដែលអាចក្លាយជាកម្មវត្ថុ រួមមាន ដី អគារដែលត្រូវបានចុះបញ្ជី ចំណែកនៃកម្មសិទ្ធិអវិភាគលើដី ឬអគារនោះ សិទ្ធិជួលអចិន្ត្រៃយ៍ និង ផលុបភោគនោះដែលរួមមានសិទ្ធិរួម (អវិភាគ)[5]។ ចំពោះការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុនេះ ត្រូវធ្វើតាមវិធីលក់ដោយបង្ខំ។

ការអនុវត្តចំពោះនាវា៖ ជាមូលដ្ឋានត្រូវធ្វើតាមវិធីដែលស្របទៅតាមវិធីលក់ដោយបង្ខំនៃអចលវត្ថុ ពោលគឺធ្វើឡើងតាមរយៈការលក់ដោយបង្ខំនូវនាវាដែលជាកម្មវត្ថុ។ នាវា នេះសំដៅដល់ជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី២០តោន និងជលយានដែលមានចំណុះសរុបជាតោនក្រោម២០តោន ហើយដែលបានចុះបញ្ជីនៅព្រះរាជាណាចក្រកម្ពុជា[6]។ ចំពោះជលយានដែលមានចំណុះសរុបជាតោនស្មើនឹង និងលើសពី ២០តោននោះ ទោះបីជាមិនបានចុះបញ្ជីក៏ដោយ ក៏ចាត់ទុកជានាវាក្នុងន័យក្រមរដ្ឋប្បវេណីដែរ។

ចំពោះការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ មានកម្មវត្ថុនៃការអនុវត្តផ្សេងៗគ្នា នីតិវិធីនៃការអនុវត្តមួយចំនួនមានភាពស្រដៀងគ្នា តែនីតិវិធីនេះមិនដូចគ្នាទាំងស្រុងនោះទេ។ យ៉ាងណាមិញ

[5] មាត្រា ៤១៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[6] មាត្រា ៤៥៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បើទោះបីជាកម្មវត្ថុនៃការអនុវត្តខុសៗគ្នាក៏ដោយ ប៉ុន្តែគោលបំណងក្នុងការអនុវត្តនេះ គឺដូចគ្នាសុទ្ធតែមានគោលបំណងសងជាប្រាក់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត។

**២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគ**

ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិប្រាតិភោគនេះ ជានីតិវិធីដើម្បីសម្រេចគោលបំណងរបស់បុគ្គលដែលមានសិទ្ធិប្រាតិភោគ ដូចជា ហ៊ីប៉ូតែកឬ សិទ្ធិលើការបញ្ចាំ ជាអាទិ៍ ដែលបានកំណត់នៅក្នុងក្រមរដ្ឋប្បវេណី ដែលជាទូទៅសិទ្ធិប្រាតិភោគទាំងនោះ អាចធ្វើការប្តូរជាប្រាក់ដោយបង្ខំ នូវទ្រព្យសម្បត្តិដែលត្រូវបានធានាតាមរយៈស្ថាប័នអនុវត្ត ហើយទទួលបានប្រាក់នៃសំណងទាំងនោះ មុននឹងម្ចាស់បំណុលដទៃទៀត។ ការអនុវត្តដោយបង្ខំចំពោះប្រាតិភោគនោះ រួមមាន ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះអចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះនាវា ការអនុវត្តសិទ្ធិប្រាតិភោគចំពោះសិទ្ធិលើបំណុល និងទ្រព្យសម្បត្តិផ្សេងទៀត។ នីតិវិធីនៃការអនុវត្តសិទ្ធិប្រាតិភោគ គឺជាប្រភេទមួយនៃការអនុវត្តដោយបង្ខំ និងត្រូវបានអនុលោមយ៉ាងជាក់ច្បាស់ដោយបញ្ញត្តិច្បាប់។ នីតិវិធីអនុវត្តសម្រាប់ប្រើប្រាស់ក្នុងកម្មវត្ថុនីមួយៗ ប្រែប្រួលទៅតាមប្រភេទនៃកម្មវត្ថុនោះ។ ការអនុវត្តសិទ្ធិប្រាតិភោគ ត្រូវធ្វើឡើងដោយផ្អែកតាមលិខិតអនុវត្ត ដូចជា សាលក្រម ឬ សាលដីកាដែលបញ្ជាក់អំពីអត្ថិភាព នៃសិទ្ធិប្រាតិភោគ ឬ លិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ។ ព្រមទាំងលិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ។

**៣. ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់**

ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់ សំដៅដល់ការអនុវត្តដោយបង្ខំទៅតាមអំណាចនៃសេចក្តីសម្រេចរបស់តុលាការដែលបង្គាប់ឱ្យកូនបំណុលនៃការអនុវត្តផ្តល់តាវកាលិកក្រៅពីប្រាក់ ទៅម្ចាស់បំណុល។ ម្លោះហើយ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់នោះ មិនចាំបាច់សម្រេចសិទ្ធិទាមទាររបស់ម្ចាស់បំណុលតាមរយៈការចាត់ចែងប្តូរជាប្រាក់ឡើយ ពោលគឺគ្រាន់តែប្រគល់វត្ថុនោះអោយទៅភាគីម្ចាស់បំណុលប៉ុណ្ណោះ។ ដើម្បីសម្រេចបាននូវតាវកាលិកផ្តល់ឱ្យទៅម្ចាស់បំណុលនៃការអនុវត្តតាមសេចក្តីសម្រេចតុលាការមានអំណាចដើម្បីដកហូត ឬរំលាយការកាន់កាប់វត្ថុនោះពីកូនបំណុលនៃការអនុវត្ត ទៅប្រគល់ឱ្យម្ចាស់បំណុល ឬបង្គាប់ឱ្យតតិយជនធ្វើសកម្មភាពនោះជំនួសកូនបំណុល ដោយឱ្យកូនបំណុលជាអ្នកចេញសោហ៊ុយចំណាយ។

ការអនុវត្តដោយបង្ខំនេះ មានលក្ខណៈពិសេសដែលអាចអនុវត្តទៅលើទាំងទ្រព្យរូបី សិទ្ធិទាមទារឱ្យធ្វើសកម្មភាព មិនធ្វើសកម្មភាពជាកំណត់ណាមួយ ទៅឱ្យម្ចាស់បំណុលបាន។ ក្នុងនោះផងដែរ ការអនុវត្តដោយបង្ខំដែលគ្មានគោលបំណងឱ្យសងជាប្រាក់៖ រួមមានការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់ការអនុវត្ត

ដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពណាមួយ និងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពណាមួយ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់៖ ការអនុវត្តសិទ្ធិក្នុងការទាមទារឱ្យប្រគល់នេះ អាចសម្រេចបានដោយការអនុវត្តដោយបង្ខំដោយផ្ទាល់ និងដោយប្រើអំណាចរបស់ស្ថាប័នអនុវត្ត។ ការប្រគល់នេះមានន័យថា ជាការផ្ទេរការកាន់កាប់ដោយផ្ទាល់ ពោលគឺការគ្រប់គ្រងជាក់ស្តែងលើវត្ថុ ទៅឱ្យម្ចាស់បំណុល ឬតតិយជន។ ចំពោះវត្ថុរូបីមួយចំនួនមិនអាចសម្រេចបាន ចំពោះការអនុវត្តដោយបង្ខំឱ្យប្រគល់ឡើយ ដូចជាករណីយកិច្ចផ្គត់ផ្គង់សេវា ទឹក និងហ្គាសជាអាទិ៍ ព្រោះវត្ថុទាំងនេះត្រូវការច្បាប់ពិសេស ដែលមានល័ក្ខខ័ណ្ឌពិសេសដើម្បីគ្រប់គ្រង និងការផ្ទេរ។ ទោះបីក្នុងករណីដែលសិទ្ធិត្រូវបានបង្កើតឡើងនៅពេលប្រគល់វត្ថុក៏ដោយ ក៏គេអាចធ្វើការអនុវត្តឱ្យប្រគល់វត្ថុរូបីបានដែរ។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារអាចអនុវត្តទៅលើ រួមមាន ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យប្រគល់អចលនវត្ថុ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុជាក់លាក់ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារ ដែលមានគោលបំណងឱ្យផ្តល់តាវកាលិកនូវចំនួនជាកំណត់នៃវត្ថុជំនួស។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យធ្វើសកម្មភាពណាមួយ៖ ខុសឡែកពីករណីយកិច្ចក្នុងការប្រគល់ ចំពោះករណីយកិច្ចធ្វើ ក៏ជាករណីយកិច្ចមួយដែលកូនបំណុលត្រូវបំពេញផងដែរ។ ចំពោះករណីយកិច្ចធ្វើដែលស្មើនឹងសិទ្ធិទាមទារឱ្យធ្វើសកម្មភាពមួយ បើមើលលើទស្សនៈទានរបស់ម្ចាស់សិទ្ធិវិញ ការសម្រេចនូវខ្លឹមសារនៃករណីយកិច្ចនោះ ដោយករណីនេះស្ថាប័នអនុវត្តមានការលំបាកច្រើន ឬមិនអាចធ្វើកើតតែម្តង។ ចំពោះករណីកិច្ចធ្វើ ត្រូវបានបែងចែកជាសកម្មភាពដែលអាចអនុវត្តជំនួសបាន និងសកម្មភាពដែលមិនអាចអនុវត្តជំនួសបាន ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈ ព្រោះមិនមែនគ្រប់សកម្មភាព ឬល័ក្ខខ័ណ្ឌសុទ្ធតែត្រូវបានអនុវត្តដោយកូនបំណុលនោះទេ សកម្មភាពខ្លះក៏អាចលើកលែងឱ្យមានការអនុវត្តជំនួសផងដែរ។ ចំពោះករណីយកិច្ចធ្វើសកម្មភាពជំនួសបាន ត្រូវអនុវត្តតាមវិធីនៃការអនុវត្តជំនួស ចំណែកករណីយកិច្ចដែលមិនអាចជំនួសបាន ដែលចាំបាច់ត្រូវបំពេញដោយកូនបំណុលផ្ទាល់ ការអនុវត្តត្រូវធ្វើតាមវិធីបង្ខំដោយប្រយោល[7]។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យបង្ហាញឆន្ទៈត្រូវតែជាការបង្ហាញឆន្ទៈដែលមានអានុភាពគតិយុត្តពិតប្រាកដ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាពណាមួយ៖ សំដៅលើសិទ្ធិដែលម្ចាស់សិទ្ធិអាចទាមទារមិនឱ្យកូនបំណុលមានករណីយកិច្ច ឬធ្វើសកម្មភាពណាមួយ ទោះបីជាសិទ្ធិនោះផ្អែកលើសិទ្ធលើ

[7] មាត្រា ៥២៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បំណុល ឬ សិទ្ធិប្រត្យក្សក៏ដោយ និងទោះបីកើតឡើងដោយកិច្ចសន្យា ឬច្បាប់ក៏ដោយ។ មានន័យថា សកម្មភាព នោះត្រូវបានរារាំងមិនឱ្យបំពេញ ឬមិនឱ្យធ្វើសកម្មភាពណាមួយ រួមទាំងការហាមឃាត់កូនបំណុលនៃការអនុវត្ត ការរារាំងការធ្វើសកម្មភាពណាមួយរបស់ម្ចាស់បំណុលនៃការអនុវត្តជាដើម។ សិទ្ធិទាមទារមិនឱ្យធ្វើសកម្មភាព ណាមួយ ត្រូវបានបែងចែកជា ករណីយកិច្ចតែមួយលើក និងករណីយកិច្ចច្រើនដង ករណីយកិច្ចបន្តបន្ទាប់។

## ផ្នែកទី២. គោលគំនិតនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

### កថាភាគទី១. អត្ថន័យនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជានីតិវិធីនៃការអនុវត្តមួយដែលស្ថិតនៅក្នុងប្រភេទនៃការ អនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ព្រោះគោលបំណងនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិ លើបំណុលនេះ គឺសងប្រាក់ទៅឱ្យម្ចាស់បំណុល។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជាការអនុវត្ត ដោយបង្ខំដើម្បីសម្រេចឱ្យបាននូវសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់ របស់ម្ចាស់បំណុល តាម រយៈការរឹបអូសសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងជាប្រាក់ ឬជាការប្រគល់ចលនវត្ថុដែលជារបស់កូន បំណុល ហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ។ យ៉ាងណាមិញ ការអនុវត្តដោយបង្ខំ គឺជា ការអនុវត្តដោយបង្ខំដែលធ្វើឡើងតាមវិធីដែល តុលាការអនុវត្តរឹបអូសយកសិទ្ធិលើបំណុលរបស់កូនបំណុលនៃ ការអនុវត្តចំពោះកូនបំណុលទី៣ ដើម្បីជួយសម្រេចសិទ្ធិលើបំណុលនៃម្ចាស់បំណុលនៃការអនុវត្តដែលមាន កំណត់នៅក្នុងលិខិតអនុវត្ត[8]។ កូនបំណុលទី៣ សំដៅដល់តតិយជនដែលជាកូនបំណុល របស់កូនបំណុលនៃ ការអនុវត្តដោយបង្ខំនោះ។ ហើយចំពោះសិទ្ធិ ឬទ្រព្យសម្បត្តិដែលបានលើកឡើងនេះ ជាសិទ្ធិ ឬ ទ្រព្យសម្បត្តិ ទាំងឡាយណាដែលជារបស់កូនបំណុលនៃការអនុវត្ត មានចំពោះតតិយជន។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិ លើបំណុលនេះ មានដូចជា ប្រាក់កម្ចី ប្រាក់បញ្ញើធនាគារ ជាអាទិ៍។ ចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើ បំណុលនេះ ក៏ដូចជាប្រភេទនៃការអនុវត្តដោយបង្ខំផ្សេងទៀតដែរ គឺមានកម្មវត្ថុនៃការអនុវត្តរៀងៗខ្លួន ដោយមិន មែនគ្រប់វត្ថុទាំងអស់សុទ្ធតែអាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទេ។ ជាក់ស្តែង សិទ្ធិលើបំណុលដែលអាចជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល រួមមាន សិទ្ធិទាមទារឱ្យសង ជាប្រាក់ និងសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ។

### កថាភាគទី ២. ប្រភេទនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

#### ១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់

ចំពោះសិទ្ធិ ឬទ្រព្យសម្បត្តិដែលបានលើកឡើងនេះ គឺជាសិទ្ធិឬ ទ្រព្យសម្បត្តិទាំងឡាយណាដែលជា របស់កូនបំណុលនៃការអនុវត្តមានចំពោះតតិយជន។ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនេះ មានដូចជា

[8] មាត្រា ៤០២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ប្រាក់កម្ចី ប្រាក់បញ្ញើធនាគារ ជាអាទិ៍។ ក្នុងចំណោមកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល សិទ្ធិដែលត្រូវបានអនុវត្តច្រើនជាងគេ គឺការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដែលមានគោលបំណងឱ្យសងជាប្រាក់នេះហើយ ដូចជាការទាមទារឱ្យសម្រេចការអនុវត្តចំពោះប្រាក់បញ្ញើរក្នុងធនាគារ សិទ្ធិលើបំណុលដែលកូនបំណុលនៃការអនុវត្តមានសិទ្ធិលើអ្នកផ្សេងជាអាទិ៍។ ដោយការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ គឺជាការសម្រេចការទាមទាររបស់ម្ចាស់បំណុល តាមរយៈសិទ្ធិលើបំណុលដែលកូនបំណុលមានជាមួយនឹងតតិយជន។ មានន័យថា សិទ្ធិលើបំណុលនេះគឺជាទំនាក់ទំនងរវាងកូនបំណុលនៃការអនុវត្តដោយបង្ខំដែលមានសិទ្ធិលើកូនបំណុលទី៣ដែលជាតតិយជន ហើយម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំនេះគឺ អនុវត្តទៅលើសិទ្ធិលើបំណុលដែលកូនបំណុលមានទៅលើកូនបំណុលទី៣ នោះ។

**២. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងឱ្យប្រគល់ចលនវត្ថុ**

ការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យប្រគល់ចលនវត្ថុ សំដៅដល់សម្រេចពីសិទ្ធិទាមទាររបស់ម្ចាស់បំណុលនៃការអនុវត្តដោយបង្ខំ ដែលត្រូវបានអនុវត្តចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការប្រគល់ចលនវត្ថុ ដោយហេតុចលនវត្ថុដែលជារបស់កូនបំណុលនោះ ត្រូវបានកាន់កាប់ដោយតតិយជន ហើយបានបដិសេធមិនព្រមប្រគល់ចលនវត្ថុនោះ។ ដោយហេតុនៃការបដិសេធរបស់តតិយជនក្នុងការប្រគល់ចលនវត្ថុរបស់កូនបំណុល នោះការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុមិនអាចអនុវត្តទៅបានឡើយ ដូចនេះពុំមានជម្រើសអ្វីផ្សេងឡើយ ក្រៅពីធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដោយរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុរបស់កូនបំណុលនោះ។

## ផ្នែកទី៣. ស្ថាប័នអនុវត្តដែលមានសមត្ថកិច្ច

ស្ថាប័នដែលទទួលបន្ទុកកាន់អំណាចក្នុងការធ្វើការអនុវត្តដោយបង្ខំដែលជាអំណាចរបស់រដ្ឋហើយគេហៅថា " ស្ថាប័នអនុវត្ត "[9]។ នីតិវិធីនៃការអនុវត្តដោយបង្ខំគឺជានីតិវិធីដាច់ដោយឡែកនិងឯករាជ្យពីនីតិវិធីបណ្តឹង ដូចនេះវាមិនចាំបាច់ដែលតុលាការដែលទទួលពាក្យបណ្តឹងត្រូវតែស្ថាប័នអនុវត្តនោះទេ។ លើសពីនេះទៅទៀត ដោយការគិតអំពីតម្រូវការនៃភាពងាយស្រួល និងភាពឆាប់រហ័សនូវការដាក់ ការទទួលបន្ទុកទៅឱ្យស្ថាប័នមួយផ្សេងទៀតគឺជាការសម្រេចស្របមួយ។ ហេតុនេះហើយទើបបានជាច្បាប់ចែងឱ្យតុលាការដែលមានសមត្ថកិច្ចក្នុងការអនុវត្តគឺ តុលាការអនុវត្ត និង អាជ្ញាសាលា ដែលជាស្ថាប័នអនុវត្ត[10]។ តុលាការអនុវត្ត និង អាជ្ញាសាលា គឺជាស្ថាប័នឯករាជ្យនៃអំណាចតុលាការ ស្ថាប័នទាំងពីរនេះមានចរិកលក្ខណៈផ្សេងពីគ្នា ដូច្នេះហើយបានជាច្បាប់ដាក់បន្ទុកការងារផ្សេងគ្នាទៅឱ្យស្ថាប័ននីមួយៗ ដោយអាស្រ័យទៅតាមកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងទៅ

[9] មាត្រា ៣៣៦ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[10] មាត្រា ៣៣៦ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តាមប្រភេទបែបបទនៃការអនុវត្ត ជាអាទិ៍។ ឧទាហរណ៍៖ ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែលតម្រូវឱ្យមានសកម្មភាពជាក់ស្តែងដោយប្រើប្រាស់កម្លាំងហើយត្រូវបានដាក់បន្ទុកទៅឱ្យអាជ្ញាសាលា ចំណែកឯការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលជាសកម្មភាពបញ្ញាមានលក្ខណៈអរូបី ដែលត្រូវបានទម្លាក់បន្ទុកទៅឱ្យតុលាការអនុវត្ត។

## កថាភាគទី១ តុលាការអនុវត្ត

តុលាការដែលមានសមត្ថកិច្ចធ្វើការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ឬដែលធ្វើការពាក់ព័ន្ធនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ គឺជាតុលាការអនុវត្ត។ ស្ថាប័នសម្រេចសេចក្តីដែលមានចៅក្រមនៃសាលាដំបូងដែលជាអង្គភាពរដ្ឋ គឺជាតុលាការអនុវត្ត។

### ១. សមត្ថកិច្ច

តុលាការអនុវត្តដើរតួនាទីជាស្ថាប័នអនុវត្តដោយផ្ទាល់ ប្រភេទនៃនីតិវិធីនៃការអនុវត្តដែលស្ថិតនៅក្រោមសមត្ថកិច្ចកិច្ចរបស់តុលាការ។ តុលាការអនុវត្តមានសមត្ថកិច្ចដូចជា៖

- ការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ[11]
- ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល[12]
- ការអនុវត្តដោយបង្ខំចំពោះនាវា
- ការអនុវត្តដោយបង្ខំឱ្យប្រគល់[13]។

សមត្ថកិច្ចរបស់តុលាការអនុវត្ត គឺជាសមត្ថកិច្ចផ្តាច់មុខ[14]។

### ២. នីតិវិធីនៃការអនុវត្តដោយតុលាការអនុវត្ត

ទម្រង់នៃសេចក្តីសម្រេច៖ ជាទូទៅ ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្តគឺធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្តី (សកម្មភាពធ្វើសេចក្តីសម្រេចសេចក្តី) ហើយទម្រង់បែការធ្វើសេចក្តីសម្រេចនេះគឺជាដីកាសម្រេច[15] បើក្នុងករណីយល់ឃើញថាចាំបាច់ នៅពេលចាត់ចែងធ្វើការអនុវត្ត តុលាការអនុវត្តអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ ឬជនផ្សេងទៀតដែលពាក់ព័ន្ធបាន[16]។

វិធានការនៃការអនុវត្តដែលបានកំណត់នៅក្នុងមាត្រា ៣៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ បានឆ្លុះបញ្ចាំងនូវទស្សនទានដ៏ទូលំទូលាយ ដែលមិនត្រឹមតែរួមបញ្ចូលនូវសកម្មភាពរបស់តុលាការ

[11] មាត្រា៤១៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[12] មាត្រា ៤០២ ៤០៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[13] មាត្រា ៤២៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[14] មាត្រា ៣៤៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[15] មាត្រា ៣៣៧ កថាខណ្ឌ១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[16] មាត្រា ៣៣៧ កថាខណ្ឌ២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

អនុវត្ត ដែលបានធ្វើឡើងនៅក្នុងនីតិវិធីនៃការអនុវត្ត ក៏ដូចជា ការរឹបអូស ការប្តូរប្រាក់ ការចែកចំណែក ជាអាទិ៍។ បន្ថែមលើសពីនេះទៅទៀតគឺ ថែមទាំងរួមបញ្ចូលនូវការចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យអនុវត្ត និង សកម្មភាពជាក់ស្តែងផ្សេងៗទៀត ដែលមិនមែនជាសេចក្តីសម្រេចសេចក្តីផងដែរ។

លើសពីនេះទៅទៀតជាគោលការណ៍ នៅក្នុងករណីដែលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រោម ទម្រង់ជាការចេញដីកាសម្រេចហើយតុលាការនោះមានឆន្ទានុសិទ្ធិនៅក្នុងការកំណត់ថា ត្រូវធ្វើការទាញហេតុ ផលដោយផ្ទាល់មាត់ ឬមិនត្រូវធ្វើ[17]។ ក្នុងករណីបើតុលាការមិនធ្វើការទាញហេតុផលដោយផ្ទាល់មាត់ទេ នោះ តុលាការអាចសួរភាគីបាន[18] នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ វិសាលភាពនៃអ្នកដែលតុលាការអាចសួរបាន ត្រូវបានពង្រីក គឺថាតុលាការអាចសួរជនដែលទាក់ទងនឹងផលប្រយោជន៍ថែមទៀត បន្ថែមពីលើការសួរភាគី។ ទៀតសោតនៅពេលតុលាការអនុវត្តធ្វើការចាត់ចែងការអនុវត្តក្រៅពីរការចាត់ចែងទម្រង់ជាការចេញដីកាសម្រេច (ឧទាហរណ៍៖ ដូចជាការរៀបចំឯកសារលំអិតអំពីវត្ថុដូចមានចែងនៅក្នុងមាត្រា ៤៣៤ ជាដើម) តុលាការអាចសួរ ជនទាំងនេះបានប្រសិនបើចាំបាច់។

**កថាភាគទី២. អាជ្ញាសាលា**

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យមួយ ដែលទទួលបន្ទុកធ្វើការបញ្ជូនឯកសារនានាដែលចេញ ដោយតុលាការ[19]និងធ្វើការអនុវត្តដោយបង្ខំមួយចំនួនដែលច្បាប់បានកំណត់។ ស្ថាប័នយុត្តាធិការស្ថិតនៅក្រោម ក្រសួងយុត្តិធម៌ និង មានសមាសភាពជាមន្ត្រីរាជការ ដែលមានឈ្មោះថាជា អាជ្ញាសាលាដែលបំពេញការងារនៅ សាលាដំបូងដែលរដ្ឋមន្ត្រីក្រសួងយុត្តិធម៌បង្គាប់ឱ្យធ្វើការ[20]។

អាជ្ញាសាលា ជាមន្ត្រីរាជការដែលត្រូវតែងតាំងដោយ ប្រកាសរបស់ក្រសួងយុត្តិធម៌ ចេញពីក្នុងចំណោម បុគ្គលដែលបានបំពេញគ្រប់លក្ខខណ្ឌទាមទារមួយចំនួន[21] ប៉ុន្តែខុសពីមន្ត្រីរាជការទូទៅ អាជ្ញាសាលាមិនទទួល ប្រាក់ខែពីរដ្ឋទេ គឺទទួលចំណូលជាប្រាក់កម្រៃពីអ្នកដាក់ពាក្យសុំ ចំពោះការអនុវត្តមុខងាររបស់ខ្លួនវិញ ដែលនេះ គឺជាចរិតលក្ខណៈពិសេសមួយរបស់អាជ្ញាសាលា[22]។

**១. សមត្ថកិច្ចរបស់អាជ្ញាសាលា**

អាជ្ញាសាលាត្រូវបំពេញមុខងារតួនាទីភារកិច្ចរបស់ខ្លួន នៅតំបន់សមត្ថកិច្ចរបស់សាលាដំបូងដែលខ្លួន បំពេញការងារ[23] និងមានការកម្រិតទៅលើតំបន់នៃការបំពេញមុខងារហើយនិងមុខនាទីរបស់ខ្លួននេះ មានឥទ្ធិពល

[17] មាត្រា ៣៣៥ និង មាត្រា ១១៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[18] មាត្រា ៣៣៥ និង មាត្រា ១១៤ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[19] មាត្រា ២៤៦ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[20] មាត្រា ២ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា លើកទី៣ ឆ្នាំ២០១២
[21] មាត្រា ៤ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា លើកទី៣ ឆ្នាំ២០១២
[22] មាត្រា ៣ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា លើកទី៣ ឆ្នាំ២០១២
[23] មាត្រា ៧ សេចក្តីព្រាងច្បាប់ស្តីពីអាជ្ញាសាលា លើកទី៣ ឆ្នាំ២០១២

ដោយប្រយោលទៅលើការកំណត់ដែនសមត្ថកិច្ចរបស់អាជ្ញាសាលា។ ចំពោះនីតិវិធីនៃការអនុវត្តដោយបង្ខំ ដែលអាជ្ញាសាលាជាអ្នកទទួលបន្ទុកដោយឯករាជ្យ ក្នុងនាមជាស្ថាប័នអនុវត្តរួមមាន ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ ការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុ ការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ។ នីតិវិធីនៃការអនុវត្តដោយបង្ខំដែលតុលាការអនុវត្តជាអ្នកទទួលបន្ទុកក្នុងនាមជាស្ថាប័នអនុវត្តអាជ្ញាសាលាមានសិទ្ធិអំណាចបន្ទាប់បន្សំលើចំណុចដូចតទៅៈ ការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំចំពោះអចលនវត្ថុ ការអនុវត្តការលក់ ការដកហូតលិខិតបញ្ជាក់សញ្ជាតិនាវាជាអាទិ៍ នៅក្នុងការអនុវត្តដោយបង្ខំចំពោះនាវា។ បន្ថែមលើសពីនេះទៅទៀត នៅក្នុងនីតិវិធីនៃការអនុវត្តរក្សាការពារ អាជ្ញាសាលាមានសិទ្ធិអំណាចនៅក្នុងការថែរក្សាគ្រប់គ្រងអចលនវត្ថុដែលជាកម្មវត្ថុនៃការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ថែមទៀត[24]។ អាជ្ញាសាលាត្រូវធ្វើការទំនាក់ទំនងជាមួយនឹងម្ចាស់បំណុលអាជ្ញាសាលាត្រូវធ្វើសកម្មភាពនៃការអនុវត្តដោយបង្ខំ ផ្អែកលើពាក្យសុំត្រឹមត្រូវតាមច្បាប់ របស់ម្ចាស់បំណុល និងដោយអនុលោមទៅតាមនិតិវិធីដែលបានកំណត់ដោយច្បាប់។ ទំនាក់ទំនងនេះគឺជាទំនាក់ទំនងរវាងបុគ្គលឯកជន និងដោយអាជ្ញាធររដ្ឋ ដែលនៅក្រោមបញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណីមិនមែនជាទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេ។

អាជ្ញាសាលា គឺជាស្ថាប័នយុត្តាធិការឯករាជ្យ អាជ្ញាសាលាត្រូវធ្វើការអនុវត្តដោយបង្ខំនៅក្នុងឆន្ទានុសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន។ អាជ្ញាសាលាធ្វើតាមការណែនាំរបស់ម្ចាស់បំណុលក៏ដោយ ប្រសិនបើសកម្មភាពនៃការអនុវត្តដោយបង្ខំនោះខុសច្បាប់ នោះអាជ្ញាសាលាមិនអាចគេចផុតពីការទទួលខុសត្រូវចំពោះសកម្មភាពនោះបានទេ។ អាជ្ញាសាលាអាចគោរពតាមឆន្ទៈរបស់ម្ចាស់បំណុលបានហើយចំពោះទំហំ និងកម្រិតនៃការអនុវត្តដោយបង្ខំ ប៉ុន្តែប្រសិនបើការណែនាំ ឬសំណូមពរនោះខុសច្បាប់ អាជ្ញាសាលាមិនត្រូវធ្វើតាមឡើយ។

ដោយសារថាសកម្មភាពរបស់អាជ្ញាសាលា គឺជាការប្រើអំណាចអនុវត្តរបស់រដ្ឋ នោះមន្ត្រីដែលទទួលបន្ទុកការអនុវត្ត ពុំមែនជានិយោជិតរបស់ម្ចាស់បំណុលឡើយ។ ហេតុនេះហើយប្រសិនបើអាជ្ញាសាលាបង្កឱ្យមានការខូចខាតដល់កូនបំណុល ឬតតិយដោយសារការអនុវត្តដោយបង្ខំម្ចាស់បំណុល មិនទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលក្នុងនាមជានិយោជកឡើយ។ ប៉ុន្តែប្រសិនបើម្ចាស់បំណុលឱ្យអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំមិនត្រឹមត្រូវដោយចេតនា ឬដោយការធ្វេសប្រហែស ហើយបង្កឱ្យមានការខូចខាតដល់អ្នកដទៃនោះម្ចាស់បំណុលអាចនឹងមានការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូលដោយផ្ទាល់។

ម្យ៉ាងវិញទៀត អាជ្ញាសាលាក៏ជាអ្នកដែលធ្វើទំនាក់ទំនងជាមួយនឹងកូនបំណុល និងតតិយជនផងដែរ។ អាជ្ញាសាលាមានសិទ្ធិប្រើប្រាស់អំណាចបង្ខំទៅលើកូនបំណុលនិងតតិយជននៅក្នុងទំហំដែលចាំបាច់ដើម្បី ធ្វើការអនុវត្តដោយបង្ខំហើយត្រូវទទួលខុសត្រូវក្នុងការធ្វើសកម្មភាពនេះដោយស្របច្បាប់។ បន្ថែមលើសពីនេះទៅទៀតដូចបានរៀបរាប់ខាងលើនេះដោយសារតែថា ទំនាក់ទំនងរវាងម្ចាស់បំណុល និង អាជ្ញាសាលាពុំមែនជា

[24] មាត្រា ៥៧១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទំនាក់ទំនងនៃអាណត្តិនៅក្រោមច្បាប់ឯកជនទេនោះ ម្ចាស់បំណុលមិនអាចប្រគល់ទៅឱ្យអាជ្ញាសាលានូវសិទ្ធិតំណាងតាមច្បាប់ឯកជនដូចជា ការទទួលការសង ឬការផ្សះផ្សារ បានឡើយ។ ប៉ុន្តែនៅក្នុងការអនុវត្តដោយបង្ខំចំពោះចលនវត្ថុ និងការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុ អាជ្ញាសាលាមានសិទ្ធិទទួលការអនុវត្តដោយស្ម័គ្រចិត្តទៅតាមច្បាប់បាន។ គោលបំណងនៃបញ្ញត្តិនេះគឺដើម្បីកុំឱ្យមានការខាតបង់នៅក្នុងការអនុវត្តក្នុងករណីដែលកូនបំណុលនៃការអនុវត្តមានឆន្ទៈធ្វើការសងដោយស្ម័គ្រចិត្ត។

តុលាការអនុវត្ត និងអាជ្ញាសាលា សុទ្ធតែជាស្ថាប័នឯករាជ្យរបស់រដ្ឋរៀងៗខ្លួន ហើយអាជ្ញាសាលាពុំមែនជាស្ថាប័នជំនួយបន្ថែមរបស់តុលាការអនុវត្តទេ។ ច្បាប់អនុញ្ញាតឱ្យតុលាការអនុវត្តផ្តល់ការណែនាំ ប្រគល់ និងបង្គាប់អាជ្ញាសាលានៅក្នុងករណីជាក់លាក់មួយចំនួនក៏ប៉ុន្តែបទប្បញ្ញតិទាំងនេះត្រូវបានរៀបចំឡើងដោយយកទំនាក់ទំនងឯករាជ្យរវាងស្ថាប័នទាំងពីរមកជាមូលដ្ឋាន និងដោយគិតពិចារណាទៅលើចរិតលក្ខណៈរបស់ស្ថាប័ននីមួយៗផង។ ដោយឡែកចំពោះរដ្ឋបាលយុត្តាធិការវិញ អាជ្ញាសាលាត្រូវទទួលការពិនិត្យពីសាលាដំបូងដែលខ្លួនស្ថិតនៅចំពោះមុខងាររបស់ខ្លួន។ ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលជាអ្នកតែងតាំងមានសិទ្ធិអំណាចដាក់ទណ្ឌកម្មខាងផ្នែកវិន័យ ចំពោះការបំពានលើមុខងាររបស់អាជ្ញាសាលា។

### ២. នីតិវិធីនៃការអនុវត្តដោយអាជ្ញាសាលា

អាជ្ញាសាលា ត្រូវយកតាមខ្លួននូវលិខិតដែលបញ្ជាក់អត្តសញ្ញាណ ឬលក្ខណៈសម្បត្តិរបស់ខ្លួន ហើយត្រូវបង្ហាញលិខិតនេះ ចំពោះជនដែលទាក់ទងទៅនឹងផលប្រយោជន៍បើជននោះទាមទារ[25]។ នៅក្នុងការអនុវត្តសិទ្ធិឆែកឆេរចំពោះអាជ្ញាសាលាអាចចូលទៅក្នុងទីកន្លែងរស់នៅរបស់កូនបំណុលនៃការអនុវត្ត ឬ កន្លែងផ្សេងទៀតដែលកូនបំណុលនៃការអនុវត្តនោះកាន់កាប់ ហើយធ្វើការឆែកឆេររកចលនវត្ថុដែលត្រូវរឹបអូសនៅក្នុងទំហំចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ។ ក្នុងករណីនេះប្រសិនបើមានភាពចាំបាច់អាជ្ញាសាលាអាចឱ្យកូនបំណុលនៃការអនុវត្ត បើកទ្វារដែលចាក់សោរ ទូដែក និងប្រអប់ផ្សេងទៀត ហើយប្រសិនបើកូនបំណុលនៃការអនុវត្តបដិសេធមិនព្រមធ្វើតាមទេអាជ្ញាសាលាអាចចាត់វិធានការណ៍ចាំបាច់ដើម្បីបើករបស់ទាំងនោះដោយប្រើកម្លាំង[26]។

ប្រសិនបើអាជ្ញាសាលាជួបប្រទះនឹងការប្រឆាំងនៅពេលបំពេញមុខនាទីរបស់ខ្លួន អាជ្ញាសាលានោះអាចប្រើកម្លាំង ឬ អាចសុំជំនួយពីនគរបាល ឬ ស្ថាប័នរដ្ឋផ្សេងទៀតដែលទទួលខុសត្រូវក្នុងការរក្សាសណ្តាប់ធ្នាប់សាធារណៈដើម្បីបំបាត់នូវការប្រឆាំងនោះបាន[27]។ នៅពេលចូលទៅទីកន្លែងរស់នៅរបស់ជនណាម្នាក់ ដើម្បីបំពេញមុខនាទីរបស់ខ្លួនបើមិនបានជួបនឹងម្ចាស់នៃទីកន្លែងរស់នៅ ឬអ្នកតំណាងរបស់អ្នកនោះ ឬញាតិនៅជាមួយ អ្នកបម្រើ អ្នកផ្សេងដែលធ្វើការនៅទីនោះដែលមានការយល់ដឹងសមរម្យទេ អាជ្ញាសាលាត្រូវហៅកអ្នកសង្កេតការណ៍ដែលអាចជាមន្ត្រីឃុំ-សង្កាត់ មន្ត្រីនគរបាលឬអ្នកដទៃទៀតដែលយល់ឃើញថាសមរម្យអាចធ្វើ

[25] មាត្រា ៣៤១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[26] មាត្រា ៣៨៥ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[27] មាត្រា ៣៣៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ជាអ្នកសង្កេតការណ៍បាន បន្ថែមលើសពីនេះទៅទៀតនៅក្នុងករណីដែលអាជ្ញាសាលាធ្វើការអនុវត្តដោយបង្ខំ ដោយប្រើកម្លាំង ឬ ដោយមានជំនួយពីនគរបាល ជាអាទិ៍ តាមបញ្ញាតិនៃមាត្រា ៣៣៨ កថាខណ្ឌទី ១ នោះបើទោះបីជាមិនចូលទៅក្នុងទីកន្លែងរស់នៅក៏ដោយក៏ចាំបាច់ត្រូវមានអ្នកសង្កេតការណ៍ដែរ[28]។ គោលបំណងនៃការកំណត់បែបនេះ គឺដើម្បីសង្កេតទៅលើភាពត្រឹមត្រូវនៅក្នុងការអនុវត្ត និងដើម្បីបង្កើតភស្តុតាងសម្រាប់ពេលអនាគតផង។

ដើម្បីចូលបំពេញមុខនាទីក្នុងទីកន្លែងរស់នៅរបស់ជនណាម្នាក់ នៅថ្ងៃអាទិត្យឬថ្ងៃឈប់សម្រាកដែលច្បាប់បានកំណត់ ឬនៅក្នុងចន្លោះពីម៉ោងប្រាំមួយល្ងាចដល់ម៉ោងប្រាំមួយព្រឹក អាជ្ញាសាលាត្រូវទទួលការអនុញ្ញាតពីសាលាដំបូងដែលខ្លួនស្ថាប័ន ឬតុលាការអនុវត្តដែលចេញដីកាបង្គាប់។ បន្ថែមលើសពីនេះទៅទៀតនៅពេលបំពេញមុខនាទីអាជ្ញាសាលាត្រូវបង្ហាញលិខិតដែលបញ្ជាក់ថាខ្លួនបានទទួលការអនុញ្ញាតនោះផងដែរ[29]។ ដោយការកំណត់បែបនេះគឺ ដើម្បីជៀសវាងការបៀតបៀនដល់ភាពស្ងប់សុខនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់កូនបំណុលដោយពុំមានភាពចាំបាច់។ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការបំពេញមុខនាទីរបស់ខ្លួនអាជ្ញាសាលាត្រូវរក្សាទុកកំណត់ហេតុអំពីការអនុវត្តដោយបង្ខំព្រមទាំងឯកសារផ្សេងៗទៀតដែលពាក់ព័ន្ធនឹងរឿងក្តីដែលមានការអនុវត្តដោយបង្ខំដើម្បីធ្វើជាសំណុំរឿងនៃការអនុវត្តដោយបង្ខំ[30]។

## ផ្នែកទី២. វិធីឧបាស្រ័យចំពោះការអនុវត្តខុសច្បាប់

នៅពេលអនុវត្តនីតិវិធីនៃការអនុវត្តដោយបង្ខំស្ថាប័នអនុវត្តត្រូវអនុលោមទៅតាមច្បាប់និងបទប្បញ្ញត្តិនានា ហើយត្រូវធ្វើការអនុវត្តនោះឱ្យស្របទៅតាមច្បាប់។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយភាពត្រឹមត្រូវតាមច្បាប់មិនមែនសុទ្ធតែត្រូវបានធានារហូតនោះទេ។ នៅក្នុងករណីដែលមានការអនុវត្តដោយបង្ខំផ្ទុយនឹងច្បាប់ ដូចជាក្នុងករណីដែលសកម្មភាពណាមួយរបស់ស្ថាប័នអនុវត្ត បំពានទៅលើក្រមនីតិវិធីជាដើម យើងមានវិធីឧបាស្រ័យចំពោះការអនុវត្តដែលរួមមានបណ្តឹងជំទាស់និងការតវ៉ាចំពោះការអនុវត្ត។ បណ្តឹងជំទាស់ គឺជានីតិវិធីឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ដែលមានលក្ខណៈជាការសម្រេចសេចក្តី រីឯការតវ៉ាចំពោះការអនុវត្តវិញ គឺជាឧបាស្រ័យចំពោះការចាត់ចែងការអនុវត្តដោយតុលាការអនុវត្តដោយអាជ្ញាសាលា[31]។

### កថាភាគទី ១. បណ្តឹងជំទាស់

#### ១. មូលហេតុនៃការប្តឹងជំទាស់

ការចាត់ចែងការអនុវត្តដោយតុលាការអនុវត្តជាទូទៅ ត្រូវបានធ្វើឡើងក្រោមទម្រង់ជាការសម្រេចសេចក្តីពោលគឺការចេញដីកាសម្រេច។ នៅក្នុងការចាត់ចែងការអនុវត្តដោយតុលាការអនុវត្ត ប្រសិនបើការចេញដីកា

[28] មាត្រា ៣៣៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[29] មាត្រា ៣៤០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[30] មាត្រា ៣៧៨ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[31] មាត្រា ៣៤៣ និង មាត្រា ៣៤៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

សម្រេច បំពានទៅលើក្រមនីតិវិធី និងផ្ទុយនឹងច្បាប់នោះវិធីឧបាស្រ័យចំពោះដីកាសម្រេចនោះគឺតាមរយៈបណ្ដឹងជំទាស់ដែលនេះគឺជាគោលការណ៍[32]។ ក៏ប៉ុន្តែមានបញ្ញត្តិចែងជាទូទៅថា បណ្ដឹងជំទាស់អាចធ្វើឡើងបាន លុះត្រាតែមានបញ្ញាត្តិក្នុងច្បាប់[33]។

បណ្ដឹងជំទាស់នៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំក៏អាចធ្វើឡើងបានតែក្នុងករណីដែលមានបញ្ញត្តិជាក់លាក់នៅក្នុងមាត្រានីមួយៗនៃគន្ថីទី ៦ ដែរ។ ឧទាហរណ៍៖ មាត្រា ៤០៣ កថាខណ្ឌទី១១ មាត្រា ៤១៩ កថាខណ្ឌទី៣ មាត្រា ៤៤៤ កថាខណ្ឌទី១ មាត្រា ៤៥៧ កថាខណ្ឌទី៧ មាត្រា ៤៧៥ កថាខណ្ឌទី១។ ប្រសិនបើបណ្ដឹងជំទាស់មិនអាចធ្វើបានទេនោះការតវ៉ាចំពោះការអនុវត្តត្រូវបានអនុញ្ញាត។

**២. បុគ្គលដែលមានសិទ្ធិដាក់ពាក្យបណ្ដឹងជំទាស់**

បុគ្គលដែលអាចដាក់ពាក្យបណ្ដឹងជំទាស់បានគឺបុគ្គលដែលទទួលរងការប៉ះពាល់ដោយសារដីកាសម្រេចដែលរួមមានម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត និងអាចជាតតិយជនផងដែរ។ ឧទាហរណ៍៖ កូនបំណុលទី៣ ដែលត្រូវបានហាមឃាត់មិនឱ្យសងបំណុល ដោយដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល[34]។

**កថាភាគទី ២. ការតវ៉ាចំពោះការអនុវត្ត**

ការតវ៉ាចំពោះការអនុវត្ត គឺជាវិធីឧបាស្រ័យដែលមានភាពងាយស្រួល និងឆាប់រហ័សជាងការដាក់ពាក្យបណ្ដឹងជំទាស់។ ការតវ៉ាចំពោះការអនុវត្តអាចធ្វើឡើង ចំពោះការចាត់ចែងការអនុវត្តរបស់តុលាការអនុវត្ត ដែលមិនអាចប្ដឹងជំទាស់បាន និងការចាត់ចែងការអនុវត្តរបស់អាជ្ញាសាលា និងការយឺតយ៉ាវ ឬ ការធ្វេសប្រហែសក្នុងការចាត់ចែងការអនុវត្តនោះ[35]។ ឧទាហរណ៍៖ ចំពោះដីកាសម្រេចចាប់ផ្ដើមការលក់ដោយបង្ខំនូវអចលនវត្ថុ ដោយតុលាការអនុវត្តមិនអាចប្ដឹងជំទាស់បានទេ ក៏ប៉ុន្តែការតវ៉ាចំពោះការអនុវត្តអាចធ្វើឡើងបាន។ ដោយសារតែថាដីកាសម្រេចលើកចោលពាក្យសុំឱ្យលក់ដោយបង្ខំ គឺជាការចាត់ចែងចុងក្រោយ ហើយមានភាពចាំបាច់ត្រូវតែអនុញ្ញាតឱ្យអាចប្ដឹងជំទាស់បាននៅក្នុងដំណាក់កាលនោះ។ ផ្ទុយទៅវិញដោយសារថា ដីកាសម្រេចចាប់ផ្ដើមមិនមែនជាការចាត់ចែងចុងក្រោយទេនោះទើបបានជាអនុញ្ញាតឱ្យត្រឹមតែការតវ៉ាចំពោះការអនុវត្តប៉ុណ្ណោះ ដែលជាវិធីងាយស្រួល ជាងបណ្ដឹងជំទាស់។ ការតវ៉ាចំពោះការអនុវត្តក៏អាចធ្វើឡើងបានដែរចំពោះការចាត់ចែងការអនុវត្តរបស់តុលាការ អនុវត្ត ដែលពុំមានចរិតលក្ខណៈជាដីកាសម្រេច ។

[32] មាត្រា ៣៣៥និង២៥៩ កថាខណ្ឌទី១ ចំណុច គ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[33] មាត្រា ២៥៩ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[34] មាត្រា ៤០៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[35] មាត្រា ៣៤៤ កថាខណ្ឌទី១ និង កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បន្ថែមលើសពីនេះទៅទៀតដោយសារថាសកម្មភាពរបស់អាជ្ញាសាលា ពុំមែនជាការសម្រេចសេចក្តីទេ នោះទើបបានជាបណ្តឹងជំទាស់មិនអាចធ្វើឡើងបានឡើយចំពោះសកម្មភាពទាំងនោះ តែអាចធ្វើការតវ៉ាចំពោះការអនុវត្តបាន ។

**១. មូលហេតុនៃការប្តឹងតវ៉ាចំពោះការអនុវត្ត**

មូលហេតុនៃការតវ៉ាចំពោះការអនុវត្តត្រូវបានកម្រិតត្រឹម ស្ថាប័នអនុវត្តបានបំពានទៅលើបញ្ញត្តិនៃនីតិវិធី ដែលខ្លួនត្រូវពិនិត្យ និង គោរពតាម។ ដូច្នេះហើយ ជាឧទាហរណ៍៖ ដោយសារថានត្ថិភាពនៃសិទ្ធិលើបំណុល ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត មិនមែនជាបញ្ហាដែលអាជ្ញាសាលា ត្រូវធ្វើការពិនិត្យទេនោះមូលហេតុនេះ មិនអាចអះអាងបានតាមរយៈការតវ៉ាចំពោះការអនុវត្តឡើយ (ក្នុងករណីនេះភាគីត្រូវធ្វើការអះអាងតាមរយៈបណ្តឹងតវ៉ាចំពោះការទាមទារដែលបានកំណត់) ។ ប្រសិនបើអាជ្ញាសាលាត្រូវធ្វើការចាត់ចែងការអនុវត្តណាមួយ តែមានភាពយឺតយ៉ាវនៅក្នុងការចាត់ចែងនោះវា គឺជាការបំពានទៅលើបញ្ញត្តិនៃនីតិវិធីហើយ។ នៅក្នុងករណីបែបនេះ ម្ចាស់បំណុលអាចធ្វើការតវ៉ាចំពោះការអនុវត្ត ហើយទាមទារឱ្យធ្វើការចាត់ចែងការអនុវត្តនោះបាន។

**២. បុគ្គលដែលមានសិទ្ធិធ្វើការប្តឹងតវ៉ាចំពោះការអនុវត្ត**

បុគ្គលដែលមានសិទ្ធិធ្វើការតវ៉ាចំពោះការអនុវត្តគឺជាអ្នកដែលទទួលរងការប៉ះពាល់ ដោយសារតែការចាត់ចែងការអនុវត្តខុសច្បាប់ ឬ ការធ្វេសប្រហែសក្នុង ការចាត់ចែងការអនុវត្ត ។ ក្រៅពីម្ចាស់បំណុលនៃការអនុវត្ត កូនបំណុលនៃការអនុវត្ត ឬតតិយជនក៏អាចធ្វើការតវ៉ាចំពោះការអនុវត្តបានដែរ។ ឧទាហរណ៍៖ ម្ចាស់បំណុល អាចធ្វើការតវ៉ាចំពោះការអនុវត្តបានប្រសិនបើអាជ្ញាសាលាលើកចោលពាក្យសុំឱ្យអនុវត្តដោយបង្ខំ ដែលធ្វើឡើងដោយត្រឹមត្រូវតាមច្បាប់ ឬធ្វេសប្រហែសមិនធ្វើការចាប់ផ្តើមការអនុវត្តដោយបង្ខំ។ កូនបំណុលអាចធ្វើការតវ៉ាចំពោះការអនុវត្តដោយបង្ខំបាន បើល័ក្ខខ័ណ្ឌទាមទារសម្រាប់ការចាប់ផ្តើមការអនុវត្តដោយបង្ខំ។ ឧទាហរណ៍៖ ការបញ្ជូនលិខិតអនុវត្ត ការមកដល់នូវពេលកំណត់ពិតប្រាកដ ជាអាទិ៍ ។ មិនត្រូវបានបំពេញ ឬប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំដែលធ្វើឡើងដោយអាជ្ញាសាលានោះខុសច្បាប់។ ឧទាហរណ៍៖ ការអនុវត្តដោយបង្ខំនៅពេលយប់ដោយពុំមានការអនុញ្ញាត ការរឹបអូសចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស។ តតិយជនអាចធ្វើការតវ៉ាចំពោះការអនុវត្តបានប្រសិនបើខ្លួនបានទទួលរងការប៉ះពាល់ដោយសារការអនុវត្តខុសច្បាប់ ដូចជាករណីនៃការរឹបអូសទ្រព្យដោយយល់ច្រឡំថាទ្រព្យនោះជាកម្មសិទ្ធិរបស់កូនបំណុលបើទោះបីជាមានភាពច្បាស់លាស់ថាទ្រព្យនោះ ជាកម្មសិទ្ធិរបស់តតិយជនក៏ដោយ ។

# ជំពូកទី២

# លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

# ជំពូកទី២
# លក្ខខណ្ឌនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

## ផ្នែកទី១. ការដាក់ពាក្យសុំ

### កថាភាគទី១. ការពិនិត្យពាក្យសុំ

ការដាក់ពាក្យសុំជាគោលការណ៍ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត ដោយធ្វើតាមការដាក់ពាក្យសុំរបស់ភាគីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ក៏ត្រូវដាក់ពាក្យសុំទៅតុលាការអនុវត្តផងដែរ[36]។ ចំពោះកន្លែងនេះ គឺមានន័យថា ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមិនមែនជានីតិវិធីដែលត្រូវបានចាប់ផ្តើមឡើងដោយស្វ័យប្រវត្តិដោយមិនមានការដាក់ពាក្យសុំនោះទេ។ លើសពីនេះទៅទៀត ការចាប់ផ្តើមនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនេះ គឺជាការបញ្ជាក់បានថានីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលជានីតិវិធីឯករាជ្យពីនីតិវិធីបណ្តឹង។ ស្ថាប័នអនុវត្តនៅក្នុងន័យនេះគឺសំដៅទៅដល់សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលជាលំនៅដ្ឋាន ឬ ការិយាល័យ ជាអាទិ៍ របស់កូនបំណុលស្ថិតនៅ។ បន្ថែមលើសពីនេះទៅទៀត ពាក្យសុំអនុវត្តដោយបង្ខំពោះសិទ្ធិលើបំណុលត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរចំពោះចំណុចដែលត្រូវសរសេរក្នុងពាក្យសុំអនុវត្តដោយបង្ខំគឺមានចែងនៅក្នុងមាត្រា ៣៤៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា៤០៣ នៃក្រមរដ្ឋប្បវេណី។ ដោយយោងទៅតាមមាត្រា ៣៤៩ កថាខណ្ឌទី២ ចំណុចដែលត្រូវសរសេរក្នុងពាក្យសុំ និង ពិនិត្យពាក្យសុំនេះយ៉ាងសំខាន់រួមមាន៖

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្តនិង កូនបំណុលនៃការអនុវត្ត ហើយនិងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់។ ឈ្មោះនៅក្នុងន័យមួយនេះសំដៅទៅដល់ឈ្មោះរបស់រូបវន្តបុគ្គល ឬឯនាមករណ៍ សំដៅទៅដល់ឈ្មោះរបស់នីតិបុគ្គល
- សញ្ញាណនៃលិខិតអនុវត្ត គឺសំដៅទៅដល់ប្រភេទនៃលិខិតអនុវត្ត វាអាចជាសេចក្តីសម្រេចរបស់តុលាការ និង កំណត់ហេតុផ្សេងៗតាមផ្លូវតុលាការដែលមានអានុភាព ដូចសេចក្តីសម្រេចរបស់តុលាការ ឬលិខិតយថាភូតដែលធ្វើឡើងដោយសារការី[37]
- ម្ចាស់បំណុលនៃការអនុវត្តត្រូវសរសេរបញ្ជាក់នូវសញ្ញាណលិខិតអនុវត្ត ប្រសិនបើលិខិតអនុវត្តជាសាលក្រម ឬ សាលដីកា ម្ចាស់បំណុលនៃការអនុវត្តគប្បីសរសេរលេខ កាលបរិច្ឆេទ និង តុលាការចេញសាលក្រម ឬសាលដីកានោះ

---

[36] មាត្រា ៤០៣ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[37] មាត្រា ៣៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- សេចក្តីស្នើសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ ឬការអនុវត្តជំនួស ឬវិធានបង្ខំដោយប្រយោល។ តាមការអនុវត្តបង្ខំដោយផ្ទាល់នេះជាប្រភេទនៃការអនុវត្តដោយបង្ខំ ដែលខ្លឹមសារនៃលិខិតអនុវត្តមានគោលបំណង ឱ្យកូនបំណុលនៃការអនុវត្តសងជាប្រាក់។

ចំពោះការអនុវត្តជំនួសគឺជាវិធាននៃការអនុវត្តដោយបង្ខំដែលខ្លឹមសារនៃលិខិតអនុវត្ត ដោយបង្ខំឱ្យកូនបំណុលនៃការអនុវត្តធ្វើសកម្មភាពណាមួយ ហើយសកម្មភាពនេះអាចឱ្យតតិយជនធ្វើជំនួសកូនបំណុលនៃការអនុវត្តបាន។ ការអនុវត្តប្រភេទនេះត្រូវធ្វើតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចអនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តឱ្យតតិយជនបំពេញសម្មភាពនោះជំនួស ដោយប្រើសោហ៊ុយរបស់កូនបំណុលនៃការអនុវត្តតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[38]។

ចំណែកឯ វិធានអនុវត្តដោយប្រយោលវិញ គឺជាវិធាននៃការអនុវត្តដោយបង្ខំដែលឱ្យកូនបំណុលនៃការអនុវត្តធ្វើឬមិនធ្វើសកម្មភាព អ្វីមួយក៏អាចធ្វើបានតាមវិធីដែលតុលាការអនុវត្តចេញដីកាសម្រេចបង្គាប់ឱ្យកូនបំណុលនៃការអនុវត្ត ឱ្យបង់នូវចំនួនទឹកប្រាក់ជាកំណត់ដែលទទួលស្គាល់ថាសមរម្យដើម្បីធានាការអនុវត្តកាតព្វកិច្ចទៅឱ្យម្ចាស់បំណុលនៃការអនុវត្តស្របទៅតាមអំឡុងពេលដែលទទួលស្គាល់ថាសមរម្យដើម្បីអនុវត្តកាតព្វកិច្ច[39]។

- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និង វិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំ ក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់ សញ្ញាណនៃទ្រព្យសម្បត្តិនេះម្ចាស់បំណុលនៃការអនុវត្តត្រូវបញ្ជាក់ពីអាស័យដ្ឋានអចលនវត្ថុរបស់កូនបំណុលនៃការអនុវត្តឱ្យបានច្បាស់លាស់។
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំដោយផ្ទាល់ ឬតាមការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល។ ចំនួននៃសិទ្ធិលើបំណុល និងការបញ្ជាក់អំពីកូនបំណុលទី៣។

## កថាភាគទី២. លិខិតអនុវត្ត

### ១. អត្ថន័យនៃលិខិតអនុវត្ត

លិខិតអនុវត្ត គឺជាឯកសារមួយដែលបានបញ្ជាក់អំពីសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកណាមួយជាក់លាក់ដែលបានកំណត់នៅក្រោមនីតិឯកជនហើយដោយផ្អែកលើឯកសារនេះ ច្បាប់ផ្តល់ឱ្យនូវអំណាចបង្ខំឱ្យអនុវត្តដើម្បីសម្រេចនូវអត្ថន័យនៃសិទ្ធិនោះតាមរយៈការអនុវត្តដោយបង្ខំ។ ខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំត្រូវកំណត់ដោយផ្អែកទៅលើលិខិតអនុវត្ត។ ខ្លឹមសារ និងវិធីនៃការអនុវត្តដោយបង្ខំអាចត្រូវបានកម្រិត ឬបន្ថែមដោយរូបមន្តអនុវត្ត។

[38] មាត្រា ៥២៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[39] មាត្រា ៥២៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

លិខិតអនុវត្ត រួមមានជាចម្បងដូចជាសេចក្តីសម្រេចរបស់តុលាការ និងកំណត់ហេតុផ្សេងៗ តាមផ្លូវតុលាការដែលមានអានុភាពដូចសេចក្តីសម្រេចរបស់តុលាការ។ ក្រៅពីនេះមានលិខិតយថាភូតដែលធ្វើឡើងដោយសារការីជាដើម។

**២. អត្ថន័យនៃលិខិតអនុវត្ត**

ប្រភេទនៃលិខិតអនុវត្តដែលអាចឱ្យម្ចាស់បំណុលអនុវត្តដោយបង្ខំបាន គឺមានដូចជា៖

**១. សាលក្រមឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលបានចូលជាស្ថាពរ៖**

សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលចេញដោយតុលាការនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានទទួលស្គាល់ថាជាលិខិតអនុវត្ត។ ក្នុងចំណោមសាលក្រម ឬសាលដីកាចុងក្រោយដែលបានចូលជាស្ថាពរ មានតែសាលក្រម ឬសាលដីកាដែលបង្គាប់ឱ្យផ្តល់តាវកាលិកតែប៉ុណ្ណោះដែលមានអានុភាពអនុវត្ត។ ទោះបីជាក្នុងករណីដែលសាលក្រម ឬសាលដីកាដែលពាក់ព័ន្ធគឺជាសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកក៏ដោយប្រសិនបើការអនុវត្តដោយបង្ខំមិនអាចធ្វើទៅបានអាស្រ័យដោយចរិតលក្ខណៈនៃសិទ្ធិទាមទារឱ្យផ្តល់តាវកាលិកនោះសាលក្រម ឬសាលដីកានោះមិនមានអានុភាពអនុវត្តទេ។

**២. សាលក្រមឬសាលដីកាចុងក្រោយដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន៖**

ស្រដៀងគ្នាទៅនឹងករណីនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរដែរ ដោយសារថាការអនុវត្តដោយបង្ខំដែលផ្អែកលើសាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបង្ខំនឹងធ្វើឱ្យមានការវិត្ត ទៅដល់ការសម្រេចនូវសិទ្ធិទាមទារជាស្ថាពរ ដូច្នេះការសម្រេចសិទ្ធិនេះមិនមានលក្ខណៈបណ្តោះអាសន្នទេ។

**៣. ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក៖**

ជាគោលការណ៍ដីកាសម្រេចមានអនុភាពភ្លាមបន្ទាប់ពីបានធ្វើការជូនដំណឹង។ ប្រសិនបើដីកាសម្រេចនោះគឺជាដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក ដីកាសម្រេចនោះត្រូវមានអានុភាពអនុវត្ត។ ឧទាហរណ៍៖ ដីកាសម្រេចបង្គាប់ឱ្យបង់ជាមុននូវសោហ៊ុយចាំបាច់សម្រាប់ការអនុវត្តជំនួស[40] ដីកាសម្រេចបង្គាប់ឱ្យបង់ប្រាក់ដើម្បីធានាការនូវការអនុវត្តកាតព្វកិច្ចនៅក្នុងវិធានដោយប្រយោល[41]។

**៤. ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន៖**

ប្រសិនបើកូនបំណុលមិនដាក់ពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿន ក្នុងអំឡុងពេលពីរសប្តាហ៍បន្ទាប់ពីថ្ងៃទទួលការបញ្ជូនដីកាសម្រេចដាស់តឿន ឬប្រសិនបើដីកាសម្រេចដែលលើកចោលនូវពាក្យសុំតវ៉ាចំពោះដីកាសម្រេចដាស់តឿនបានចូលជាស្ថាពរ នោះការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននឹងត្រូវបានភ្ជាប់

[40] មាត្រា ៥២៧ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[41] មាត្រា ៥២៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទៅនឹងដីកាសម្រេចដាស់តឿន ហើយដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តដោយបណ្ដោះអាសន្ននោះនឹងក្លាយជាលិខិអនុវត្ត។

**៥. ការចាត់ចែងរបស់ក្រឡាបញ្ជី ដែលកំណត់អំពីចំនួនប្រាក់ប្រដាប់ក្ដី៖**

បន្ទាប់ពីតុលាការបានវិនិច្ឆ័យអំពីភាគ និងបន្ទុកប្រាក់ប្រដាប់ក្ដីហើយ ចំនួនទឹកប្រាក់លម្អិត ត្រូវកំណត់ដោយក្រឡាបញ្ជីនៃសាលាដំបូងតាមពាក្យសុំរបស់ភាគី[42]។ ភាគីម្ខាងអាចធ្វើការអនុវត្តដោយឱ្យភាគីម្ខាងទៀតសងប្រាក់ប្រដាប់ក្ដី ដោយយកការចាត់ចែងរបស់ក្រឡាបញ្ជីនេះធ្វើជាលិខិតអនុវត្ត។

**៦. លិខិតបញ្ជាក់អនុវត្ត (លិខិតយថាភូតដែលធ្វើឡើងដោយសារការី)៖**

លិខិតយថាភូតដែលធ្វើឡើងដោយសារការី និងដែលបានបំពេញតាមល័ក្ខខ័ណ្ឌទាមទារមួយចំនួន ត្រូវបានទទួលស្គាល់ថាមានអានុភាពអនុវត្តក្នុងលក្ខណៈជាលិខិតអនុវត្ត។ លិខិតយថាភូតធ្វើឡើងដោយសារការីដែលបានបំពេញតាមល័ក្ខខ័ណ្ឌទាមទារមួយចំនួននេះ ហៅថា លិខិតបញ្ជាក់អនុវត្ត។ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់ ហើយដែលនៅក្នុងលិខិតនោះបានបញ្ជាក់សេចក្ដី ថ្លែងការណ៍ថា កូនបំណុលនឹងទទួលការអនុវត្តដោយបង្ខំភ្លាមៗ។

**៧. សាលក្រម ឬសាលដីការបស់តុលាការបរទេស ដែលមានសាលក្រមអនុវត្តដែលបានចូលជាស្ថាពរ៖**

ប្រសិនបើសាលក្រម ឬសាលដីការបស់តុលាការបរទេស បានបំពេញគ្រប់ល័ក្ខខ័ណ្ឌមួយចំនួនសាលក្រម ឬសាលដីកាបរទេសនោះ នឹងត្រូវបានអនុវត្តទទួលស្គាល់នូវអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពររបស់ តុលាការកម្ពុជាទើបអាចធ្វើការអនុវត្តបាន[43]។

**៨. សេចក្ដីសម្រេចមជ្ឈត្តករ ដែលមានដីកាសម្រេចអនុវត្តដែលបានចូលជាស្ថាពរ៖**

នីតិវិធីមជ្ឈត្តកម្ម គឺជានីតិវិធីនៃការដោះស្រាយវិវាទជំនួសនីតិវិធីបណ្ដឹង ហើយសេចក្ដីសម្រេចមជ្ឈត្តករដែលជាលទ្ធផលនៃនីតិវិធីនេះមានអានុភាពចងចំពោះភាគី ដូចជាសាលក្រម ឬសាលដីកាស្ថាពរដែរ។ ប៉ុន្តែយ៉ាងណាក៏ដោយ ដើម្បីធ្វើការអនុវត្តដោយបង្ខំដោយផ្អែកលើសេចក្ដីសម្រេចមជ្ឈត្តករ ទោះបីជាសេចក្ដីសម្រេចមជ្ឈត្តករក្នុងប្រទេសក៏ដោយ ឬបរទេសក៏ដោយត្រូវទទួលដីកាសម្រេចអនុវត្តរបស់តុលាការនៅព្រះរាជាណាចក្រកម្ពុជា។ ភាគីត្រូវដាក់ឯកសារដូចខាងក្រោមៈ

- ច្បាប់ដើមនៃសេចក្ដីសម្រេចមជ្ឈត្តករ ដែលត្រូវបានបញ្ជាក់ដោយត្រឹមត្រូវ ឬឯកសារចម្លងដែលមានសេចក្ដីបញ្ជាក់ត្រឹមត្រូវ។
- ច្បាប់ដើមនៃកិច្ចសន្យាមជ្ឈត្តកម្ម ឬ ឯកសារចម្លងនៃកិច្ចសន្យានោះដែលមានសេចក្ដីបញ្ជាក់ត្រឹមត្រូវ។

ពាក្យសុំចេញដីកាសម្រេចអនុវត្តសេចក្ដីសម្រេចមជ្ឈត្តករក្នុងប្រទេស ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់

[42] មាត្រា ៦៦ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[43] មាត្រា ១៩៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការដែលមានសមត្ថកិច្ចលើកន្លែងរបស់កូនក្តីនៃការអនុវត្ត[44]។ ចំពោះពាក្យសុំចេញដីកាសម្រេចអនុវត្ត សេចក្តីសម្រេចមជ្ឈត្តករបរទេសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។

**៩. កំណត់ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរៈ**

កំណត់ហេតុនៃការទទួលស្គាល់ការទាមទារ និងកំណត់ហេតុនៃការសះជាតាមផ្លូវតុលាការ[45]សុទ្ធតែត្រូវបានរាប់ចូលជាកំណត់ ហេតុដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរ។

**១០. លិខិតអនុវត្តដើម្បីអនុវត្តសិទ្ធិប្រាតិៈ**

- សាលក្រម ឬសាលដីកាស្ថាពរ ដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ ឬលិខិតដែលមានអានុភាពដូចសាលក្រម ឬសាលដីកាស្ថាពរនោះ។ នៅក្នុងករណីកិច្ចសន្យាប្រាតិភោគដែលធ្វើឡើងដោយឯកជន និងឯកជន ត្រូវបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគដោយតុលាការ
- លិខិតយថាភូតដែលធ្វើឡើងដោយសារការី ហើយដែលបញ្ជាក់អំពីអត្ថិភាពនៃសិទ្ធិប្រាតិភោគ បើកិច្ចសន្យាប្រាតិភោគដែលធ្វើឡើងដោយសារការីការបញ្ជាក់ពីអត្ថិភាពនៃសិទ្ធិប្រាតិភោគត្រូវធ្វើឡើងដោយសារការី។

## ផ្នែកទី២. រូបមន្តអនុវត្ត

### កថាភាគទី១. អត្ថន័យនៃរូបមន្តអនុវត្ត

រូបមន្តអនុវត្ត គឺជាប្រយោគដែលក្រឡាបញ្ជី ឬសារការី សរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និងដែលបញ្ជាក់ជាផ្លូវការនូវអត្ថិភាព និងអត្ថន័យនៃអំណាចបង្ខំឱ្យអនុវត្តនៃលិខិតអនុវត្ត។ ជាទូទៅស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[46]។ អត្ថិភាពនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត គឺជាល័ក្ខខ័ណ្ឌទាមទារសម្រាប់ការអនុវត្តដោយបង្ខំ។ ម្យ៉ាងវិញទៀត ប្រសិនបើមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយរូបមន្តអនុវត្តហើយ នោះស្ថាប័នអនុវត្តត្រូវធ្វើការអនុវត្តដោយបង្ខំ ដោយមិនចាំបាច់ពិនិត្យពិចារណាលើខ្លឹមសារនៃលិខិតអនុវត្តនោះទេ។

ហេតុនេះហើយ ទោះបីជាឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តខុសគ្នាពីលិខិតអនុវត្តច្បាប់ដើម ឬប្រសិនបើរូបមន្តអនុវត្តនោះត្រូវបានផ្តល់ដើម្បីជាផលប្រយោជន៍ ឬទៅឱ្យបុគ្គលណាម្នាក់ដែលពុំមានលក្ខណៈជាភាគីនៃការអនុវត្តដោយបង្ខំក៏ដោយ ឬទោះបីជាលិខិតអនុវត្តនោះបាត់បង់អានុភាពក៏ដោយ ក៏ការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តនោះ នៅតែជាការអនុវត្តស្របតាមច្បាប់ស្តីពីការអនុវត្តដោយបង្ខំដែរ។ ជាគោលការណ៍ ទោះបីជា

[44] មាត្រា ៣៥៣ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[45] មាត្រា ២២២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[46] មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ដើម្បីអាចដាក់ពាក្យសុំឱ្យអនុវត្ត ដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគបានម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូបមន្តអនុវត្តសិនជានិច្ច។

ប៉ុន្តែក៏មានករណីលើកលែង ប្រសិនបើលិខិតអនុវត្ត គឺជាសាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬ ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ននោះពុំចាំបាច់មានរូបមន្តអនុវត្តទេ[47]។

### ១. ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត

ពាក្យសុំរូបមន្តអនុវត្តត្រូវធ្វើឡើងដោយលិខិតជាលាយល័ក្ខណ៍អក្សរ ដែលត្រូវសរសេរចំណុចដូចខាងក្រោម[48]៖

- ឈ្មោះ ឬ នាមករណ៍និងអាសយដ្ឋានរបស់ម្ចាស់បំណុលនៃការអនុវត្តនិងកូនបំណុលនៃការអនុវត្ត ហើយនឹង ឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់
- សញ្ញាណនៃលិខិតអនុវត្ត
- ហេតុការណ៍ និងមូលហេតុ បើការទាមទារឱ្យផ្តល់រូបមន្តអនុវត្តត្រូវធ្វើឡើងចំពោះបុគ្គលផ្សេង ក្រៅពីភាគីដែលត្រូវសរសេរឡើងនៅលើលិខិតអនុវត្តធ្វើជាម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តក្រឡាបញ្ជី ឬសារការីត្រូវធ្វើការស្រាវជ្រាវអំពីអត្ថិភាពនៃល័ក្ខខ័ណ្ឌទាមទារនានាសម្រាប់ការផ្តល់រូបមន្តអនុវត្ត និងការធ្វើការសម្រេចដោយឯករាជ្យ និងដោយឆន្ទានុសិទ្ធិថា តើគួរផ្តល់រូបមន្តអនុវត្តតាមពាក្យសុំឬមិនផ្តល់។ ក៏ប៉ុន្តែដើម្បីផ្តល់រូបមន្តពិសេស ក្រឡាបញ្ជីត្រូវទទួលសេចក្តីអនុញ្ញាតពីតុលាការដែលខ្លួនស្ថិតនៅសិន[49]។

### ២. ស្ថាប័នផ្តល់រូបមន្តអនុវត្តដោយបង្ខំ

ការផ្តល់រូបមន្តអនុវត្តត្រូវបានធ្វើឡើងដោយក្រឡាបញ្ជី ឬ សារការី ទៅតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ក្នុងករណីដែលលិខិតអនុវត្តគឺជាសាលក្រម ឬសាលដីកា ស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការផ្តល់រូបមន្តអនុវត្តគឺក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនៃបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬសាលដីកានោះ។ តែក្នុងករណីដែលលិខិតអនុវត្តគឺជាលិខិតបញ្ជាក់អនុវត្តសារការីដែលរក្សាទុកនូវច្បាប់ដើម នៃលិខិតអនុវត្តនៃលិខិតបញ្ជាក់នោះ គឺជាស្ថាប័នផ្តល់រូបមន្តអនុវត្ត[50]។ នៅក្នុងករណីដែលលិខិតអនុវត្ត គឺជា

---

47 មាត្រា ៣៥៤ កថាខណ្ឌទី១ វាក្យខណ្ឌទី២ ចំណុច ក ដល់ គ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

48 មាត្រា ៣៥៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

49 មាត្រា ៣៥៦ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

50 មាត្រា ៣៥៦ កថាខណ្ឌទី២ វាក្យខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

លិខិតបញ្ជាក់អនុវត្ត សារការីដែលរក្សាទុកនៅច្បាប់ដើមនៃលិខិតបញ្ជាក់នោះ គឺជាស្ថាប័នដែលផ្តល់រូបមន្តអនុវត្ត[51]។

**កថាភាគទី២. ប្រភេទនៃរូបមន្តអនុវត្ត**

ការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត[52]។ រូបមន្តអនុវត្ត ដែលត្រូវបានប្រើនៅក្នុងនីតិវិធីនៃការអនុវត្តដោយបង្ខំ រួមមាន រូបមន្តអនុវត្តធម្មតា និងរូបមន្តអនុវត្តពិសេស។ ជាគោលការណ៍ ទោះបីជាមានលិខិតអនុវត្តប្រភេទណាមួយក៏ដោយ ដើម្បីអាចដាក់ពាក្យ សុំឱ្យអនុវត្តដោយបង្ខំនូវសិទ្ធិទាមទារ ឬសិទ្ធិប្រាតិភោគបាន ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបាននូវការផ្តល់រូបមន្តសិនជានិច្ច។ ទោះបីជាលិខិតអនុវត្តដែលម្ចាស់បំណុលមានសេចក្តីប្រកាសថាៈ ការអនុវត្តដោយបង្ខំអាចធ្វើទៅបានដោយផ្អែកលើលិខិតនោះ (ដូចជា សាលក្រម ឬសាលដីកា) ក៏ចាំបាច់ត្រូវតែបានទទួលការផ្តល់រូបមន្តអនុវត្តសិនដែរ។ ជាករណីលើកលែង បើលិខិតអនុវត្ត គឺជាសាលក្រមនៃបណ្តឹងរឿងក្តីដែលមានចំនួនទឹក ប្រាក់តិចដែលបានចូលជាស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនទឹកប្រាក់តិចដែលភ្ជាប់ជាមួយ នឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ឬក៏ជាដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹង ការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ពុំចាំបាច់មានរូបមន្តអនុវត្តទេ។

រូបមន្តអនុវត្តធម្មតា សំដៅដល់រូបមន្តអនុវត្តដែលត្រូវផ្តល់ ក្រៅពីល័ក្ខខ័ណ្ឌដែលត្រូវផ្តល់ រូបមន្តអនុវត្តពិសេស។ ចំពោះលិខិតអនុវត្តជាសេចក្តីសម្រេចដែលមិនបង្កើតអានុភាពជាស្ថាពរទេ ប្រសិនបើម្ចាស់បំណុលនៃការអនុវត្តដាក់ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្តចំពោះលិខិតខាងលើនេះ ត្រូវភ្ជាប់ពាក្យសុំនូវលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសេចក្តីសម្រេចនោះ[53]។

ចំណែករូបមន្តអនុវត្តពិសេស គឺជារូបមន្តអនុវត្តដែលត្រូវបានផ្តល់ដោយក្រឡាបញ្ជី ឬសារការី ក្នុងករណីដូចជាៈ ករណីសិទ្ធិទាមទារ ដែលកំណត់ក្នុងលិខិតអនុវត្តភ្ជាប់ជាមួយល័ក្ខខ័ណ្ឌបង្អង់ ឬពេលកំណត់មិនពិតប្រាកដ។ រួមទាំងក្នុងករណីការអនុវត្តដោយបង្ខំដោយយកបុគ្គលផ្សេងពីភាគីដែលបានសរសេរក្នុងលិខិតអនុវត្តដូចជាអ្នកបន្តសិទ្ធិ ដែលនាំឱ្យម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលបានរូបមន្តអនុវត្តពិសេស ដែលមានសរសេរនូវហេតុការណ៍បញ្ជាក់ក្នុងរូបមន្តអនុវត្ត។

**១. នីតិវិធីផ្តល់រូបមន្តអនុវត្ត**

រូបមន្តអនុវត្ត ត្រូវបានផ្តល់ដោយក្រឡាបញ្ជីនៃតុលាការដែលមានសំណុំរឿងនោះតាមពាក្យសុំ។ ជាគោលការណ៍ ការផ្តល់រូបមន្តអនុវត្តមិនចាំបាច់ជូនដំណឹងទៅកូនបំណុលនៃការអនុវត្តទេ ក៏ប៉ុន្តែក្នុងករណីដែលផ្តល់រូមន្តអនុវត្ត នៅក្នុងលិខិតចម្លងយថាភូតច្រើនច្បាប់នៃលិខិតអនុវត្ត ត្រូវជូនដំណឹងអំពីហេតុនោះ ទៅកូន

[51] មាត្រា ៣៥៦ កថាខណ្ឌទី២ វាក្យខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[52] មាត្រា ៣៥៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[53] មាត្រា ៣៥៥ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បំណុលនៃការអនុវត្តឱ្យបានដឹង[54]។ បន្ទាប់ពីមានពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត ការផ្តល់រូបមន្តអនុវត្ត ត្រូវធ្វើឡើងតាមវិធីសរសេរភ្ជាប់បន្ថែម នៅផ្នែកក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត នូវចំណុចនីមួយៗដូចជា៖[55]

- បុគ្គលដែលអាចទាមទារឱ្យធ្វើការអនុវត្តដោយបង្ខំបាន ដោយលិខិតអនុវត្ត នោះ និង ភាគីម្ខាងទៀត ។
- ហេតុការណ៍ ក្នុងករណីដែលបានផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃរូបមន្តអនុវត្តពិសេស
- ទំហំដែលអាចអនុវត្តដោយបង្ខំបាន បើបានផ្តល់រូបមន្តអនុវត្តតែមួយផ្នែកនៃ សិទ្ធិទាមទារដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត
- ហេតុការណ៍ ក្នុងករណីដែលផ្តល់រូបមន្តអនុវត្ត តាមបញ្ញត្តិនៃការផ្តល់រូបមន្តអនុវត្តច្រើនច្បាប់

ជាចុងក្រោយនៃការអនុញ្ញាតផ្តល់រូបមន្តអនុវត្ត គឺក្រឡាបញ្ជី ឬ សារការី ត្រូវចុះហត្ថលេខាលើរូបមន្តអនុវត្ត ដោយសរសេរថ្ងៃ ខែ ឆ្នាំនៃការផ្តល់នោះ។

### ២. ពាក្យសុំតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត

ពាក្យតវ៉ាអំពីការផ្តល់រូបមន្តអនុវត្ត គឺជាការសង្គ្រោះមួយសម្រាប់ម្ចាស់បំណុល ឬកូនបំណុលនៃការអនុវត្ត ក្នុងនីតិវិធីផ្តល់រូបមន្តអនុវត្ត ដែលអាចតវ៉ាទៅនឹងការបដិសេធនេះ។ ប្រសិនបើមានការដាក់ពាក្យតវ៉ាបែបនេះ តុលាការត្រូវធ្វើការសម្រេចលើពាក្យតវ៉ានេះ ដោយការចេញដីកាសម្រេច[56]។

- របៀបនៃការតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

ក្នុងករណីដែលក្រឡាបញ្ជីបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនោះអាចដាក់ពាក្យបណ្តឹងតវ៉ាទៅតុលាការដែលក្រឡាបញ្ជីនោះស្ថិតនោះ ដើម្បីធ្វើឧបាស្រ័យទៅនឹងការចាត់ចែងនេះ[57]។ ចំពោះសារការីដែលបដិសេធមិនផ្តល់រូបមន្តអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តអាចដាក់ពាក្យសុំតវ៉ាទៅសាលាដំបូងដែលមានសមត្ថកិច្ចលើការិយាល័យរបស់សារការីនោះបាន។

- ការសម្រេចអំពីការតវ៉ាចំពោះការផ្តល់រូបមន្តអនុវត្ត

ប្រសិនបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ានោះមិនមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចលើកចោលនូវពាក្យសុំតវ៉ានោះ។ ម្ចាស់បំណុលនៃការអនុវត្តមិនអាចដាក់ពាក្យបណ្តឹងជំទាស់ចំពោះដីកាសម្រេចនេះបានឡើយ។ ប៉ុន្តែបើតុលាការយល់ឃើញថា ពាក្យសុំតវ៉ាមានមូលហេតុត្រឹមត្រូវ តុលាការត្រូវចេញដីកាសម្រេចបង្គាប់ឱ្យស្ថាប័នផ្តល់រូបមន្តអនុវត្ត ផ្តល់នូវរូបមន្តអនុវត្តនោះ។

---

[54] មាត្រា ៣៥៨ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[55] មាត្រា ៣៥៧ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[56] មាត្រា ៣៦២ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[57] មាត្រា ៣៦២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

## ផ្នែកទី៣. សោហ៊ុយ

### កថាភាគទី១. អត្ថន័យសោហ៊ុយសម្រាប់ការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី

សោហ៊ុយសម្រាប់ការអនុវត្ត មានន័យថាជាការចំណាយរបស់ស្ថាប័នអនុវត្ត និងភាគីដែលជាសេចក្តីត្រូវការ ដើម្បីធ្វើការអនុវត្តដោយបង្ខំ ។ សោហ៊ុយនេះ ជាការចំណាយរបស់ភាគីជាមុន នឹងតុលាការអនុវត្តចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំ។ សោហ៊ុយសម្រាប់ការអនុវត្តរួមមាន៖ ពន្ធដាក់ពាក្យសុំ សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ និងសោហ៊ុយភាគី[58]។ ចំណែកសោហ៊ុយសម្រាប់នៅនីតិវិធី ជាសោហ៊ុយសម្រាប់ផលប្រយោជន៍រួមក្នុងចំណោមសោហ៊ុយសម្រាប់ការអនុវត្ត។ ការចំណាយទាំងនេះរួមមាន ការចំណាយលើនីតិវិធីបណ្តឹងដែលនាំទៅដល់ការចេញសាលក្រម ឬ សាលដីកាដែលជា លិខិតអនុវត្ត ចំពោះខ្លឹមសារ អ្នកទទួលបន្ទុក វិធីប្រមូល ជាដើម។ នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត អ្នកដែលដាក់ពាក្យសុំត្រូវបង់ជាមុននូវចំនួនទឹកប្រាក់ដែលតុលាការអនុវត្តកំណត់ថាជាសោហ៊ុយចាំបាច់ដើម្បីធ្វើនីតិវិធីនៃការអនុវត្តដោយបង្ខំ បើមិនបង់ពន្ធពាក្យសុំនោះទេ តុលាការមានមូលហេតុក្នុងការលើកចោល ឬលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំនោះ[59]។ ចំពោះអាជ្ញាសាលាវិញ អាចធ្វើការអនុវត្តដូចតុលាការអនុវត្តដែរ ក្នុងករណីអ្នកដាក់ពាក្យសុំមិនបង់សោហ៊ុយចាំបាច់ជាមុន[60]។

#### ១. ការបង់ពន្ធដាក់ពាក្យសុំ

ពន្ធដាក់ពាក្យសុំ សំដៅដល់ពន្ធដែលម្ចាស់បំណុលត្រូវបង់នៅពេលដែលដាក់ពាក្យសុំឱ្យអនុវត្ត។ ក្នុងករណីដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅតុលាការអនុវត្ត ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ១០.០០០ (មួយម៉ឺន) រៀល ទៅតុលាការ [61]។ ចំណែកការដែលដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំទៅអាជ្ញាសាលា ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់ពន្ធចំនួន ៥.០០០ (ប្រាំពាន់) រៀល[62]។

#### ២. សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ

ចំពោះសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ សំដៅដល់សោហ៊ុយចំណាយសម្រាប់ដំណើរការ ឬការធ្វើសកម្មភាពក្នុងនីតិវិធីទៅស្ថាប័នអនុវត្ត។ ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់នូវចំនួនទឹកប្រាក់ដែលកំណត់ដោយតុលាការ ជាសោហ៊ុយចាំបាច់ក្នុងការបញ្ជូនឯកសារ ឬ ធ្វើសកម្មភាពផ្សេងទៀត ដើម្បីនីតិវិធីក្នុងការអនុវត្តដោយបង្ខំ [63]។

ចំពោះអាជ្ញាសាលាសោហ៊ុយទាំងនោះមានដូចជា៖

---

[58] មាត្រា ៣៧១ ចំណុច ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[59] មាត្រា ៣៧៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[60] ប្រការ ១៥ ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឆ្នាំ២០០៧

[61] មាត្រា ៣៧២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[62] ប្រការ ១៣ ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឆ្នាំ២០០៧

[63] មាត្រា ៣៧៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- សោហ៊ុយសំរាប់ធ្វើដំណើរ និងស្នាក់នៅសម្រាប់មន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា
- សោហ៊ុយសម្រាប់ផ្ញើឯកសារ ទូរស័ព្ទ និងទូរសារ ជាអាទិ៍
- សោហ៊ុយសម្រាប់ជូនដំណឹងជាសាធារណៈ
- សោហ៊ុយធ្វើដំណើរប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងសោហ៊ុយសម្រាប់ស្នាក់នៅ សម្រាប់អ្នកអង្កេតការណ៍ដែលបានកំណត់នៅក្នុងមាត្រា ៣៣៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- កម្រៃសម្រាប់អ្នកបច្ចេទេស ឬកម្មករ
- សោហ៊ុយសម្រាប់ការដឹកជញ្ជូន ថែរក្សា និងគ្រប់គ្រងវត្ថុ
- សោហ៊ុយសម្រាប់ការប្រមូលផល
- សោហ៊ុយសម្រាប់ការទទួលលិខិតបញ្ជាក់ពីស្ថាប័នសាធារណៈ
- សោហ៊ុយសម្រាប់ថត និងផ្តិតរូបថត ដើម្បីថតស្ថានភាពបច្ចុប្បន្ននៃវត្ថុ
- សោហ៊ុយសម្រាប់ធ្វើលិខិតបញ្ជាក់ ដែលកំណត់នៅក្នុងកថាខណ្ឌទី៩នៃមាត្រា៤១៣
- សោហ៊ុយធ្វើដំណើរ ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ សោហ៊ុយសម្រាប់ស្នាក់នៅ កម្រៃសម្រាប់អ្នកវាយតម្លៃ
- សោហ៊ុយធ្វើលិខិតរាយការណ៍ដែលត្រូវដាក់ជូនទៅតុលាការអនុវត្ត
- សោហ៊ុយចាំបាច់សម្រាប់ការលក់តាមនីតិវិធីផ្សេងពីវិធីលក់ឡាយឡុងដោយស្រោមសំបុត្រ ឬដោយផ្ទាល់មាត់[64]។

**៣. សោហ៊ុយភាគី**

ចំណែកសោហ៊ុយភាគី គឺជាសោហ៊ុយលើការចំណាយរបស់ភាគីក្នុងដំណើការនៃនីតិវិធីការអនុវត្តដោយបង្ខំ។ ក្រៅពីសោហ៊ុយ ដែលជាការចំណាយនៃ ពន្ធដាក់ពាក្យសុំ និងសោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំចំពោះសោហ៊ុយដែលតុលាការដែលតុលាការទទួលស្គាល់ថាចាំបាច់ដើម្បីធ្វើការអនុវត្តដោយបង្ខំ ត្រូវបានចាត់ទុកថាជាសោហ៊ុយភាគី[65]។

ម្ចាស់បំណុលនៃការអនុវត្ត ឬ កូនបំណុលនៃការអនុវត្តត្រូវចេញឱ្យអ្នកផ្សេងក្រៅពីតុលាការអនុវត្ត និងអាជ្ញាសាលាដើម្បីធ្វើការអនុវត្តដោយបង្ខំ។ តាមអនុវត្តជាក់ស្តែងប្រភេទសោហ៊ុយប្រភេទនេះម្ចាស់បំណុលនៃការអនុវត្តធ្វើការរ៉ាប់រងទទួលខុសត្រូវដោយខ្លួនឯង ឬក៏បង់សរុបទៅខាងស្ថាប័នអនុវត្តតែម្តង រួចខាងស្ថាប័នអនុវត្តជាអ្នកចេញរ៉ាប់រងលើថ្លៃដំណើរការនីតិវិធីទាំងអស់។

[64] ប្រការ ១៤ ប្រកាសស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ឆ្នាំ២០០៧

[65] មាត្រា ៣៧៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# ជំពូកទី៣

# នីតិវិធីនៃការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុល

# ជំពូកទី៣
# នីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល

នៅក្នុងតថភាពសង្គមបច្ចុប្បន្ន វិវាទរដ្ឋប្បវេណីច្រើនតែកើតឡើងដោយសារតែការមិនបំពេញកាតព្វកិច្ច ដូច្នេះបន្ទាប់ពីការដោះស្រាយរវាងភាគី និងភាគីនៅតែមិនមានដំណោះស្រាយ ពេលនោះហើយដែលភាគីត្រូវការ ការអន្តរាគមន៍ពីរដ្ឋ។ មុននឹងឈានដល់ការអនុវត្តតាមផ្លូវតុលាការ ម្ចាស់បំណុលតែងតែចង់ឱ្យកូនបំណុល បំពេញកាតព្វកិច្ចដោយស្ម័គ្រចិត្ត។ គោលការណ៍ស្វ័យភាពបុគ្គលឯកជន ទំនាក់ទំនងឯកជន ភាគីមានសេរីភាព ក្នុងការសម្រេចលើមធ្យោបាយដោះស្រាយវិវាទ ដរាបណាមិនមានលក្ខណៈផ្ទុយច្បាប់។ យ៉ាងណាមិញ ចំពោះ ម្ចាស់បំណុលខ្លះទទួលបានជោគជ័យលើការចរចាជាមួយកូនបំណុល ឱ្យធ្វើការអនុវត្តកាតព្វកិច្ចដោយស្ម័គ្រចិត្ត តែម្ចាស់បំណុលខ្លះទៀតពុំទទួលបានជោគជ័យលើការចរចាឡើយ ទើបឈានដល់ការអនុវត្តដោយបង្ខំ។ ជៀស វាងការលើកលែងដល់កូនបំណុលដែលមានបំណងមិនល្អ បើទោះបីជាប្រាក់ ឬ ចលនវត្ថុរបស់កូនបំណុលនោះ ត្រូវបានកាន់កាប់ដោយតតិយជនក៏ដោយ ក៏ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនេះអាចអនុវត្តទៅលើត តិយជននោះផងដែរ។

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជានីតិវិធីនៃការអនុវត្តទៅលើសិទ្ធិលើបំណុលរបស់ កូនបំណុលនៃការអនុវត្ត ដើម្បីសម្រេចសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់របស់ម្ចាស់បំណុល តាមរយៈការរឹបអូសសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ ឬជាការប្រគល់ចលនវត្ថុដែលជារបស់ កូនបំណុល ហើយប្តូរជាប្រាក់នូវតម្លៃសេដ្ឋកិច្ចនៃសិទ្ធិលើបំណុលនោះ[66]។ នៅក្នុងជំពូកទី៣ នេះ យើងនឹងធ្វើ ការសិក្សាទៅលើលំហូរនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល**ទាំងពីរប្រភេទ** ដែលធ្វើការបែង ចែកជា ៦ ផ្នែក៖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងសងជាប្រាក់ (**ផ្នែកទី១**) ការរឹប អូសសិទ្ធិលើបំណុល (**ផ្នែកទី២**) ការប្តូរជាប្រាក់ (**ផ្នែកទី៣**) ការផ្ញើប្រាក់ទុក ដោយកូនបំណុលទី៣ (**ផ្នែកទី៤**) ការចែកចំណែក (**ផ្នែកទី៥**) ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងឱ្យប្រគល់ចលនវត្ថុ (**ផ្នែកទី៦**) ។

## ផ្នែកទី១. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានគោលបំណងសងជាប្រាក់

### កថាភាគទី១. ការដាក់ពាក្យសុំ

ជាគោលការណ៍ ការអនុវត្តដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្តតាមរយៈពាក្យសុំរបស់ភាគី។ តាម រយៈ គោលការណ៍នេះ មានន័យថាការអនុវត្តដោយបង្ខំពុំមែនជានីតិវិធីដែលកើតឡើងដោយស្វ័យប្រវត្តនោះទេ

[66] មាត្រា ៤០២ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

គឺត្រូវមានពាក្យសុំរបស់ភាគី។ ដោយសារតែការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ម្ចាស់បំណុលជាអ្នកដាក់ពាក្យសុំដើម្បីឱ្យមាននីតិវិធីនៃការអនុវត្តដោយបង្ខំ ម្លោះហើយម្ចាស់បំណុលត្រូវដឹងបែបផែននៃការដាក់ពាក្យសុំដែលអាចប្រែប្រួលតាមគោលបំណងនៃការអនុវត្ត។ ដោយហេតុថានីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺអនុវត្តទៅលើសិទ្ធិលើបំណុលរបស់កូនបំណុលនៃការអនុវត្ត ដើម្បីយកមកសងម្ចាស់បំណុល។ ដូច្នេះកិច្ចដែលចាំបាច់ គឺត្រូវកំណត់អត្តសញ្ញាណឱ្យច្បាស់លាស់អំពីទ្រព្យរបស់កូនបំណុល ហើយកិច្ចការស្រាវជ្រាវទ្រព្យរបស់កូនបំណុលនេះ គឺជាកាតព្វកិច្ចរបស់ម្ចាស់បំណុលនៃការអនុវត្ត។ ក្រោយពីកំណត់បានពីអត្តសញ្ញាណដែលជាកាតព្វកិច្ចម្ចាស់បំណុលហើយ ម្ចាស់សិទ្ធិលើបំណុលនៃការអនុវត្ត ត្រូវយកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងឯកសារភ្ជាប់នៅក្នុងពាក្យសុំទៅដាក់ទៅតុលាការអនុវត្ត[67]។

❖ ដើម្បីអាចដាក់ពាក្យសុំ ម្ចាស់បំណុលនៃការអនុវត្តត្រូវរៀបចំឯកសារដូចខាងក្រោម៖

១. លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត (សាលក្រម/សាលដី,..)

២. ឯកសារបញ្ជាក់ពីការចូលជាស្ថាពរនៃលិខិតអនុវត្ត

៣. រូបមន្តអនុវត្ត (ប្រសិនបើលិខិតអនុវត្តត្រូវចូលជាស្ថាពរ [68]ឯកសារបញ្ជាក់ពីការចូលជាស្ថាពរនៃលិខិតអនុវត្ត[69])

៤. ត្រូវសរសេរពាក្យសុំ តាមមាត្រា ៣៤៩ និង មាត្រា ៤០៣។

ជាគោលការណ៍ ចំពោះពាក្យសុំឱ្យអនុវត្តដោយបង្ខំតាមមាត្រា ៣៤៩ ត្រូវមានបញ្ជាក់នូវចំណុចដូចជា៖[70]

- ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋាន របស់ម្ចាស់បំណុលនៃការអនុវត្ត និង កូនបំណុលនៃការអនុវត្ត ហើយនឹងឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។
- សញ្ញាណនៃលិខិតអនុវត្ត ដែលសំដៅដល់ប្រភេទនៃលិខិតអនុវត្ត អាចជាសេចក្ដីសម្រេចរបស់តុលាការផ្សេងៗ ដែលមានអានុភាពតាមផ្លូវការព្រមទាំងលិខិតដែលមានអានុភាពដូចសេចក្ដីសម្រេចរបស់តុលាការ ឬ លិខិតយថាភូតដែលធ្វើឡើងដោយសារការី ឬ សេចក្ដីសម្រេចរបស់មជ្ឈត្តករជាអាទិ៍[71]។
- សេចក្ដីសុំឱ្យអនុវត្ត តាមការបង្ខំដោយផ្ទាល់ ឬ ការអនុវត្តជំនួស ឬ វិធានបង្ខំដោយប្រយោល ។

[67] មាត្រា ៤០៣ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[68] មាត្រា ៣៥០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[69] មាត្រា ៣៥៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[70] មាត្រា ៣៤៩ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[71] មាត្រា ៣៥០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំ និងវិធីអនុវត្តដោយបង្ខំដែលម្ចាស់បំណុលនៃការអនុវត្តសុំក្នុងករណីដែលសុំឱ្យអនុវត្តតាមការបង្ខំដោយផ្ទាល់។ ក្នុងករណីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រង់នេះចាំបាច់ត្រូវចង្អុលបង្ហាញ និងបញ្ជាក់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូសផងដែរ។ យ៉ាងណាមិញ ចំពោះការអនុវត្តជាក់ស្តែង គឺមានភាពលំបាកក្នុងការបញ្ជាក់ឱ្យច្បាស់អំពីសិទ្ធិលើបំណុល។
- ខ្លឹមសារនៃសេចក្តីសម្រេចដែលម្ចាស់បំណុលសុំ ក្នុងករណីដែលសុំឱ្យអនុវត្តដោយបង្ខំ តាមការអនុវត្តក្នុងករណីដែលម្ចាស់បំណុលនៃការអនុវត្តសុំឱ្យអនុវត្តដោយបង្ខំចំពោះផ្នែកណាមួយនៃសិទ្ធិទាមទារ

ដែលបានសរសេរនៅក្នុងលិខិតអនុវត្តដែលបង្គាប់ឱ្យសងជាប្រាក់ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវសរសេរបញ្ជាក់អំពីសេចក្តីសុំ និង ទំហំនៃសេចក្តីសុំនោះ ក្នុងពាក្យសុំឱ្យអនុវត្តដោយបង្ខំ ។

ចំពោះពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដោយក្រៅពីបំណុលដែលបានកំណត់នៅក្នុងចំណុចនីមួយៗ ខាងលើ នោះម្ចាស់បំណុលក៏ត្រូវបញ្ជាក់អំពីកូនបំណុលទី៣ ផងដែរ[72]។

បន្ទាប់ពីបានរៀបចំពាក្យសុំ និងឯកសារភ្ជាប់គ្រប់គ្រាន់ដូចបានរៀបរាប់ខាងលើរួចហើយ ម្ចាស់បំណុលនៃការអនុវត្តត្រូវយកឯកសារទៅដាក់នៅលេខាធិការដ្ឋានរដ្ឋបាលនៃសាលាដំបូងដែលមានសមត្ថកិច្ច ហើយចំពោះពន្ធដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំ គឺត្រូវបង់ចំនួន ១០,០០០ (មួយម៉ឺន)រៀល[73]។ ពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ត្រូវដាក់ទៅតុលាការអនុវត្តដែលមានសមត្ថកិច្ច (សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលនៃការអនុវត្ត)។ ហើយបើក្នុងករណីដែលគ្មានទីកន្លែងខាងលើនេះទេ សាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងរបស់កូនបំណុលទី៣ វិញ។ តុលាការអនុវត្តទទួលសំណុំរឿងអនុវត្តដោយបង្ខំស្របតាមលំដាប់លំដោយ ដែលបានកំណត់ទុកជាមុនដោយដីកាសម្រេចប្រចាំឆ្នាំរបស់ប្រធានតុលាការ[74]។

**កថាភាគទី២. ការពិនិត្យពាក្យសុំ**

បន្ទាប់ពីតុលាការទទួលបានពាក្យសុំហើយ តុលាការត្រូវពិនិត្យលើពាក្យសុំនោះ ចៅក្រមម្នាក់ៗត្រូវទទួលបន្ទុកជាស្វ័យប្រវត្ត[75]។

- ការពិនិត្យលើសមត្ថកិច្ចតុលាការ

[72] មាត្រា ៤០៣ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[73] មាត្រា ៣៧២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[74] មាត្រា ២៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[75] មាត្រា ២៦ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចំពោះការអនុវត្តដោយបង្ខំ គឺដូចគ្នានឹងសមត្ថកិច្ចរបស់តុលាការ ក្នុងនីតិវិធីបណ្តឹងអង្គសេចក្តីដែរ ក្នុងករណីដែលពាក្យសុំខុសសមត្ថកិច្ច ត្រូវលើកចោលពាក្យសុំអនុវត្តដោយបង្ខំនោះ។

- ការពិនិត្យទម្រង់នៃពាក្យសុំ

ពាក្យសុំត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[76] ត្រូវពិនិត្យមើលពីចំណុចដែលត្រូវសរសេរក្នុងពាក្យសុំថាបានត្រឹមត្រូវ តាមមាត្រា ៣៤៩ និង ៤០៣ (ជាពិសេសចំណុចអត្តសញ្ញាណនៃទ្រព្យសម្បត្តិ និងកូនបំណុលទី៣)។ បើពិនិត្យឃើញថាមានកំហុសឆ្គង ឬខ្វះត្រង់ចំណុចណាមួយតម្រូវឱ្យ កែតម្រូវពាក្យសុំ។ តុលាការត្រូវផ្ទៀងផ្ទាត់ចំពោះភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារភ្ជាប់។ ការពិនិត្យបន្ថែមលើនីតិវិធីការបញ្ជូនទៅកូនបំណុលចំពោះលិខិតផ្សេងៗ ការបង់ពន្ធ និងសោហ៊ុយជាអាទិ៍។

- ការសម្រេចលើពាក្យសុំ

តុលាការអនុវត្តត្រូវសម្រេចសេចក្តីអំពីពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ដោយចេញដីកាសម្រេច[77]។ បើយល់ឃើញថាពាក្យសុំមានទម្រង់ត្រឹមត្រូវ ហើយល័ក្ខខ័ណ្ឌដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំត្រូវ បានបំពេញ។ ផ្ទុយទៅវិញ ប្រសិនបើយល់ឃើញថា ពាក្យសុំពុំមានទម្រង់ត្រឹមត្រូវ ឬ បើល័ក្ខខ័ណ្ឌដើម្បីចាប់ផ្តើមការអនុវត្តដោយបង្ខំ មិនត្រូវបានបំពេញទេ តុលាការត្រូវចេញដីកាសម្រេចលើកចោលពាក្យសុំ ឬកែតម្រូវលើពាក្យសុំនោះ។ អ្នកដាក់ពាក្យសុំអាចប្តឹងជំទាស់ចំពោះដីកាសម្រេចលើកចោលពាក្យសុំបាន។

## ផ្នែកទី២. ការរឹបអូសសិទ្ធិលើបំណុល

### កថាភាគទី១. នីតិវិធីនៃការរឹបអូស

ជាគោលការណ៍ ការរឹបអូសអាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យ ទាំងអស់ដែលធ្លាក់ទៅលើកូនបំណុលនៃការអនុវត្ត លើកលែងតែមានការកំណត់ពិសេសក្នុងច្បាប់[78]។ បន្ទាប់ពីការពិនិត្យពាក្យសុំអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល មានភាពត្រឹមត្រូវ ព្រមទាំងពិនិត្យមើលលើកម្មវត្ថុនៃសិទ្ធិទាមទារផងដែរ ព្រោះកម្មវត្ថុខ្លះត្រូវបានរឹតត្បិតដោយច្បាប់ហាមឃាត់មិនឱ្យរឹបអូស។ សិទ្ធិលើបំណុលដែលត្រូវបានហាមឃាត់មិនឱ្យរឹបអូសមានដូចជា ប្រាក់បៀវត្ស ប្រាក់ឈ្នួល និង សិទ្ធិលើបំណុលដែលមានលក្ខណៈដូចជា ប្រាក់បៀវត្សផ្សេងទៀតរបស់កូនបំណុលនៃការអនុវត្ត បន្ទាប់ពីកាត់ចេញនូវអាករ និងប្រាក់ធានារ៉ាប់រងសង្គមកិច្ច ដែលមានកំណត់ចំនួនបន្ថែមក្នុងមាត្រា ៣៨២។ ចំពោះសិទ្ធិលើបំណុលចំពោះប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ ឧបត្ថម្ភផ្នែកសិក្សាប្រាក់ឧបត្ថម្ភសុខភាព និងសិទ្ធិលើបំណុលផ្សេង ទៀតដែលមានគោលបំណងការពារជីវភាពរបស់កូនបំណុលនៃការអនុវត្ត ពុំអាចរឹបអូសបានឡើយ។

[76] មាត្រា ៣៤៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[77] មាត្រា ៣៣៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[78] មាត្រា ៣៧៩ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ទោះបីជាមានមាត្រា ៣៨២ (សិទ្ធិលើបំណុលដែលហាម ឃាត់មិនឱ្យរឹបអូស) ក៏ដោយ តុលាការអនុវត្ត អាចលុបចោលដីកា សម្រេចទាំងអស់ ឬ មួយផ្នែក ឬ អាចចេញដីកាសម្រេចរឹបអូសសិទ្ធិ លើបំណុលទាំងអស់ ឬមួយផ្នែក ដែលហាមឃាត់នោះ ដោយពិចារណាលើជីវភាព និងស្ថានភាពផ្សេងទៀតរបស់កូនបំណុល ឬ ម្ចាស់បំណុល តាមពាក្យសុំ។ បើមានស្ថានភាពផ្លាស់ប្តូរ តុលាការអាចផ្លាស់ប្តូរសេចក្តី សម្រេចរបស់ខ្លួនបាន តាមពាក្យសុំ។ បើមានពាក្យសុំដូចខាងលើ តុលាការអនុវត្តអាចបង្គាប់ ហាមឃាត់កូនបំណុលទី៣ មិនឱ្យបង់ ឬផ្តល់តាវកាលិកផ្សេងទៀត ដោយឱ្យដាក់ប្រាក់ភោគ ឬមិនឱ្យដាក់ប្រាតិភោគបាន រហូតដល់ដីកាសម្រេចនោះមានអានុភាព[79]។

ការអនុវត្តចំពោះសិទ្ធិលើបំណុល ត្រូវចាប់ផ្តើមដោយដីកាសម្រេចរឹបអូសរបស់តុលាការអនុវត្ត។ ក្នុងន័យនេះមានន័យថា គឺលុះត្រាតែមានដីកាសម្រេចរឹបអូសលើសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការរឹបអូសទើបអាចចាត់ទុកថា ជាការចាប់ផ្តើមនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដោយតុលាការអនុវត្ត។ ហើយតុលាការអនុវត្តអាចចេញដីកាសម្រេចរឹបអូសនូវសិទ្ធិលើបំណុលទាំងអស់ ឬសិទ្ធិលើបំណុលមួយផ្នែកដែលត្រូវរឹបអូសនោះ[80]។ យ៉ាងណាមិញ កម្មវត្ថុចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនេះអាចខុសគ្នាជាមួយនឹងនីតិវិធីមួយចំនួន តួយ៉ាងដីកាសម្រេចរឹបអូសនេះ ត្រូវធ្វើឡើងដោយមិនត្រូវសួរកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣ ទេ[81] ព្រោះថា កាលបើសួរកូនបំណុល ឬ កូនបំណុលទី៣ មុននឹងចេញដីកាសម្រេចរឹបអូស ហើយអាចនឹងមានការបញ្ចៀសការអនុវត្តដោយបង្ខំ ដោយប្រមូលសិទ្ធិលើបំណុល ដែលរឹបអូស ឬ ធ្វើការចាត់ចែងសិទ្ធិលើបំណុលនៅ ដូចជាការធ្វើអនុប្បទានជាដើម។ ក៏ប៉ុន្តែ ដីកាសម្រេចរឹបអូស ត្រូវតែបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត និងកូនបំណុលទី៣[82]។

ក្នុងដីកាសម្រេចរឹបអូសត្រូវមានខ្លឹមសារៈ ហាមឃាត់មិនឱ្យកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬការចាត់ចែងផ្សេងទៀត និងហាមមិនឱ្យកូនបំណុលទី៣ សងសំណងឱ្យកូនបំណុលនៃការអនុវត្តឡើយ។

ក្រឡាបញ្ជីត្រូវជូនដំណឹង អំពីការណ៍នោះ និងថ្ងៃខែ ឆ្នាំ នៃការបញ្ជូននោះទៅម្ចាស់បំណុលនៃការអនុវត្ត។ បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេង ទៀតដែលបានចុះបញ្ជី បានបង្កើតអានុភាពតាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី បញ្ជាក់ថាសិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ចំពោះសេចក្តីសម្រេចអំពីពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសអាចប្តឹងជំទាស់បាន។ មុននឹងឈានដល់នីតិវិធីនៃការអនុវត្តដោយបង្ខំ

[79] មាត្រា ៣៨៣ កថាខណ្ឌទី ៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[80] មាត្រា ៤០៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[81] មាត្រា ៤០៣ កថាខណ្ឌទី៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[82] មាត្រា ៤០៣ កថាខណ្ឌទី៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត គឺធ្វើការចុះបញ្ជីដែលពាក្យសុំ និង ឯកសារភ្ជាប់ មានភាពប្រែប្រួលពីល័ក្ខខ័ណ្ឌមួយទៅល័ក្ខខ័ណ្ឌមួយទៀត[83]។

ទោះក្នុងករណីដែលសិទ្ធិលើបំណុលមានតម្លៃលើសពីចំនួនទឹកប្រាក់នៃ សិទ្ធិទាមទារឱ្យសងជាប្រាក់ដែលបានកំណត់នៅក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តក៏ដោយ តុលាការអនុវត្តអាចរឹបអូសសិទ្ធិលើបំណុលនោះទាំងអស់បាន ដើម្បីសងបំណុលរបស់ម្ចាស់បំណុលបានគ្រប់ ប្រសិនបើមានម្ចាស់បំណុលដទៃទៀតទាមទារឱ្យចែកចំណែកដែរ[84]។ ប៉ុន្តែ បើតម្លៃនៃសិទ្ធិលើបំណុលដែលបានរឹបអូស មានតម្លៃលើសពីចំនួនសិទ្ធិលើបំណុលដែលមានក្នុងលិខិតអនុវត្ត និងសោហ៊ុយសម្រាប់អនុវត្តនោះ តុលាការអនុវត្តមិនត្រូវរឹបអូសសិទ្ធិលើបំណុលផ្សេងទៀតឡើយ [85] នេះជាគោលការណ៍ នៃការហាមឃាត់មិនឱ្យធ្វើការរឹបអូសហួសប្រមាណ ដែលមានហេតុផលដូចគ្នាទៅនឹងករណីអនុវត្តដោយបង្ខំចំពោះចលនវត្ថុដែរ។

នៅក្នុងដីកាសម្រេចរឹបអូស តុលាការអនុវត្ត ត្រូវបញ្ជាក់ឱ្យច្បាស់អំពីសិទ្ធិលើបំណុលដែលត្រូវរឹបអូស ត្រូវហាមមិនឱ្យកូនបំណុលនៃការអនុវត្ត ធ្វើការប្រមូលសិទ្ធិលើបំណុល ឬ ការចាត់ចែងផ្សេងទៀត និងត្រូវហាមមិនឱ្យកូនបំណុលទី៣ ធ្វើការសងបំណុលឱ្យទៅកូនបំណុលនៃការអនុវត្ត[86]។

### កថាភាគទី២. អានុភាពនៃការរឹបអូស

#### ១. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះម្ចាស់បំណុលនៃការអនុវត្ត

ចំពោះតាវកាលិកដែលទទួលបន្តបន្ទាប់ ដើម្បីភាពងាយស្រួលឱ្យដល់ម្ចាស់បំណុលនៃការអនុវត្ត ច្បាប់បានបញ្ញត្តិថានៅពេលទទួលដីកាសម្រេចរឹបអូសហើយម្ចាស់បំណុលនោះ មិនចាំបាច់ទទួលដីកាសម្រេចរឹបអូសផ្សេងទៀត សម្រាប់កាលបរិច្ឆេទនៃការផ្តល់តាវកាលិកនីមួយៗនោះទេ។ សិទ្ធិលើបំណុលដែលទាក់ទងនឹងតាវកាលិកដែលទទួលបន្តបន្ទាប់ សំដៅទៅលើករណីដែលសិទ្ធិលើបំណុលនោះនឹងកើតមានយ៉ាងពិតប្រាកដ ឬពេលកំណត់សងនីមួយៗ នឹងមកដល់យ៉ាងពិតប្រាកដ ដោយផ្អែកលើទំនាក់ទំនងគតិយុត្តជាក់លាក់ណាមួយ[87]។

ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យសុំទៅតុលាការអនុវត្ត ដើម្បីដាស់តឿនឱ្យកូនបំណុលទី៣ ធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស[88]។

[83] ប្រការ ១៣ ដល់ ប្រការ ១៥ ប្រកាសអន្តរក្រសួង ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០១១

[84] មាត្រា ៤០៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[85] មាត្រា ៤០៤ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[86] មាត្រា ៤០៣ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[87] មាត្រា ៤០៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[88] មាត្រា ៤០៥ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

របបនៃការដាស់តឿននេះម្ចាស់បំណុលនៃការអនុវត្តអាចទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយនៃទ្រព្យ ម្ចាស់បំណុលត្រូវទទួលបាននូវលិខិតបញ្ជាក់អំពីសិទ្ធិលើបំណុលពីកូនបំណុលនៃការអនុវត្ត (ប្រសិនបើមាន)[89]។ របបនេះត្រូវបានបង្កើតឡើង ដើម្បីទម្លាក់ករណីយកិច្ចធ្វើការសហការនៅក្នុងនីតិវិធី ទៅលើកូនបំណុលទី៣ ដែលដឹងព័ត៌មានជាងគេ អំពីអត្ថិភាព ឬនត្ថិភាពចំនួនទឹកប្រាក់ ជាអាទិ៍។

ម្ចាស់បំណុលនៃការអនុវត្ត អាចប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់បាន[90]។ ម្ចាស់បំណុលដែលបានរឹបអូសសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ អាចប្រមូលបំណុលនោះបាន បើ ១ (មួយ) សប្តាហ៍កន្លងហួស ក្រោយពីថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។ ប៉ុន្តែ ម្ចាស់បំណុលនៃការអនុវត្តនោះមិនអាចទទួលការសងលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និងសោហ៊ុយសម្រាប់ការអនុវត្តបានឡើយ។

ម្ចាស់បំណុលនៃការអនុវត្ត ត្រូវទទួលខុសត្រូវចំពោះកូនបំណុលនៃការអនុវត្ត ក្នុងការសងការខូចខាតដែលកើតឡើង ដោយសារការមិនអនុវត្តសិទ្ធិលើបំណុលដែលខ្លួនបានរឹបអូស[91]។ ប៉ុន្តែពេលដែលបានទទួលសំណងហើយ ម្ចាស់បំណុលនៃការអនុវត្ត ត្រូវជូនដំណឹងអំពីការណ៍នេះទៅតុលាការអនុវត្ត។ ម្ចាស់បំណុលនៃការអនុវត្ត អាចដាក់ពាក្យបណ្តឹងទាមទារឱ្យផ្តល់តាវកាលិកឱ្យកូនបំណុលទី៣ ផ្តល់តាវកាលិកដែលទាក់ទងនឹងសិទ្ធិលើបំណុលនោះបាន[92]។

### ២. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះកូនបំណុលនៃការអនុវត្ត

អានុភាពនៃដីកាសម្រេចរឹបអូសនេះ អាចហាមកូនបំណុលនៃការអនុវត្តធ្វើការប្រមូលសិទ្ធិលើបំណុល ឬការចាត់ចែងផ្សេងទៀត ដូចជាការធ្វើអនុប្បទាន ការលើលែងការទូទាត់ ជាអាទិ៍ ពីកូនបំណុលទី៣[93]។ ប៉ុន្តែនេះជាមោឃភាពមិនដាច់ខាត ព្រោះមានល័ក្ខខ័ណ្ឌមួយចំនួនដែលត្រូវបានរួចផុត។ ម្យ៉ាងទៀតការរឹបអូស មិនបានហាមឃាត់ដល់ទំនាក់ទំនងគតិយុត្តិដែលនាំឱ្យកើតមានសិទ្ធិលើបំណុលនៃការរឹបអូសនោះទេ។

កូនបំណុលការអនុវត្តត្រូវប្រគល់លិខិតបញ្ជាក់នោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត[94]។ ជាល័ក្ខខ័ណ្ឌ កូនបំណុលនៃការអនុវត្ត ត្រូវទទួលការបញ្ជូនអំពីដីកាសម្រេចរឹបអូស ហើយម្យ៉ាងទៀតកូនបំណុលនៃការអនុវត្ត អាចប្តឹងជំទាស់ចំពោះដីកាសម្រេចរឹបអូសបាន ។

---

89 មាត្រា ៤០៦ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

90 មាត្រា ៤១០ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

91 មាត្រា ៤១០ កថាខណ្ឌទី៤ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

92 មាត្រា ៤១២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

93 មាត្រា ៤០៣ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

94 មាត្រា ៤០១ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

**៣. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះកូនបំណុលទី៣នៃការអនុវត្ត**

ប្រសិនបើមានការបង្គាប់ពីតុលាការអនុវត្ត កូនបំណុលទី៣ ត្រូវធ្វើសេចក្តីថ្លែងការណ៍ទាក់ទងនឹងសិទ្ធិលើបំណុល ក្នុងអំឡុងពេល ២ សប្តាហ៍ ចាប់ពីថ្ងៃបញ្ជូនដីកាសម្រេចរឹបអូស ដូចខាងក្រោម ៖

- អត្ថិភាព ឬនត្ថិភាពនៃសិទ្ធិលើបំណុលដែលត្រូវរឹបអូស ហើយប្រភេទចំនួនទឹកប្រាក់ និងខ្លឹមសារនៃសិទ្ធិលើបំណុល បើមានសិទ្ធិនោះ។
- អត្ថិភាព ឬនត្ថិភាពនៃឆន្ទៈសង និងទំហំនៃការសង ឬ មូលហេតុដែលមិនសង។
- បើមានសញ្ញាណនៃជនដែលមានអាទិភាពជាម្ចាស់បំណុលនៃការអនុវត្តចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធនោះ និងប្រភេទនៃសិទ្ធិលើបំណុល និងទំហំនៃអាទិភាពនោះ។
- អត្ថិភាព ឬនត្ថិភាពនៃការរឹបអូស ឬ ការរឹបអូសជាបណ្តោះអាសន្នចំពោះសិទ្ធិលើបំណុលដែលពាក់ព័ន្ធ។

កូនបំណុលទី៣ ត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាតដែលកើតឡើងដោយសារ ការមិនធ្វើសេចក្តីថ្លែងការណ៍ ឬ ថ្លែងការណ៍ ខុសពីការពិត ឬមានចេតនាកុហក ហើយធ្វើសេចក្តីថ្លឬការណ៍ដែលខុសការពិត។ ពេលដែលម្ចាស់បំណុលនៃការអនុវត្តបានទទួលសំណងពីកូនបំណុលទី៣ ត្រូវចាត់ទុកថាបំណុលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ត្រូវបានសង ត្រឹមកម្រិតនៃចំនួន ទឹកប្រាក់សំណងដែលខ្លួនបានទទួល។ ក្នុងករណីដែលមានការរឹបអូសជាន់គ្នា កូនបំណុលទី៣ មិនអាចរួចផុតពីកាតព្វកិច្ចឡើយលុះត្រាតែផ្ញើទុកប្រាក់ដែលស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូស ឬ ប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ ទៅតុលាការអនុវត្ត[95]។

**៤. អានុភាពនៃដីកាសម្រេចរឹបអូសចំពោះម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក**

ម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក រួមមាន៖

- ម្ចាស់បំណុលដែលមានឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាពអនុវត្ត
- ម្ចាស់បំណុលដែលបានអនុវត្តរឹបអូសជាបណ្តោះអាសន្ន
- និងម្ចាស់បំណុលដែលមានឯកសារបញ្ជាក់ថាខ្លួនមានឯកសិទ្ធិ[96]

ម្ចាស់បំណុលដែលមានសិទ្ធិទទួលចំណែក អាចទាមទារឱ្យចែកចំណែកបាន។ ប្រសិនបើមានការទាមទារឱ្យចែកចំណែក ក្នុងនេះតុលាការអនុវត្តត្រូវបញ្ជូនឯកសារដែលបញ្ជាក់អំពីការទាមទារនេញទៅកូនបំណុលទី៣។ ដោយសារកូនបំណុលទី៣ មានករណីយកិច្ចផ្ញើប្រាក់ទុកនោះ ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែកអាចទទួលបានចំណែកពីប្រាក់ដែលបានផ្ញើទុកនោះ ប៉ុន្តែពួកគេមិនអាចធ្វើការប្រមូលសិទ្ធិលើបំណុលដែល

[95] មាត្រា ៥១១ កថាខណ្ឌទី២ ចំណុច ក ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[96] មាត្រា ៥០៩ និង ៥១៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បានរឹបអូសដោយខ្លួនឯងបានទេ។ ម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក អាចប្ដឹងជំទាស់ចំពោះដីកាសម្រេចលើកចោលការទាមទារឱ្យចែកចំណែកបាន។

ម្ចាស់បំណុលដែលបានទាមទារឱ្យចែកចំណែក មិនអាចទទួលចំណែកបានទេ ប្រសិនបើ៖

- ម្ចាស់បំណុលនៃការ អនុវត្ត បានដកពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល) ឬ
- ប្រសិនបើនីតិវិធីនៃការអនុវត្តដោយបង្ខំ ត្រូវបានលុបចោល។

## ផ្នែកទី៣. ការប្ដូរជាប្រាក់

### កថាភាគទី១. ការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

នីតិវិធីនៃការប្ដូរជាប្រាក់ នៅក្នុងនីតិវិធីអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងសងជាប្រាក់ រួមមាន (ក) ការប្រមូលបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ និង (ខ) ការលក់សិទ្ធិលើបំណុល។

វិធីទូទៅនៃការប្ដូរជាប្រាក់ នៅក្នុងការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ គឺការប្រមូលសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ដោយម្ចាស់បំណុលនៃការអនុវត្តដែលបានធ្វើការរឹបអូស។ ម្ចាស់បំណុលនៃការអនុវត្ត អាចប្រមូលបំណុលនោះបាន បើ ០១ សប្ដាហ៍ បានកន្លងផុត ក្រោយថ្ងៃដែលដីកាសម្រេចរឹបអូសត្រូវបានបញ្ជូនទៅឱ្យកូនបំណុលនៃការអនុវត្ត។ ម្ចាស់បំណុលនៃការអនុវត្ត មិនអាចទទួលការសងលើសតម្លៃនៃសិទ្ធិលើបំណុលរបស់ខ្លួន និងសោហ៊ុយសម្រាប់អនុវត្ត បានឡើយ[97]។នៅពេលដែលម្ចាស់បំណុលនៃការអនុវត្តបានទទួលការសងពីកូនបំណុកទី៣ ត្រូវចាត់ទុកថា បំណុលនោះ និង សោហ៊ុយសម្រាប់ការអនុវត្ត ត្រូវបានសងត្រឹមកម្រិតនៃចំនួនទឹកប្រាក់នៃសំណងដែលខ្លួនបានទទួល។ នៅពេលដែលបានទទួលការសងពីកូនបំណុលទី៣ ម្ចាស់បំណុលនៃការអនុវត្តត្រូវជូនដំណឹងអំពីការណ៍នេះទៅតុលាការអនុវត្ត។

ដើម្បីប្រមូលសិទ្ធិលើបំណុល ម្ចាស់បំណុលដែលបានធ្វើការរឹបអូស អាចធ្វើសកម្មភាពទាំងអស់ តាមផ្លូវតុលាការ ឬ ក្រៅផ្លូវតុលាការបាន។ មានន័យថា ប្រសិនបើកូនបំណុលទី ៣ មិនព្រមសងដោយ ស្ម័គ្រចិត្តទេនោះ ម្ចាស់បំណុលអាចដាក់ពាក្យបណ្ដឹងទាមទារប្រមូលបំណុលបាន ហើយបើសិទ្ធិលើបំណុលនោះ ត្រូវបានធានាដោយសិទ្ធិប្រាតិភោគ ម្ចាស់បំណុលក៏អាចអនុវត្តសិទ្ធិប្រាតិភោគនោះបានដែរ។

ក្នុងករណីដែលសិទ្ធិលើបំណុលធានាដោយប្រាតិភោគ ម្ចាស់បំណុលក៏អាចអនុវត្តសិទ្ធិលើប្រាតិភោគបានដែរ។ អាជ្ញាសាលាត្រូវបំពេញល័ក្ខខ័ណ្ឌតតាំងសម្រាប់អនុប្បទាននៃសិទ្ធិលើបំណុល និងផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីសិទ្ធិប្រាតិភោគដែលធានាសិទ្ធិលើបំណុលដែលត្រូវរឹបអូសជាបន្ដបន្ទាប់។ អានុភាពនៃសាលក្រមលើបណ្ដឹងទាមទារប្រមូលបំណុល មិនត្រឹមតែមានចំពោះភាគីប៉ុណ្ណោះទេ គឺមានចំពោះម្ចាស់បំណុលផ្សេងដែលបានរឹបអូសសិទ្ធិលើបំណុលនោះ ដែលបានទទួលការបង្គាប់ឱ្យចូលរួម តែមិនបានចូលរួមក្នុងបណ្ដឹងទាមទារប្រមូលបំណុលនោះ ផងដែរ។

[97] មាត្រា ៤១០ កថាខណ្ឌ ១ និង កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

### កថាភាគទី២. ការលក់សិទ្ធិលើបំណុលដែលត្រូវបានរឹបអូស

#### ១. ល័ក្ខខ័ណ្ឌនៃការអនុវត្តនីតិវិធីលក់សិទ្ធិលើបំណុល

ប្រសិនបើសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស មានល័ក្ខខ័ណ្ឌ ឬមានកំណត់ពេល ឬមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវកាលិកតប ឬមានហេតុផ្សេងទៀត តុលាការអាចចេញដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់សិទ្ធិលើបំណុលនោះ តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត[98]។ មុននឹងចេញដីកាសម្រេចបង្គាប់ឱ្យលក់នេះ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្តសិន។ អាជ្ញាសាលាត្រូវបំពេញល័ក្ខខ័ណ្ឌតតាំងសម្រាប់អនុប្បទាននៃសិទ្ធិលើបំណុល និងផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីសិទ្ធិប្រាតិភោគដែលបានធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស។

នៅក្នុងនីតិវីធីនេះ ម្ចាស់បំណុលនៃការអនុវត្តមិនអាចធ្វើការប្រមូលបំណុលដោយខ្លួនឯងបានទេ។ នីតិវិធីលក់សិទ្ធិលើបំណុល ត្រូវធ្វើឡើងតាមការចេញ ដីកាសម្រេចបង្គាប់ឱ្យលក់ របស់តុលាការអនុវត្ត ដោយឱ្យអាជ្ញាសាលាជាអ្នកអនុវត្តការលក់ ប្រសិនបើមានល័ក្ខខ័ណ្ឌណាមួយដែលពាក់ព័ន្ធសិទ្ធិលើបំណុលដូចខាងក្រោម៖

- សិទ្ធិលើបំណុលមានល័ក្ខខ័ណ្ឌ
- សិទ្ធិលើបំណុលមានកំណត់អំឡុងពេលដែលត្រូវសង
- សិទ្ធិលើបំណុលមានការលំបាកក្នុងការប្រមូលដោយសារភ្ជាប់នឹងតាវកាលិកតប
- ឬសិទ្ធិលើបំណុលមានភ្ជាប់ជាមួយនឹងហេតុការណ៍ផ្សេងទៀត

#### ២. ល័ក្ខខ័ណ្ឌនៃការចេញដីកាសម្រេចបង្គាប់ឱ្យលក់

ជាពាក្យសុំឱ្យចេញដីកាសម្រេចបង្គាប់ឱ្យលក់ របស់ម្ចាស់បំណុលនៃការអនុវត្ត។ អាជ្ញាសាលាមិនអាចលក់សិទ្ធិលើបំណុលបានឡើយ ប្រសិនបើប្រាក់ដែលបានមកពីលក់សិទ្ធិលើបំណុលនោះ បន្ទាប់ពីសងបំណុលដែលមានអាទិភាពជាងសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត ព្រមទាំងសោហ៊ុយសម្រាប់នីតិវិធី ហើយមិនសល់ទេនោះនៃការអនុវត្ត[99]។ តុលាការអនុវត្តត្រូវសួរកូនបំណុលនៃការអនុវត្ត[100]។ ករណីចាំបាច់ តុលាការអនុវត្តអាចជ្រើសតាំងអ្នកវាយតម្លៃ និងបង្គាប់ឱ្យវាយតម្លៃលើសិទ្ធិលើបំណុលនោះបាន។

#### ៣. ខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យលក់

ខ្លឹមសារនៃដីកាសម្រេចបង្គាប់ឱ្យលក់

- កំណត់ឱ្យអាជ្ញាសាលាជាអ្នកដឹកនាំនីតិវិធីលក់
- វិធីលក់ ៖ ត្រូវកំណត់ដោយឆន្ទានុសិទ្ធិ ឬ តាមពាក្យសុំ។
- តម្លៃលក់អប្បបរមា៖ ត្រូវកំណត់ដោយឆន្ទានុសិទ្ធិ ឬ តាមរបាយការណ៍វាយតម្លៃ។

[98] មាត្រា ៤១៣ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[99] មាត្រា ៤១៣ កថាខណ្ឌទី៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[100] មាត្រា ៤១៣ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

– កាលបរិច្ឆេទ និងទីកន្លែងនៃការលក់

ច្បាប់មិនបានកំណត់ថា តុលាការអនុវត្តត្រូវធ្វើការផ្សាយជាសាធារណៈ ដូចការលក់អចលនវត្ថុនោះទេ ប៉ុន្តែករណីនេះ តុលាការអនុវត្ត គួរផ្សាយជាសាធារណៈដូចគ្នានឹងការលក់អចលនវត្ថុដែរ។

**កថាភាគទី៣. ល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តដីកាសម្រេចបង្គាប់ឱ្យលក់**

**១. កាលបរិច្ឆេទនៃការលក់ដោយអាជ្ញាសាលា**

អាជ្ញាសាលាអាចចាប់ផ្តើមនីតិវិធីលក់បានលុះត្រាតែៈ

– ដីកាសម្រេចបង្គាប់ឱ្យលក់ ត្រូវចូលជាស្ថាពរ[101]

– អាជ្ញាសាលា ប៉ាន់ប្រមាណថាប្រាក់ដែលបានមកពីការលក់នោះ ក្រោយពីបានសងសិទ្ធិលើបំណុល ដែលអាទិភាពជាង សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនៃការអនុវត្ត និងសោហ៊ុយសម្រាប់នីតិវិធី គឺមាន ចំនួនសល់។ ហើយប្រសិនបើមិន មានចំនួនសេសសល់ទេ អាជ្ញាសាលា មិនអាចលក់បានទេ[102]។

កាលបរិច្ឆេទនៃការលក់សិទ្ធិលើបំណុលដោយអាជ្ញាសាលាៈ

នៅពេលដែលល័ក្ខខ័ណ្ឌនៃការចាប់ផ្តើមអនុវត្តដីកាសម្រេចបង្គាប់ឱ្យលក់បានត្រូវបំពេញ អាជ្ញាសាលា ត្រូវលក់ដោយវិធី ដូចដែលកំណត់នៅក្នុងដីកាសម្រេចបង្គាប់ឱ្យលក់[103]។ ច្បាប់ពុំបានបញ្ញត្តិអំពីវិធីលក់សិទ្ធិលើ បំណុល ឱ្យបានច្បាស់លាស់ដូចវិធីលក់ចលនវត្ថុ ឬ អចលនវត្ថុ ដែលត្រូវលក់ឡាយឡុងដោយផ្ទាល់មាត់ ឬ ស្រោមសំបុត្រនោះទេ។ ករណីនេះគឺច្បាប់បានអនុញ្ញាតឱ្យតុលាការអនុវត្តមានសមត្ថកិច្ច កំណត់អំពីវិធីលក់ សិទ្ធិលើបំណុល ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន នៅក្នុងដីកាសម្រេចបង្គាប់ឱ្យលក់។

អាជ្ញាសាលា ត្រូវចាប់ផ្តើមការលក់ទៅតាមវិធី និង កាលបរិច្ឆេទដែលបានកំណត់ក្នុងដីកាសម្រេចបង្គាប់ ឱ្យលក់។ មានន័យថា នៅក្នុងដីកាសម្រេចបង្គាប់ឱ្យលក់ ត្រូវតែមានកំណត់យ៉ាងជាក់លាក់អំពីវិធីលក់ និង កាលបរិច្ឆេទនៃការលក់។ អាជ្ញាសាលាត្រូវធ្វើកំណត់ហេតុស្តីពីការអនុវត្តការលក់សិទ្ធិលើបំណុល ដោយកំណត់ អ្នកស្នើសុំទិញក្នុងតម្លៃលក់អតិបរមា និងប្រកាសអត្តសញ្ញាណនៃជននោះ។

**២. បុគ្គលដែលមិនអាចក្លាយជាអ្នកទិញ**

បុគ្គលដែលមិនអាចធ្វើសំណើទិញៈ

– កូនបំណុលនៃការអនុវត្ត មិនអាចធ្វើសំណើទិញបានឡើយ[104]

---

101 មាត្រា ៥១៣ កថាខណ្ឌទី៥ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

102 មាត្រា ៥១៣ កថាខណ្ឌទី៧ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

103 មាត្រា ៥១៣ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

104 មាត្រា ៥១៣ កថាខណ្ឌទី៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- បុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពដែលកំណត់ក្នុងក្រមរដ្ឋប្បវេណី ដូចជាអនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ ជននៅក្រោមហិតូបត្ថម្ភៈ[105] និង បុគ្គលដែលខ្វះសមត្ថភាពខាងឆន្ទៈ[106]
- បុគ្គលដែលមិនអាចក្លាយជាអ្នកទិញ ជាអាទិ៍[107]
- បុគ្គលដែលត្រូវបានអាជ្ញាសាលាមិនអនុញ្ញាតឱ្យធ្វើសំណើទិញ ដោយមូលហេតុបង្កឱ្យប៉ះពាល់ដល់ការលក់។

**៣. ការចាត់ចែងក្រោយការលក់សិទ្ធិលើបំណុល**

បន្ទាប់ពីអាជ្ញាសាលា លក់សិទ្ធិលើបំណុលនោះបានរួចរាល់ហើយនោះ អាជ្ញាសាលា ត្រូវធ្វើសកម្មភាព ដូចជា អាជ្ញាសាលា ត្រូវយកប្រាក់ដែលបានមកពីការលក់ ទៅឱ្យតុលាការអនុវត្តដែលបានចេញដីកាសម្រេចបង្គាប់ឱ្យលក់នោះ។ អាជ្ញាសាលាត្រូវជូនដំណឹងអំពីអនុប្បទានដោយលិខិតបញ្ជាក់ដែលមានកាលបរិច្ឆេទស្ថាពរចំពោះកូនបំណុលទី ៣ ជំនួសឱ្យកូនបំណុលនៃការអនុវត្ត។

ប្រសិនបើសិទ្ធិលើបំណុលដែលជាកម្មវត្ថុនៃការអនុវត្ត គឺជាសិទ្ធិលើបំណុលដែលត្រូវធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតនោះ នៅក្រោយបញ្ចប់ការលក់សិទ្ធិលើបំណុលនោះ តុលាការត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជី អំពីការផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត សម្រាប់អ្នកទិញដែលទទួលសិទ្ធិលើបំណុល ហើយឱ្យស្ថាប័នដែលមាន សមត្ថកិច្ចលុបចោលនូវការចុះបញ្ជីដែលធ្វើឡើងដោយផ្អែកលើដីកាសម្រេចរឹបអូស[108]។

## ផ្នែកទី៤. ការធ្វើប្រាក់ទុក ដោយកូនបំណុលទី៣

### កថាភាគទី១. ការធ្វើដោយមានសិទ្ធិ

ការធ្វើដោយមានសិទ្ធិ ទោះបីជានៅក្នុងករណីដែលម្ចាស់បំណុលដែលធ្វើការរឹបអូស មានតែម្នាក់ក៏ដោយក៏កូនបំណុលទី៣ អាចរួចផុតពីបំណុលរបស់ខ្លួន ដោយធ្វើទុកប្រាក់ស្មើនឹងចំនួនប្រាក់ដែលត្រូវបានរឹបអូសក្នុងចំណោមសិទ្ធិលើបំណុលនោះ ឬប្រាក់ស្មើនឹងចំនួនប្រាក់នៃសិទ្ធិលើបំណុលទាំងអស់ នៅតុលាការអនុវត្តបាន[109] ការធ្វើនេះ គឺជាការធ្វើប្រាក់ដែលចេញពីសិទ្ធិរបស់កូនបំណុល។ ហើយបន្ថែមលើសពីនេះទៅទៀត ការធ្វើប្រាក់នេះ ហៅថា ការធ្វើដោយមានសិទ្ធិ។

### កថាភាគទី២. ការធ្វើដោយមានករណីយកិច្ច

ចំពោះការធ្វើដោយមានករណីយកិច្ចប្រសិនបើមានម្ចាស់បំណុលច្រើន ចំពោះសិទ្ធិលើបំណុលតែមួយគឺកូនបំណុលទី៣ ត្រូវមានកាតព្វកិច្ចធ្វើប្រាក់។ បន្ថែមលើសពីនេះទៅទៀត កូនបំណុលទី៣ ត្រូវធ្វើទុកប្រាក់នៅ

[105] មាត្រា ១៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[106] មាត្រា ១៤ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[107] មាត្រា ៥២៥ និង មាត្រា ៥២៦ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧
[108] មាត្រា ៤០៣ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦
[109] មាត្រា ៤១១ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

តុលាការអនុវត្តស្មើនិងចំនួនប្រាក់ទាំងអស់នៃសិទ្ធិលើបំណុលនោះ ប្រសិនបានចេញដីកាសម្រេចរឹបអូស ឬដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ដោយលើសភាគសំណុលពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ហើយបានទទួលការបញ្ជូននូវដីកាសម្រេចនោះមុនពេលដែលកូនបំណុលទី៣ បានទទួលការបញ្ជូននូវពាក្យបណ្ដឹងទាមទារប្រមូលបំណុល ឬ ស្មើនឹងភាគនៃសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស ប្រសិនបើបានទទួលការបញ្ជូនឯកសារដែលបញ្ជាក់ថា មានការទាមទារឱ្យចែកចំណែក[110]។ ហើយនេះគឺជាការផ្ញើប្រាក់ដែលកើតចេញពីករណីយកិច្ចរបស់កូនបំណុល ហេតុដូច្នេះការផ្ញើនេះ ហៅថា ការផ្ញើដោយមានករណីយកិច្ច។ លើសពីនេះទៅទៀតទោះបីជាការផ្ញើដោយមានសិទ្ធិក៏ដោយ ឬការផ្ញើដោយមានករណីយកិច្ចក៏ដោយកូនបំណុលទី៣ ដែលបានផ្ញើប្រាក់ទុកនោះ ត្រូវជូនដំណឹងអំពីស្ថានភាពនោះទៅតុលាការអនុវត្ត[111]។

## ផ្នែកទី៥. ការចែកចំណែក

ការចែកចំណែក គឺជានីតិវិធីមួយដែលត្រូវបានធ្វើឡើងដើម្បីប្រគល់ប្រាក់ដែលទទួលបានពីការលក់ដោយបង្ខំទៅម្ចាស់បំណុល និងអ្នកដែលមានសិទ្ធិដទៃទៀតដែលបានទាមទារឱ្យធ្វើការចែកចំណែកនិងប្រគល់ប្រាក់ដែលនៅសល់ពីការចែកចំណែកឱ្យទៅកូនបំណុលនៃការអនុវត្ត។

### កថាភាគទី១. បុគ្គលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក

បុគ្គលដែលមានសិទ្ធិដែលទាមទារឱ្យចែកចំណែករួមមាន៖

- ម្ចាស់បំណុល ដែលបានទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្ដី[112]។ ជាធម្មតាមិនមែនគ្រប់ម្ចាស់បំណុល ដែលមានសិទ្ធិលើបំណុលលើកូនបំណុល សុទ្ធតែអាចរួមបញ្ចូលរឿងក្ដីជាមួយនឹងម្ចាស់បំណុលនៃការអនុវត្តដើម្បីទទួលបានចំណែកនោះទេ។ លើសពីនេះទៅទៀតម្ចាស់បំណុលដែលអាចសុំរួមបញ្ចូលរឿងក្ដីបាននោះគឺមានតែម្ចាស់បំណុលដែលមានលិខិតអនុវត្ត[113]ហើយបានដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល
- ម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ អាចទាមទារឱ្យអាជ្ញាសាលាធ្វើការ ចែកចំណែកឱ្យមកខ្លួនបាន។

### កថាភាគទី២. វិធីទាមទារឱ្យចែកចំណែក

ការទាមទារឱ្យចែកចំណែក មានភាពខុសប្លែកគ្នាអាស្រ័យទៅតាមប្រភេទនៃម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែក។ ដែលក្នុងនោះមាន ចំពោះម្ចាស់បំណុលដែលទាមទារឱ្យចែកចំណែកតាមរយៈការរួមបញ្ចូលរឿងក្ដី៖ ដើម្បីអាចក្លាយជាម្ចាស់បំណុល ដែលមានសិទ្ធិទទួលចំណែកបាន ម្ចាស់បំណុលប្រភេទនេះ

[110] មាត្រា ៤១១ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[111] មាត្រា ៤១១ កថាខណ្ឌទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[112] ៣៨៨ និង មាត្រា ៣៩៨ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

[113] មាត្រា ៣៥០ កថាខណ្ឌទី២ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

មិនអាចដាក់ពាក្យសុំទាមទារឱ្យចែកចំណែកបានទេ គឺមានវិធីដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ឬ ដាក់ពាក្យសុំឱ្យអនុវត្តរឹបអូសជាបណ្តោះអាសន្នដោយសំអាងលើលិខិតអនុវត្តរបស់ខ្លួន។

ការរួមបញ្ចូលរឿងក្តីក៏អាចត្រូវធ្វើឡើងតាមរយៈពាក្យសុំរបស់ម្ចាស់បំណុលនៅក្នុងសំណុំរឿងក្តីអនុវត្តថ្មី ក៏អានុភាពនៃការចែកចំណែកកកើតមានដែរ[114]។ ចំពោះម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំ ដើម្បីអាចក្លាយខ្លួនជាម្ចាស់បំណុលដែលមានឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំត្រូវដាក់ ពាក្យសុំទាមទារឱ្យចែកចំណែក។ ប៉ុន្តែម្ចាស់បំណុលត្រូវភ្ជាប់មកជាមួយឯកសារដែលមានបញ្ជាក់អំពីឯកសិទ្ធិ ឬ សិទ្ធិលើការបញ្ចាំនោះ។

**១. អំឡុងពេលអត្ថិភាពនៃការទាមទារឱ្យចែកចំណែក**

អំឡុងពេលសម្រាប់ទាមទារឱ្យចែកចំណែកគឺជាការកំណត់ត្រឹមពេលដែលបានទទួលការប្រគល់ប្រាក់ចំពោះប្រាក់ដែលបានមកពីការលក់ ឬ ពេលដែលបានរឹបអូសប្រាក់ចំពោះប្រាក់ដែលត្រូវបានរឹបអូសប៉ុណ្ណោះ។ ទោះបីជាខ្លួនជាម្ចាស់បំណុលដែលមានសិទ្ធិទាមទារឱ្យចែកចំណែកក៏ដោយ ប៉ុន្តែប្រសិនបើម្ចាស់បំណុលមិនបានសុំទាមទារឱ្យចែកចំណែកក្នុងអំឡុងពេលដែលច្បាប់បានកំណត់នោះ ក៏ម្ចាស់បំណុលនោះនៅតែមិនអាចក្លាយជាម្ចាស់បំណុល ដែលមានសិទ្ធិទទួលចំណែកបានដដែល។ បន្ថែមលើសពីនេះទៅទៀត នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីពុំបានចែងអំពីអំឡុងពេលនៃការទាមទារចែកចំណែកឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែយើងសាកពិនិត្យមើលមាត្រា ៣៩៨ យើងនឹងអាចសង្កេតបានថា អំឡុងពេលសម្រាប់ទាមទារឱ្យចែកចំណែក គឺកំណត់ត្រឹមពេលដែលបានទទួលការប្រគល់ប្រាក់បំពោះប្រាក់ ដែលបានមកពីការលក់ ឬ ពេលដែលបានរឹបអូសប្រាក់បំពោះប្រាក់ដែលត្រូវបានរឹបអូសតែប៉ុណ្ណោះ។ ក្នុងន័យនេះ ម្ចាស់បំណុលអាចទាមទារឱ្យចែកចំណែកបានគឺគិតចាប់ពីការចាប់ផ្តើមការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល រហូតដល់ពេលទទួលប្រាក់។

ប៉ុន្តែអាជ្ញាសាលា អាចចែកចំណែកឱ្យម្ចាស់បំណុល ដែលបានសុំឱ្យចែកចំណែកបានតែក្នុងករណីដែលមានឯកសារដូចខាងក្រោមត្រូវបានដាក់៖

- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែលកំណត់ថាលុបចោលលិខិតអនុវត្ត ក្រៅពីលិខិតយថាភូតដែលកំណត់ក្នុងចំណុច ច កថាខណ្ឌទី២ នៃមាត្រា ៣៥០ ឬឯកសារចម្លងយថាភូតនៃសេចក្តីសម្រេចដែល កំណត់ថា លុបចោលការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលបានកំណត់ថាមិនអនុញ្ញាតឱ្យអនុវត្តដោយបង្ខំ។
- អនុសារសាលក្រមស្ថាពរ ឬ អនុសារសាលដីកាស្ថាពរ ដែលប្រកាសថាការផ្សះផ្សារ ឬ ការទទួលស្គាល់ដែលទាក់ទងនឹងលិខិតអនុវត្តគ្មានអានុភាព។
- ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ឬ ឯកសារផ្សេងទៀត ដែលក្រឡាបញ្ជីបានធ្វើ ដែលបញ្ជាក់ថាលិខិតអនុវត្ត ដែលត្រូវបានកំណត់ពីចំណុច ខ រហូតដល់ចំណុច ង កថាខណ្ឌទី២ នៃមាត្រា ៣៥០ បាត់បង់អានុភាពដោយសារការដកពាក្យបណ្តឹង ឬ មូលហេតុផ្សេងទៀត។

[114] មាត្រា ៣៨៨ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

- ឯកសារចម្លងយថាភូត ដែលកំណត់អំពីការផ្សះផ្សា តាមនីតិវិធីនៃការសម្រេចសេចក្តី ដែលបានកំណត់ថាមិនអនុវត្តដោយបង្ខំ ឬ ដកពាក្យសុំឱ្យអនុវត្តដោយបង្ខំនោះវិញ។
- ឯកសារដែលបញ្ជាក់អំពីការដាក់ប្រាតិភោគ ដើម្បីឱ្យឱ្យរួចផុតពីការអនុវត្តដោយបង្ខំ។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់បង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំ និងការលុបចោលការចាត់ចែងការអនុវត្ត។
- ឯកសារចម្លងយថាភូតនៃសេចក្តីសម្រេច ដែលកំណត់ការបង្គាប់ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈ។
- ឯកសារដែលសរសេរថា ម្ចាស់បំណុលទទួលសំណង ឬ បានយល់ព្រមពន្យារពេលដែលត្រូវសងនៅក្រោយពេលលិខិតអនុវត្តត្រូវបានបង្កើត។

### ២. វិសាលភាពនៃម្ចាស់សិទ្ធិដែលត្រូវទទួលបានចំណែក

វិសាលភាពនៃម្ចាស់បំណុលដែលត្រូវទទួលចំណែករួមមាន៖

- ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូស
- ម្ចាស់បំណុលដែលបានអនុវត្តការរឹបអូសជាបណ្តោះអាសន្ន
- ម្ចាស់បំណុលដែកបានទាមទារឱ្យចំណែកមុនពេល។

តុលាការដែលត្រូវអនុវត្តការចែកចំណែកសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅចំពោះការអនុវត្តដោយបង្ខំចំពោះចលនវត្ថុឬតុលាការអនុវត្តចំពោះករណីផ្សេង។ តុលាការដែលត្រូវចែកចំណែកត្រូវកំណត់កាលបរិច្ឆេទនៃការចែកចំណែកនិងផ្តល់ដំណឹងអំពីពេលវេលានិងទីកន្លែងចែកចំណែកទៅម្ចាស់បំណុលដែលត្រូវទទួលការចែកចំណែកនិងកូនបំណុលនៃការអនុវត្ត។

លើសពីនេះនៅពេលដែលកាលបរិច្ឆេទត្រូវបានកំណត់ហើយ ក្រឡាបញ្ជីត្រូវដាស់តឿនម្ចាស់បំណុលម្នាក់ៗឱ្យផ្តល់លិខិតគណនាអំពីប្រាក់ដើមនៃសិទ្ធិលើបំណុលការប្រាក់រហូតដល់កាលបរិច្ឆេទនៃការចែកចំណែកនិងសោហ៊ុយសម្រាប់ការអនុវត្តទៅតុលាការដែលត្រូវចែកចំណែកក្នុងអំឡុងពេល១សប្តាហ៍។ ក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ហើយទឹកប្រាក់ដែលត្រូវចែកនោះមិនគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលនិងសោហ៊ុយសម្រាប់អនុវត្តទេ តុលាការដែលត្រូវចែកចំណែកត្រូវរៀបចំសេចក្តីព្រាងនៃតារាងចែកចំណែក។ ពេលម្ចាស់បំណុលណាម្នាក់ ឬ កូនបំណុលនៃការអនុវត្តដែលមិនពេញចិត្តចំពោះសេចក្តីព្រាងនៃតារាងនោះអាចថ្លែងតវ៉ានៅកាលបរិច្ឆេទនោះ។ បើម្ចាស់បំណុលមានច្រើននាក់ហើយទឹកប្រាក់ដែលត្រូវចែកនោះមិនគ្រប់គ្រាន់សម្រាប់សងសិទ្ធិលើបំណុលនិងសោហ៊ុយសម្រាប់អនុវត្តទេតុលាការដែលត្រូវចែកចំណែកត្រូវរៀបចំសេចក្តីព្រាងនៃតារាងចែកចំណែក។

## កថាភាគទី២. នីតិវិធីចែកចំណែក

នីតិវិធីនៃការចែកចំណែកមាន២គឺ៖ ការចែកចំណែកដោយការព្រមព្រៀង និង ការចែកចំណែកដោយតុលាការ។

**១. ការចែកចំណែកដោយការព្រមព្រៀង**

នៅក្នុងករណីដែលម្ចាស់បំណុលមានតែម្នាក់ ឬនៅក្នុងករណីដែលម្ចាស់បំណុលមានច្រើននាក់ ហើយប្រាក់ដែលបានពីការលក់ ឬ ប្រាក់ដែលបានរឹនអូសអាចសងចំពោះសិទ្ធិលើម្ចាស់បំណុលរបស់ម្ចាស់បំណុលនីមួយៗ និងសោហ៊ុយសម្រាប់ការអនុវត្តទាំងអស់បានតុលាការអនុវត្តត្រូវចែកចំណែកចំពោះម្ចាស់បំណុលមានតែម្នាក់ ឬ ទោះជាម្ចាស់បំណុលមានច្រើននាក់ក៏ដោយ បើទឹកប្រាក់ដែលបានមកពីការលក់អាចសងបំណុលគ្រប់នោះគឺនេះជាការសងគ្រប់គ្រាន់ហើយ ដែលត្រូវសងបំណុលទៅម្ចាស់បំណុលនីមួយៗនិងប្រគល់ប្រាក់ដែលនៅសេសសល់ទៅកូនបំណុលវិញ។

នៅក្នុងករណីផ្សេងទៀតប្រសិនបើម្ចាស់បំណុលទាំងអស់បានព្រមព្រៀងគ្នា លើការចែកចំណែកនូវប្រាក់ដែលបានមកពីការលក់នោះ តុលាការអនុវត្តត្រូវធ្វើការបែងចែកទៅតាមការព្រមព្រៀងនោះ។ ទោះបីជាម្ចាស់បំណុលមានច្រើន ហើយទឹកប្រាក់ដែលបានមកពីការលក់មិនអាចសងបំណុលគ្រប់ក៏ដោយប្រសិនបើម្ចាស់បំណុលទាំងអស់បានព្រមព្រៀងគ្នាលើការចែកចំណែកហើយនោះពុំមានភាពចាំបាច់អ្វីដែលត្រូវធ្វើការសម្រេចជាពិសេសទៀតនោះទេ ហេតុដូច្នេះបញ្ញត្តិនេះតម្រូវឱ្យតុលាការអនុវត្តធ្វើការបែងចែកតាម។

**២. ការចែកចំណែកដោយតុលាការ**

ប្រសិនបើនៅក្នុងករណីម្ចាស់បំណុលមិនអាចព្រមព្រៀងគ្នាលើការចែកចំណែកនូវប្រាក់ ដែលបានមកពីការលក់ទេនោះតុលាការអនុវត្តត្រូវធ្វើការបែងចែកចំណែកនោះ។ សាលាដំបូងត្រូវកំណត់កាលបរិច្ឆេទសម្រាប់ការចែកចំណែករួចធ្វើការចែកចំណែក។ ដីកាសម្រេចអំពីការកំណត់កាលបរិច្ឆេទនៃការបែងចែកចំណែកត្រូវចេញឱ្យបានឆាប់រហ័សបន្ទាប់ពីអ្នកទិញបានបង់ថ្លៃលក់។ ច្បាប់មិនបានកំណត់រយៈពេលប៉ុន្មានថ្ងៃ គិតចាប់ពីថ្ងៃចេញដីកាដើម្បីបែងចែកចំណែកនោះទេ ប៉ុន្តែមានការផ្តល់យោបល់ថាកាលបរិច្ឆេទសម្រាប់បែងចែកចំណែកគួរស្ថិតក្នុងអំឡុងពេល១ខែគិតចាប់ពីថ្ងៃចេញដីកា។

## ផ្នែកទី៦. ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានបំណងឱ្យប្រគល់ចលនវត្ថុ

### កថាភាគទី១. ការប្រគល់ចលនវត្ថុ

ការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់ចលនវត្ថុ ក៏ជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដូចជាការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានកម្មវត្ថុជាការសងប្រាក់ដែរ។ ដើម្បីចាត់ទុកថាជាកម្មវត្ថុដែលត្រូវប្រគល់នោះ ចាំបាច់ត្រូវតែជាចលនវត្ថុជាក់លាក់ ប៉ុន្តែមិនសំខាន់ថាតើនោះជាចលនវត្ថុមួយទាំងមូល ឬ ជាផ្នែកណាមួយនៃចលនវត្ថុដែលរួមគ្នានៅឡើយទេ។ លើសពីនេះទៅទៀតដោយសារតែនេះមិនមែនជាការអនុវត្តដោយបង្ខំដែលមានគោលបំណងឱ្យសងជាប្រាក់ ដូច្នេះទោះបីជាកម្មវត្ថុនោះគ្មានតម្លៃឬមានតម្លៃប៉ុន្មានក៏ដោយ ហើយទោះបីជាចលនវត្ថុនោះជាទ្រព្យសម្បត្តិដែលហាមឃាត់មិនឱ្យរឹបអូសក៏ដោយ ក៏អាចក្លាយជាកម្មវត្ថុនៃការអនុវត្តដោយបង្ខំឱ្យប្រគល់ចលនវត្ថុជាក់លាក់ដែរ។

ម្ចាស់បំណុលដែលរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ចនវត្ថុ ទាមទារឱ្យកូនបំណុលទី៣ ប្រគល់ចនវត្ថុនោះទៅអាជ្ញាសាលាដែលទទួលពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តបើអំឡុងពេលមួយសប្តាហ៍បានកន្លងហួស

ដោយគិតពីថ្ងៃដែលដីកាសម្រេចរឹបអូស ត្រូវបានបញ្ជូនទៅកូនបំណុលនៃការអនុវត្ត[115]។ ហើយក្នុងករណីកិច្ចប្រគល់សំដៅលើការប្រគល់ទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត ក៏ដូចជាការប្រគល់ទៅឱ្យ តតិយជន ឬការបង្ហាញដើម្បីធ្វើការត្រួតពិនិត្យ។ បន្ថែមលើសពីនេះទោះបីកូនបំណុលនៃការអនុវត្តមានករណីកិច្ចបន្ទាប់បន្សំផ្សេងទៀត ក៏ដូចជាករណីកិច្ចវេចខ្ចប់និងផ្ញើក៏ដោយ ក៏គេអាចធ្វើការអនុវត្តដោយបង្ខំនៅកន្លែងវត្ថុនោះស្ថិតនៅបាន។

**១. ការដាក់ពាក្យសុំ**

មុននិងដាក់ពាក្យសុំឱ្យអនុវត្តដោយបង្ខំជាគោលការណ៍ម្ចាស់បំណុលនៃការអនុវត្ត តែងតែចង់ឱ្យកូនបំណុលនៃការអនុវត្តធ្វើការអនុវត្តដោយស្ម័គ្រចិត្តតាមលិខិតអនុវត្តដោយការចរចា ជាជាងការអនុវត្តដោយបង្ខំ ទោះបីការជាការចរចានោះទទួលបានជោគជ័យ ឬជួនកាលមិនទទួលបានជោគជ័យដោយហេតុថា កូនបំណុលនៃការអនុវត្តពុំយល់ព្រមអនុវត្តដោយស្ម័គ្រចិត្ត តាមការចង់បានរបស់កូនបំណុលនៃការអនុវត្ត។ នៅក្នុងការអនុវត្តចំពោះការចរចានេះមិនមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីទេ ក៏ប៉ុន្តែចំពោះការអនុវត្តជាក់ស្តែងម្ចាស់បំណុលនៃការអនុវត្តតែងតែធ្វើការចរចាជាមួយកូនបំណុល ព្រោះដោយសារនេះជាគោលការណ៍ស្វ័យភាពនៃការបុគ្គលឯកជនហើយបើគ្មានការអនុវត្តដោយស្ម័គ្រចិត្តទេ ទើបបានឈានទៅដល់ការអនុវត្តដោយបង្ខំ។ នៅក្នុងករណីនេះ ម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើការជ្រើសរើសប្រភេទនៃការអនុវត្តដោយបង្ខំ ដែលងាយនិងសម្រេចនៅសិទ្ធិទាមទារនោះ។ ម្ចាស់បំណុលនៃការអនុវត្ត ជ្រើសរើសការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនោះ ម្ចាស់បំណុលនៃការអនុវត្តត្រូវធ្វើការស្រាវជ្រាវរកចលនវត្ថុរបស់កូនបំណុលដោយខ្លួនឯងគឺវាមិនមែនជាកាតព្វកិច្ចរបស់អាជ្ញាសាលាទេ។

ពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាស្អន ត្រូវធ្វើជាលាយល័ក្ខណ៍ណ៍អក្សរ។ នៅក្នុងពាក្យសុំនោះគេកំណត់ឱ្យអ្នកដាក់ពាក្យសុំត្រូវសរសេរនូវពាក្យសុំដែលក្នុងនោះត្រូវមានអត្តសញ្ញាណភាគីនៃការអនុវត្ត និងអ្នកតំណាងដែលច្បាប់បានកំណត់ដែលមានដូចជា៖ ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយព្រមទាំងឈ្មោះ និងអាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ផងដែរ។ ជាមួយគ្នានេះដែរអ្នកដាក់ពាក្យសុំត្រូវសរសេរចំណុចនេះឱ្យបានច្បាស់លាស់ និងអះអាងនូវភស្តុតាងតាមអង្គហេតុនីមួយៗដែលត្រូវបានបញ្ជាក់។

បន្ថែមលើសពីនេះទៅទៀត អ្នកដាក់ពាក្យសុំត្រូវបញ្ជាក់អំពីខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលអ្នកដាក់ពាក្យសុំខ្លួនឯងទាមទារដែលជាគោលការណ៍ កម្មវត្ថុនៃការរឹបអូសជាបណ្តោះអាសន្នត្រូវកំណត់ឱ្យបានជាក់លាក់ថាតើសុំឱ្យអនុវត្តទៅលើអ្វីមួយឱ្យប្រាកដ។ ប៉ុន្តែប្រសិនបើកម្មវត្ថុមួយនោះជាចលនវត្ថុ គឺមិនចាំបាច់កំណត់ជាក់លាក់អំពីចនវត្ថុនីមួយៗនោះទេ ដោយហេតុថាចលនវត្ថុអាចផ្លាស់ប្តូរទីតាំងបានគ្រប់ពេល ដូចនេះដើម្បីកុំឱ្យកូនបំណុលដឹងខ្លួនមុនថាម្ចាស់បំណុលរឹបអូសអ្វីខ្លះ គួរគប្បីកុំសរសេរបញ្ជាក់អត្តសញ្ញាណចលនវត្ថុនោះ តែគេត្រូវបញ្ជាក់អំពីទីតាំងនៃចលនវត្ថុនោះឱ្យបានច្បាស់លាស់ប្រាកដហើយពាក្យសុំត្រូវសរសេរ

[115] មាត្រា ៤១៤ កថាខណ្ឌទី១ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

បញ្ជាក់នូវសិទ្ធិ ឬក៏ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារភ្ជាប់ជាមួយផងដែរ ហើយត្រូវរៀបរាប់អំពីមូលហេតុនិងចំនួនទឹកប្រាក់នៃសិទ្ធិទាមទារ។

អ្នកដាក់ពាក្យសុំក៏ត្រូវរៀបរាប់អំពីភាពចាំបាច់នៃការរក្សាការពារ ដោយខ្លួនទាមទារផងដែរដោយហេតុថាអ្នកដាក់ពាក្យសុំពិតជាមានផលវិបាក ឬ បាត់បង់ផលប្រយោជន៍ណាមួយមិនខានប្រសិនបើ ស្ថាប័នអនុវត្តមិនព្រមចេញដីការក្សាការពារ ហើយចំណុចនេះក៏ត្រូវសរសេរឡើងឱ្យមានលក្ខណៈច្បាស់លាស់ផងដែរ។ បន្ថែមលើសពីនេះទៅទៀតចំពោះគោលបំណងនៃការកំណត់បែបនេះគឺដើម្បីធានានូវភាពច្បាស់លាស់ និងសុក្រឹតភាពនៃការអនុវត្តការរក្សាការពារ បើចំពោះសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តព្រមទាំងភាពចាំបាច់នៃការរក្សាការពារគឺរូវឱ្យអ្នកដាក់ពាក្យសុំត្រូវសរសេរសេចក្តីបញ្ជាក់ដំបូង។ មួយវិញទៀតចំពោះការដាក់ពាក្យសុំនេះគឺត្រូវប្រាកដថាអ្នកដាក់ពាក្យសុំបានបង់ពន្ធនៃការដាក់ពាក្យសុំ ដែលត្រូវបានកំណត់ចំនួន ៥.០០០ រៀល។

**២. ការពិនិត្យពាក្យសុំ**

នៅក្នុងការអនុវត្តដោយបង្ខំជាគោលការណ៍ត្រូវធ្វើឡើងដោយលិខិតអនុវត្ត ដែលជាលក្ខយណ្ឌគតិយុត្តតម្រូវចាំបាច់។ បានសេចក្តីថាស្ថាប័នអនុវត្តមិនអាចចាប់ផ្តើមការអនុវត្តដោយមិនមានលិខិតអនុវត្តដែលភ្ជាប់ជាមួយនូវពាក្យសុំឱ្យអនុវត្តដោយបង្ខំ ប៉ុន្តែក៏មានករណីលើកលែងតែការអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុដែលអាជ្ញាសាលាអាចធ្វើការចាប់ផ្តើមអនុវត្តសិទ្ធិប្រាតិភោគចំពោះចលនវត្ថុបានដោយ មិនចាំបាច់មានលិខិតអនុវត្តឡើយ ពោលគឺគ្រាន់តែម្ចាស់បំណុលនៃការអនុវត្តប្រគល់ចនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគឱ្យអាជ្ញាសាលា ឬដាក់លិខិតបញ្ជាក់ថាអ្នកកាន់កាប់ចលនវត្ថុនោះយល់ព្រមប្រគល់ឱ្យអាជ្ញាសាលាជាការស្រេច។

ការអនុវត្តដោយបង្ខំចំពោះចលនវត្ថុត្រូវធ្វើឡើងដោយលិខិតអនុវត្ត។ ចំពោះលិខិតអនុវត្តទាំងនោះមានដូចជា សាលក្រមឬសាលដីកាបង្គាប់អោយផ្តល់នូវតាវកាលិកដែលបានចូលជាស្ថាពរ សាលក្រម ឬសាលដីកាបង្គាប់ឱ្យផ្តល់តាវកាលិកដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចបង្គាប់ឱ្យផ្តល់តាវកាលិក យ៉ាងណាមិញចំពោះដីកាសម្រេចដែលមិនមានអានុភាពបើដីកាសម្រេចនោះមិនទាន់ចូលស្ថាពរមានកម្រិតតែដីកាសម្រេចនោះបានចូលស្ថាពរ។

ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តបណ្តោះអាសន្នហើយជាការ ចាត់ចែងរបស់ក្រឡាបញ្ជីដែលបានធ្វើ និងលិខិតយថាភូតដែលធ្វើឡើងដោយសារការី ចំពោះការទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់មានកំណត់។ ក៏ប៉ុន្តែមានកម្រិតតែលិខិតដែលបញ្ជាក់សេចក្តីថ្លែងការណ៍ថា កូនបំណុលនឹងទទួលអនុវត្តដោយបង្ខំភ្លាមៗ។

ការអនុវត្តដោយបង្ខំ ត្រូវធ្វើឡើងដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្ត។ ហើយរូបមន្តអនុវត្តជាប្រយោគដែលក្រឡាបញ្ជី ឬ សារការីសរសេរភ្ជាប់បន្ថែមនៅផ្នែកខាងក្រោមនៃឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត និង បញ្ជាក់ជាផ្លូវការនូវនត្ថិភាពឬអត្ថិភាពនៃអំណាចបង្ខំឱ្យអនុវត្តនៃលិខិតអនុវត្តនោះ។ ហេតុផលនៃការការតម្រូវឱ្យភ្ជាប់បន្ថែមនូវរូបមន្តអនុវត្តទៅនឹងលិខិតអនុវត្ត ដោយហេតុថាមានតែស្ថាប័នអនុវត្ត មិនមែនជាតុលាការនៃបណ្តឹងទេ ហេតុដូច្នេះហើយវាមិនមែនជាការសមស្របនោះ

ទេបើឱ្យស្ថាប័នអនុវត្តធ្វើការវិនិច្ឆ័យទៅលើអានុភាពនៃលិខិតអនុវត្តនៅពេលដែលមានពាក្យសុំអនុវត្តដោយបង្ខំម្តងៗដែលកិច្ចនេះនឹងនាំអោយមានការយឺតយ៉ាវនៅក្នុងកិច្ចនីតិវិធីនៃការអនុវត្តដោយបង្ខំ។

នៅក្នុងករណីនៃការអនុវត្តដោយបង្ខំត្រូវធ្វើឡើងចំពោះបុគ្គលផ្សេងពីអ្នកដែលបានបញ្ជាក់នៅក្នុងលិខិតអនុវត្តថាជាម្ចាស់បំណុល ឬ កូនបំណុលនៃការអនុវត្ត នោះជាការចាំបាច់ត្រូវធ្វើការស្រាវជ្រាវថាតើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលឥទ្ធិពលនៃអានុភាពនៃលិខិតអនុវត្តដែរឬទេ ហើយតើបុគ្គលនោះមានលក្ខណៈធ្វើជាភាគីនៃការអនុវត្តដោយបង្ខំឬទេ។ ក្នុងករណីប្រសិនបើបុគ្គលនោះជាបុគ្គលដែលត្រូវទទួលអានុភាពអនុវត្តនៃលិខិតអនុវត្ត នោះត្រូវសរសេរបន្ថែមនៅក្នុងលិខិតអនុវត្តដោយ រៀបរាប់នូវចំណុចនោះក្រោមទម្រង់ជារូបមន្តអនុវត្ត។

ចំពោះការអនុវត្តដោយបង្ខំដោយផ្អែកលើឯកសារចម្លងយថាភូតដែលមិនចាំបាច់តម្រូវឱ្យមានការភ្ជាប់ជាមួយនូវរូបមន្តអនុវត្តដែលមានជាអាទិ៍ សាលក្រមនៃបណ្តឹងរឿងក្តីដែលមានចំនួនប្រាក់តិចដែលចូលស្ថាពរ សាលក្រមនៃបណ្តឹងរឿងក្តីចំនួនប្រាក់តិចភ្ជាប់ជាមួយនឹងការប្រកាសឱ្យអនុវត្តជាបណ្តោះអាសន្ន ដីកាសម្រេចដាស់តឿនដែលភ្ជាប់ជាមួយនូវការប្រកាសឱ្យអនុវត្តបណ្តោះអាសន្ន។ ហើយបើសិនបើមានហេតុការណ៍នៃការអនុវត្តដោយបង្ខំត្រូវធ្វើឡើង ដោយផ្អែកលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានភ្ជាប់ជាមួយនឹងរូបមន្តអនុវត្តពិសេស ក្នុងនោះរួមមានសិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្ត មានភ្ជាប់ជាមួយនូវល័ក្ខខ័ណ្ឌបង្អង់ សិទ្ធិទាមទារដែលបានកំណត់នៅក្នុងលិខិតអនុវត្តមានភ្ជាប់ជាមួយនូវពេលកំណត់មិនពិតប្រាកដ និង ការយកបុគ្គលផ្សេងក្រៅពីភាគីបានកំណត់ក្នុងលិខិតអនុវត្តធ្វើជាម្ចាស់បំណុលឬកូនបំណុលនៃការអនុវត្តជាដើម។

ម្ចាស់បំណុលនៃការអនុវត្តត្រូវបង់សោហ៊ុយនៃការអនុវត្ត ដូចជាពន្ធដាក់ពាក្យសុំដែលស្មើនឹងចំនួន ៥.០០០ រៀល និង សោហ៊ុយក្រៅពីពន្ធដាក់ពាក្យសុំ ព្រមទាំងសោហ៊ុយភាគី ដែលត្រូវបង់ជាមុន។ ការអនុវត្តដោយបង្ខំផ្អែកលើលិខិតអនុវត្តរបស់ខ្លួនបានឡើយ បើអំឡុងពេល៥ឆ្នាំបានកន្លងផុតទៅបន្ទាប់ពីលិខិតអនុវត្តបានចូលស្ថាពរ។

### កថាភាគទី២. ការស្នើសុំកម្លាំង

ចំពោះការអនុវត្តដោយប្រគល់មានការលំបាកជាងការអនុវត្តផ្សេងៗទៀត ដោយសារការអនុវត្តនេះតម្រូវឱ្យអាជ្ញាសាលាត្រូវទៅធ្វើការរំលាយការកាន់កាប់របស់កូនបំណុលនៃការអនុវត្ត ហើយធ្វើឱ្យម្ចាស់បំណុលបានទទួលការកាន់កាប់វិញ។ ដើម្បីសម្រេចគោលបំណងនេះ អាជ្ញាសាលាដាច់ខាត់ត្រូវការជាចាំបាច់នូវកម្លាំងមានសមត្ថកិច្ចដើម្បីចូលរួមធ្វើការអនុវត្តនេះ។ ទោះបីជានៅក្នុងករណីដែលក្រមនីតិវិធីរដ្ឋប្បវេណីបានចែងផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាសាលាក្នុងការប្រើប្រាស់កម្លាំងប៉ូលីសក៏ដោយតែការអនុវត្តជាក់ស្តែង ដើម្បីឱ្យមានការចូលរួមអនុវត្តពីអាជ្ញាធរក៏ដូចជាកងកម្លាំងមានសមត្ថកិច្ចនោះ អាជ្ញាសាលាត្រូវដាក់លិខិតស្នើសុំកម្លាំងជាមុនទៅអាជ្ញាធរនៃទីកន្លែងដែលត្រូវចុះអនុវត្តនោះ ចំនួន១៥ថ្ងៃមុន បើមិនដូច្នោះទេខាងអាជ្ញាធរមិនមានការចូលរួមសហការជាមួយអាជ្ញាសាលាឡើយ។ លើសពីនេះបែបបទនៃលិខិតស្នើសុំកម្លាំងនេះគឺមានលក្ខណៈខុសគ្នាទៅតាមសាលាដំបូងរាជធានីខេត្តនីមួយៗ និង តាមខេត្តនីមួយៗផងដែរ។

**កថាភាគទី៣. នីតិវិធីនៃការប្រគល់ចលនវត្ថុ**

នីតិវិធីប្រគល់ចលនវត្ថុគឺជានីតិវិធីមួយថ្មីចំពោះស្ថាប័នអនុវត្ត ឬ អ្នកអនុវត្តមុនក្រមនីតិវិធីរដ្ឋប្បវេណី គេអនុវត្តតាម អនុលោមការអនុវត្តតាមសាលក្រមព្រហ្មទណ្ឌលុះដល់បច្ចុប្បន្ននេះនីតិវិធីនៃការអនុវត្តដោយបង្ខំត្រូវបានបញ្ញត្តិ នៅគន្ថីទី៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។ ចំពោះវត្ថុកាន់កាប់ដោយកូនបំណុលនៅក្នុងករណីដែលកូនបំណុលនៃការអនុវត្តជាអ្នកកាន់កាប់ចលនវត្ថុដែលជាកម្មវត្ថុ អាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុនោះស្ថិតនៅត្រូវដកយកវត្ថុនោះពីកូនបំណុលនៃការអនុវត្ត ហើយប្រគល់វត្ថុនោះទៅឱ្យម្ចាស់បំណុលនៃការអនុវត្ត តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត។

យ៉ាងណាមិញប្រសិនបើកូនបំណុលនៃការអនុវត្តមិនពេញចិត្តចំពោះការកំណត់សញ្ញាណនៃវត្ថុ កូនបំណុលនោះ អាចធ្វើការតវ៉ាចំពោះការអនុវត្តបាន។ វត្ថុកាន់កាប់ដោយតតិយជននៅក្នុងដៃដែលតតិយជនជាអ្នកកាន់កាប់ចលនវត្ថុ ដែលជាកម្មវត្ថុវិញ ដូចក្នុងករណីនៃការអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ ម្ចាស់បំណុលនៃការអនុវត្តត្រូវទទួលដីកាសម្រេចរបស់តុលាការអនុវត្ត ដែលបង្គាប់ឱ្យរឹបអូសសិទ្ធិទាមទារឱ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជនហើយ ទាមទារឱ្យតតិយជននោះប្រគល់វត្ថុដែលជាកម្មវត្ថុមកឱ្យខ្លួនដោយដោយផ្អែកលើដីកាសម្រេចរឹបអូស[116]។

**កថាភាគទី៤. ការបិទបញ្ចប់ការប្រគល់**

ការបិទបញ្ចប់ការប្រគល់ចលនវត្ថុ ត្រូវបានបញ្ចប់ដោយការធ្វើកំណត់ហេតុប្រគល់របស់អាជ្ញាសាលា ហើយប្រគល់ចលនវត្ថុនោះឱ្យទៅម្ចាស់បំណុលនៃការអនុវត្ត។

[116] មាត្រា ៤០៣ ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

បច្ចុប្បន្នប្រព័ន្ធតុលាការនៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានការរីកចម្រើន ហើយនិងកំពុងធ្វើការកែទម្រង់ដើម្បីឱ្យមានការសមស្របទៅនិងគោលនយោបាយរបស់រាជរដ្ឋាភិបាល ពិសេសជាងនេះទៅទៀត រាជរដ្ឋាភិបាលកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងបំផុតចំពោះការជម្រះក្តី និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋពិតប្រាកដ។ ក្រោយពីបានធ្វើការបកស្រាយលើប្រធានបទ " ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល " យើងសង្កេតឃើញថាមានស្ថាប័នមួយមានលក្ខណៈឯករាជ្យ និងជាស្ថាប័នអនុវត្តសាលក្រម និងសាលដីការបស់តុលាការ ជាពិសេសអនុវត្តនូវកិច្ចការនានាក្នុងការជួយសម្រួលដល់ស្ថាប័នតុលាការ ហើយនិងស្ថាប័ននឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រួលដល់ការអនុវត្តសាលក្រម ឬសាលដីកា។

មួយវិញទៀតទោះបីជាតុលាការអនុវត្តមានរូបរាងនិងរចនាសម្ព័ន្ធមួយច្បាស់លាស់ក៏ដោយ ប៉ុន្តែចំពោះការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺនៅតែមិនទាន់ត្រូវបានអនុវត្តទៅរលូនដដែល ដែលកិច្ចការនេះត្រូវបានប្រគល់ទៅឱ្យចៅក្រមអនុវត្តនៃសាលាដំបូងរាជធានីខេត្តជាអ្នកអនុវត្ត ដោយហេតុថាមានការនៅខ្វះចន្លោះដែល។ បន្ថែមលើសពីនេះទៅទៀតបើមើលទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជាយើងបានកំណត់នៅនីតិវិធីមួយជាក់លាក់សម្រាប់ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនិងបានកំណត់នៅលក្ខខណ្ឌច្បាស់លាស់ហើយនិងបានកំណត់អំពីអពីសារៈសំខាន់នៃការដាក់ពាក្យសុំដើម្បីឱ្យតុលាការធ្វើការអនុវត្តដោយបង្ខំចំពោះកូនបំណុលនៃការអនុវត្ត។

បន្ថែមលើសពីនេះទៅទៀតគឺនៅក្នុងប្រធានបទនេះ គឺមានសារៈសំខាន់យ៉ាងខ្លាំងចំពោះការអនុវត្តនៅក្នុងស្ថានភាពបច្ចុប្បន្នដែលតែងតែកើតមាននៅក្នុងសង្គមជាពិសេសចំពោះប្រជាពលរដ្ឋដែលមានការយល់ដឹងផ្នែកប្រព័ន្ធច្បាប់ គឺត្រូវមានការពឹងពាក់ទៅមេធាវីដើម្បីឱ្យមេធាវីជួយក្នុងការដើរក្តីនៅក្នុងដំណាក់កាលនៃការដំណើរការនៃរឿងក្តី។ មួយវិញទៀតចំពោះប្រធានបទនេះគឺមានចំណុចសំខាន់ជាច្រើនដែលអាចយកទៅធ្វើការសិក្សាដល់អ្នកដែលចង់យល់ដឹងនិងចង់ចេះទៅលើប្រធានបទមួយនេះ។

លើសពីនេះទៅទៀត តាមរយៈការសិក្សាស្រាវជ្រាវ បានឱ្យយើងយល់ដឹងកាន់តែច្បាស់មួយកម្រិតទៀតទៅលើប្រធានបទ "ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល" និងបានដឹងកាន់តែច្បាស់ថាការអនុវត្តរបស់តួនាទីរបស់ចៅក្រមនៅក្នុងការអនុវត្តនៅស្ថានភាពជាក់ស្តែងនៅក្នុងពេលបច្ចុប្បន្ននេះ គឺមិនទាន់មានលក្ខណៈគ្រប់គ្រាន់ និងច្បាស់លាស់ដូចដែលមានចែងក្នុងច្បាប់នៅឡើយទេគឺនៅមានចំណុចខ្វះខាត។

បើយើងមើលតាមការអនុវត្តជាក់ស្តែងពិតណាស់ថាការបណ្តុះបណ្តាលចៅក្រមជាបន្តបន្ទាប់ពីមួយជំនាន់ទៅមួយជំនាន់ក្តី តែទោះបីជាយ៉ាងនេះក៏ដោយក៏ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនៅតែមើលទៅហាក់បីដូចជាមានភាពផ្ទុយគ្នាពីអ្វីដែលមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាថ្មីនេះបានកំណត់។ ការអនុវត្តនៅក្នុងករណីជាក់ស្តែងគឺតែងតែមានការធ្វើការដោះស្រាយទៅតាមច្បាប់និងទៅតាមនីតិវិធីរបស់តុលាការនីមួយៗដែលជាតុលាការនោះគឺជាតុលាការអនុវត្ត។

ហើយចំពោះការស្រាវជ្រាវមួយនេះគឺនៅមានចន្លោះខ្វះខាតខ្លះដែលមាននៅលើប្រធានបទមួយនេះដែលមានការផ្លាស់ប្តូរទៅតាមការបត់បែននៃការអនុវត្តជាក់ស្តែងនិងទៅតាមការដោះស្រាយនៅក្នុងករណីជាក់ស្តែងដែលមានការលំបាក ដោយហេតុថាពេលខ្លះមានច្បាប់ចែងពិតមែនតែមានការលំបាកក្នុងការអនុវត្តដោយជួប។ ករណីរឿងជាក់ស្តែងដែលមានការលំបាកខ្លាំង ប៉ុន្តែតុលាការនៅតែមានដំណោះស្រាយជានិច្ចជូនប្រជាពលរដ្ឋក្នុងការទទួលបានយុត្តិធម៌។ ទៀតសោតចំពោះប្រធានបទមួយនេះយើងនិងមានការស្រាវជ្រាវនៅពេលក្រោយបន្តទៅទៀតនៅចំណុចដែលមានការខ្វះខាតនៅក្នុងការស្រាវជ្រាវនៅលើប្រធានបទមួយនេះដោយសារការស្រាវជ្រាវរបស់ពួកយើងមានដែនកំណត់នៅក្នុងការសិក្សាស្រាវជ្រាវ។

# អនុសាសន៍

# អនុសាសន៍

ឆ្លងកាត់តាមការសិក្សាស្រាវជ្រាវអំពីប្រធានបទ " ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល " ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល គឺជានីតិវិធីមួយដែលពោរពេញទៅដោយភាពចម្រូងចម្រាស និងពេលខ្លះអាចមានការប្រឆាំងតបមកតុលាការអនុវត្តក៏មាន។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលនោះគឺត្រូវបានធ្វើឡើងដោយស្របតាមបញ្ញត្តិច្បាប់ផងដែរ។ ចំពោះការស្របច្បាប់នៅត្រង់ថាការអនុវត្ត គឺត្រូវបានធ្វើតាមការសម្រេចសេចក្តីរបស់ស្ថាប័នតុលាការ និងតាមការស្នើសុំពីម្ចាស់បំណុលនៃការអនុវត្ត។ មួយវិញទៀត ដោយឡែកប្រជាពលរដ្ឋខ្មែរមួយចំនួនធំនៅមិនទាន់ស្គាល់ច្បាស់ពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល និងស្ថាប័នអនុវត្តដោយបង្ខំនៅឡើយទេ ហេតុដូចនេះហើយទើបបានជារាល់ពេលអនុវត្តដោយបង្ខំម្តងៗគឺកូនបំណុលនៃការអនុវត្ត និងប្រជាពលរដ្ឋបែរជាចោទប្រកាន់ថានេះគឺជាសកម្មភាពដែលចេញពីគោលបំណងនៃអាជ្ញាធរសាធារណៈទៅវិញ ។ ជាការពិតណាស់ថាកងកម្លាំង និងអាជ្ញាធរសាធារណៈគឺជាអ្នកអនុវត្តដោយបង្ខំ តែមិនមែនមានន័យថា នេះគឺជាឆន្ទៈរបស់អាជ្ញាធរសាធារណៈនោះទេ ។ ផ្ទុយទៅវិញវាគឺជាគោលបំណង និងសិទ្ធិរបស់ ម្ចាស់បំណុល ដែលមានសាលក្រម ឬសាលដីការបស់តុលាការអនុវត្តហើយបានដាក់ពាក្យសុំឱ្យតុលាការអនុវត្ត ដោយអនុវត្តនូវសិទ្ធិទាមទារលើទ្រព្យសម្បត្តិនោះមកប្តូរជាប្រាក់វិញ។ ដូច្នេះហើយទើបប្រជាពលរដ្ឋខ្មែរយើងមិនគួរមើលរំលង នូវស្ថាប័នមួយនេះឡើយ ព្រោះវាគឺជាស្ថាប័នមួយដែលជួយដល់ការអនុវត្តសាលក្រម ឬ សាលដីការបស់តុលាការ។

បន្ថែមលើសពីនេះទៅទៀតក្រោយបានសិក្សាលំអិតទៅលើប្រធានបទ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលយ៉ាងស៊ីជម្រៅរួចមក សមាជិកក្រុមយើងខ្ញុំបានកត់សម្គាល់ឃើញថានីតិវិធីនេះមានភាពស្មុគស្មាញហើយពិបាកយល់ជាច្រើនកន្លែងទៀតផង។ ទៀតសោតភាពមិនច្បាស់លាស់នេះ កើតមានឡើងនៅពេលដែលម្ចាស់បំណុលបានដាក់ពាក្យព្រោះថា ជាការអនុវត្ត អ្នកដាក់ពាក្យសុំភាគច្រើនសរសេរពាក្យសុំខុសពីការកំណត់នៃច្បាប់។ ជារួមមក ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ជានីតិវិធីមួយថ្មីសម្រាប់ព្រះរាជាណាចក្រកម្ពុជាហើយមកដល់ពេលនេះយើងមិនសូវមានសំណុំរឿងនេះច្រើនទេនៅតាមសាលាដំបូងរាជធានីខេត្ត។ ជាដំណោះស្រាយនៅក្នុងស្ថានភាពជាក់ស្តែង ស្ថាប័នពាក់ព័ន្ធគួរធ្វើការផ្សព្វផ្សាយ និង បណ្តុះបណ្តាលឱ្យបានច្រើន និងបានកាន់តែទូលំទូលាយអំពីការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលទាំងមន្ត្រីអនុវត្តច្បាប់ក៏ដូចជាសាធារណជនទូទៅ។

ដូច្នេះហើយ យើងខ្ញុំទាំងពីសូមសំណូមពរមួយចំនួនដើម្បីជាការបន្ថែមទៅលើការដោះស្រាយរាល់បញ្ហាប្រឈមដែលកើតមានឡើង និង ដើម្បីការពារផលប្រយោជន៍ដល់ភាគីទាំងសងខាងនៅក្នុងសំណុំរឿងអនុវត្តដោយបង្ខំមានដូចជា៖

១.សូមសំណូមពរដល់តុលាការត្រូវតែធ្វើការស្រាវជ្រាវ រួមទាំងពិនិត្យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសាលក្រម ឬសាលដីការបស់តុលាការឱ្យបានច្បាស់លាស់ ព្រោះដើម្បីឱ្យប្រាកដថាការអនុវត្តដោយបង្ខំនីមួយៗមានលក្ខណៈត្រឹមត្រូវ យុត្តិធម៌ និងស្មើភាព។

២.សូមសំណូមពរដល់តុលាការត្រូវតែត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវឱ្យបានស៊ីជម្រៅស្ដីអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃសេចក្ដីសម្រេចមជ្ឈត្តករ គឺក្នុងន័យធ្វើឱ្យការអនុវត្តដោយបង្ខំ មិនបង្កឱ្យបាត់បង់ផលប្រយោជន៍របស់ភាគីណាម្ខាង។

៣.សូមសំណូមពរដល់អាជ្ញាសាលានៃសាលាដំបូង ក៏ត្រូវធ្វើការពិនិត្យឱ្យបានច្បាស់នូវពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុល មុននឹងធ្វើការអនុវត្ត ដើម្បីឱ្យការអនុវត្តដោយបង្ខំនោះមាន ភាពត្រឹមត្រូវ យុត្តិធម៌ និងមិនបំពានទៅលើភាគីដែលជាកូនបំណុល។

៤.សូមសំណូមពរ ចំពោះការសុំឱ្យផ្ដល់រូបមន្តអនុវត្តដោយ ក្រឡាបញ្ជី ឬសារការីធ្វើការផ្ទៀងផ្ទាត់លើច្បាប់ដើមនៃលិខិតអនុវត្ត និងសំណុំរឿងជាអាទិ៍ និងធ្វើការពិនិត្យសាលក្រមថាបានចូលជាស្ថាពរហើយឬនៅប្រសិនបើឃើញថាត្រឹមត្រូវហើយ ក្រឡាបញ្ជី ឬ សារការី នឹងផ្ដល់រូបមន្តអនុវត្តលើឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- ❖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០, ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧
- ❖ ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១, ថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០០៦
- ❖ ប្រកាសអន្តរក្រសួង លេខ៥៩ ប្រក.ជ.ន.ស/១១ ស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១១
- ❖ ប្រកាសលេខ ៣០ កយ.ប្រក/០៧ ស្តីពីមន្ត្រីទទួលបន្ទុកកិច្ចការអាជ្ញាសាលា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧

## ២. សេចក្តីពន្យល់ក្រមនីតិវិធី និងប្រភពឯកសារផ្សេងៗ

- ❖ សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ២: ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ រៀបចំដោយក្រុមការងារជប៉ុនដែលទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា ឆ្នាំ២០០៩
- ❖ សេចក្តីកំណត់មាត្រាក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧
- ❖ សេចក្តីព្រាងច្បាប់ អាជ្ញាសាលា ឆ្នាំ២០១២
- ❖ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល ធ្វើបទបង្ហាញដោយក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ❖ ការផ្អាក និងការលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំ ធ្វើបទបង្ហាញដោយក្រុមការងាររាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ
- ❖ អត្ថបទ ការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុល (ករណី៖ ការរឹបអូសប្រាក់ដែលមាននៅគណនីធនាគារ) រៀបរាងដោយ លោក ស៊ុន លៀងហេង

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមឧបសម្ព័ន្ធ

| ល.រ | ឈ្មោះឯកសារ |
|---|---|
| ០១ | ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី: ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត |
| ០២ | ពាក្យសុំអនុវត្តដោយបង្ខំ |
| ០៣ | ពាក្យសុំអនុវត្តជំនួស |
| ០៤ | ពាក្យសុំឱ្យផ្តល់រូបមន្តអនុវត្ត |
| ០៥ | លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលដីកា |
| ០៦ | លិខិតបញ្ជាក់ការចូលជាស្ថាពរនៃដីកាសម្រេច |
| ០៧ | ការកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្តី |
| ០៨ | តារាងឧបសម្ព័ន្ធ |
| ០៩ | រូបមន្តអនុវត្ត |
| ១០ | រូបមន្តអនុវត្តដីកាសម្រេច |
| ១១ | រូបមន្តអនុវត្តសាលដីកា |
| ១២ | រូបមន្តអនុវត្តពិសេស |
| ១៣ | ដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល |

ឧបសម្ព័ន្ធ ១

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**ក្រសួងយុត្តិធម៌**

លេខ :៥៩ ប្រក.ដ.វ.ស/១១ រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ ២០១១

**ប្រកាសអន្តរក្រសួង**
**ស្តីពី**
**ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**
**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញក្រឹត្យលេខ ០៦ ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែ កក្កដា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៤៦អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពី ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ
- តាមការចាំបាច់ក្នុងការអនុវត្តក្រមនីតិវិធីរដ្ឋប្បវេណី

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ ១ :** គោលដៅ

ប្រកាសនេះ មានគោលដៅធានានូវប្រសិទ្ធភាព នៃការចុះបញ្ជីអចលនវត្ថុឱ្យបានត្រឹមត្រូវទៅតាមក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ២ :** គោលបំណង

១-ប្រកាសនេះ បញ្ញត្តអំពីនីតិវិធីនៃការផ្ទុកផ្ដាក់របស់ក្រឡាបញ្ជី ទៅស្ថាប័នដែលមានសមត្ថកិច្ចចុះបញ្ជីអំពីការរឹបអូស ការផ្ទេរ ការលុបចោល ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្ន ដោយយោងតាមក្រមនីតិវិធីរដ្ឋប្បវេណី និងនីតិវិធីនៃការចុះបញ្ជីទាំងនោះ ។

២-ប្រកាសនេះ ក៏បញ្ញត្តផងដែរអំពីនីតិវិធីនៃការចុះបញ្ជីអចលនវត្ថុតាមរយៈ សាលក្រម សាលដីកា ដីកាសម្រេច ឬ លិខិតអនុវត្តដោយផ្អែកលើការផ្សះផ្សា ឬ ការទទួលស្គាល់នូវការទាមទារ យោងតាមមាត្រា ៥២៩ (ការចាត់ទុកថាបានបង្ហាញឆន្ទៈ) នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**ប្រការ ៣ :** វិសាលភាព

ប្រកាសនេះ ត្រូវយកមកអនុវត្ត ចំពោះដីដែលកម្មសិទ្ធិត្រូវបានចុះបញ្ជី ក្នុងសៀវភៅគោលបញ្ជីដីធ្លី ហើយដែលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រូវបានចេញ ។

ប្រកាសនេះ ក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះដីដែលត្រូវបានចុះបញ្ជី ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ហើយដែលប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬ ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីត្រូវបានចេញ ។

**ប្រការ ៤ :** ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី

ស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីតាមន័យនៃប្រកាសនេះ គឺរដ្ឋបាលសុរិយោដីដែលបានកំណត់ដូចខាងក្រោមនេះ :

-ចំពោះការចុះបញ្ជីដែលបានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ២ (គោលបំណង)

ឃ-មូលហេតុ ៖

-ដីកាសម្រេចអនុញ្ញាតឱ្យលក់លេខ.......ចុះថ្ងៃទី....ខែ.....ឆ្នាំ..... និងឈ្មោះរបស់តុលាការ.........................

-អ្នកទិញបានបង់ថ្លៃលក់ទៅឱ្យតុលាការ...................នៅថ្ងៃទី........ខែ.......ឆ្នាំ.........

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត....................(អាសយដ្ឋាន................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.....................(អាសយដ្ឋាន................)

ឆ-អត្តសញ្ញាណអ្នកទិញ...........................(ថ្ងៃទី.....ខែ.....ឆ្នាំ......ទីកន្លែងកំណើត ឈ្មោះឪពុកម្ដាយ អាសយដ្ឋាន .......................................)

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូត នៃដីកាសម្រេចអនុញ្ញាតឱ្យលក់

-ឯកសារថតចម្លងអត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនរបស់អ្នកទិញ

-ឯកសារចម្លងយថាភូតនៃកំណត់ហេតុ ដែលបញ្ជាក់ថាអ្នកទិញ បានបង់ថ្លៃលក់ទៅតុលាការអនុវត្តរួចហើយ ។

## កថាភាគទី ៣

## ការចុះបញ្ជីដែលពាក់ព័ន្ធនឹងការអនុវត្តដោយបង្ខំចំពោះ សិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត

**ប្រការ ១៣ :** លិខិតផ្ទុកផ្ដាក់ឱ្យចុះបញ្ជីអំពីការរឹបអូស ចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត ដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលបានចុះបញ្ជីបានបង្កើតអានុភាព តាមពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្រឡាបញ្ជីត្រូវផ្ទុកផ្ដាក់ឱ្យស្ថាប័នមានសមត្ថកិច្ចចុះបញ្ជីបញ្ជាក់ថា សិទ្ធិលើបំណុលនោះត្រូវបានរឹបអូសហើយ ។



7 8

ចំពោះពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្តដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវសរសេរនូវចំណុចដូចខាងក្រោម :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃដីកាសម្រេចរឹបអូសចំពោះសិទ្ធិលើបំណុល (ប្រសិនបើមាន)

-សញ្ញាណរបស់ម្ចាស់បំណុលនៃការអនុវត្ត កម្មសិទ្ធិករនៃអចលនវត្ថុ ដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ កូនបំណុលនៃការអនុវត្ត និងកូនបំណុលទី ៣

-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណនៃសិទ្ធិលើបំណុល ដែលម្ចាស់បំណុលទាមទារឱ្យអនុវត្តដោយបង្ខំទៅលើកូនបំណុលនៃការអនុវត្ត ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:...............................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ........................(លេខក្បាលដី ឬ លេខប័ណ្ណដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិជួលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុ...... ...............................(អាសយដ្ឋាន..............................................)

គ-គោលបំណងនៃការចុះបញ្ជី.........................(ការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ...................(ដីកាសម្រេចរឹបអូសលេខ.....ចុះថ្ងៃទី.....ខែ..... ឆ្នាំ.....ហើយថ្ងៃទី.....ខែ.....ឆ្នាំ......ដែលដីកាសម្រេចមានអានុភាព និងឈ្មោះរបស់តុលាការ ...............................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត........................(អាសយដ្ឋាន........... ........................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត............................(អាសយដ្ឋាន......... ........................)

ឆ-ឈ្មោះកូនបំណុលទី ៣ ..........................(អាសយដ្ឋាន................ ........................)

ជ- សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយៈ

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចរឹបអូស ដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជី អំពីកាលបរិច្ឆេទ ដែលដីកាសម្រេចរឹបអូសនោះមានអានុភាព។

ចំពោះដីកាសម្រេចរឹបអូសខាងលើមានអានុភាព នៅពេលដែលបានបញ្ជូនទៅដល់កូនបំណុលទី ៣ ។

-ឯកសារចម្លងនៃពាក្យសុំរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលមានសេចក្តីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

**ប្រការ ១៤ : លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដោយផ្អែកលើមាត្រា ៤០៨ មាត្រា ៤១០ និងមាត្រា ៤១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

បើមានពាក្យសុំឱ្យលុបការចុះបញ្ជី ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

- បើពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលត្រូវបានដកវិញ ឬ
- បើដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលមានអានុភាព ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ឬ
- បើតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការអនុវត្តដូចជា : សញ្ញាណនៃរឿងក្តី ឈ្មោះនាមករណីរបស់ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត មូលហេតុនៃការធ្វើចំនួនទឹកប្រាក់ដែលបានធ្វើជាដើម ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុៈ...........................(សរសេរអំពីខ្លឹមសារផ្ទុកផ្តាក់ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុលដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត)

ក-អត្តសញ្ញាណនៃអចលនវត្ថុ.......................(លេខក្បាលដី ឬ លេខប័ណ្ណ



*7 8*

ដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ដែលធានាសិទ្ធិលើបំណុលដែលត្រូវបានរឹបអូស)

ខ-ឈ្មោះកម្មសិទ្ធិករ ឬម្ចាស់សិទ្ធិផ្ទាល់អចិន្ត្រៃយ៍ ឬ ផលុបភោគីនៃអចលនវត្ថុ.......... (អាសយដ្ឋាន ..................................................................................)

គ-គោលបំណងនៃការចុះបញ្ជី..................(ការលុបការចុះបញ្ជីអំពីការរឹបអូសសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតទៅលើអចលនវត្ថុចំណុច "ក")

ឃ-មូលហេតុ.........................(ការដកពាក្យសុំឱ្យអនុវត្តចំពោះសិទ្ធិលើបំណុលនៅថ្ងៃទី.......ខែ......ឆ្នាំ.......ដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តចំពោះសិទ្ធិលើបំណុលលេខ......ចុះថ្ងៃទី......ខែ.......ឆ្នាំ.......ហើយថ្ងៃទី......ខែ......ឆ្នាំ......ដែលមានអានុភាព និងឈ្មោះរបស់តុលាការ ឬ ការសងប្រាក់ ឬ ការផ្ញើប្រាក់របស់កូនបំណុលទី ៣ ចុះថ្ងៃទី..... ខែ......ឆ្នាំ........)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន........... ............................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត..........................(អាសយដ្ឋាន.......... ............................................)

ឆ-ឈ្មោះកូនបំណុលទី៣.....................................(អាសយដ្ឋាន.......... ............................................)

ជ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុល ដែលត្រូវបានធានា

ឯកសារភ្ជាប់ជាមួយ :

១-ក្នុងករណីមានការដកពាក្យសុំអនុវត្តចំពោះសិទ្ធិលើបំណុល :

ក-នៅពេលដែលការដកពាក្យសុំធ្វើឡើងជាលាយលក្ខណ៍អក្សរ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតពាក្យសុំនោះ ដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

ខ-នៅពេលដែលការដកពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់ ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លង យថាភូតនៃកំណត់ហេតុនៃការដកពាក្យសុំនោះ ។

២-ក្នុងករណីដីកាសម្រេចលុបចោលនីតិវិធីនៃការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលមានអានុភាព :



ℱ ℋ

ក-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ១ នៃមាត្រា ៣៧០ (ការផ្អាក និងការលុបចោលការអនុវត្តដោយបង្ខំ)

ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោល ។

ខ-ការលុបចោលដោយផ្អែកលើកថាខណ្ឌទី ២ នៃមាត្រា ៣៧៥ (ការបង់សោហ៊ុយជាមុន) ក្រឡាបញ្ជីត្រូវភ្ជាប់នូវឯកសារចម្លងយថាភូតនៃដីកាសម្រេចលុបចោលដែលមានសេចក្ដីបញ្ជាក់ពីក្រឡាបញ្ជីថាបានចូលជាស្ថាពរ ។

៣-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីម្ចាស់បំណុល នៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ ពីម្ចាស់បំណុលនៃការអនុវត្តថាបានទទួលសំណងពីកូនបំណុលទី ៣ ហើយក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីម្ចាស់បំណុលនៃការអនុវត្តនោះ ។

៤-ក្នុងករណីតុលាការអនុវត្តបានទទួលដំណឹងពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការអនុវត្ត :

ក-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងជាលាយលក្ខណ៍អក្សរ ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងនៃលិខិតជូនដំណឹងនោះ ដែលមានសេចក្ដីបញ្ជាក់ថាបានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ខ-នៅពេលដែលតុលាការអនុវត្តបានទទួលដំណឹងដោយផ្ទាល់មាត់ពីកូនបំណុលទី ៣ អំពីស្ថានភាពដែលពាក់ព័ន្ធទៅនឹងការធ្វើប្រាក់ទៅតុលាការ ក្រឡាបញ្ជីត្រូវភ្ជាប់ជាមួយនូវឯកសារចម្លងយថាភូតនៃកំណត់ហេតុនៃការបានទទួលដំណឹងពីកូនបំណុលទី ៣ ។

## ប្រការ ១៥ : លិខិតផ្ទេរផ្ដាក់ឱ្យចុះបញ្ជីអំពីការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតដោយផ្អែកលើកថាខណ្ឌទី ១០ នៃមាត្រា ៤១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី

បើបានបញ្ចប់ការលក់ចំពោះសិទ្ធិលើបំណុល ដែលត្រូវបានធានាដោយហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀតរួចហើយ ក្រឡាបញ្ជីត្រូវផ្ទេរផ្ដាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជី

ផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូសតាមពាក្យសុំរបស់អ្នកទិញ ។

ចំពោះពាក្យសុំរបស់អ្នកទិញ ត្រូវសរសេរនូវចំណុចដូចខាងក្រោមនេះ :

-កម្មវត្ថុនៃពាក្យសុំ

-សញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀតដែលត្រូវបានផ្ទេរ

-សញ្ញាណអ្នកទិញ

-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបានធានា

-សញ្ញាណម្ចាស់អចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត

-មូលហេតុនៃការផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត ។

លិខិតផ្ទុកផ្ដាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្ដាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :

កម្មវត្ថុ:................................(សរសេរអំពីខ្លឹមសារឱ្យចុះបញ្ជីផ្ទេរហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត និងឱ្យលុបការចុះបញ្ជីអំពីការរឹបអូស)

ក-អត្តសញ្ញាណនៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (លេខក្បាលដី ឬ លេខប័ណ្ណ និងទីតាំងដី)

ខ-ឈ្មោះកម្មសិទ្ធិករ ឬ ម្ចាស់សិទ្ធិផលអចិន្ត្រៃយ៍ ឬ ផលុបភោគី នៃអចលនវត្ថុដែលជាកម្មវត្ថុនៃហ៊ីប៉ូតែក ឬ សិទ្ធិប្រាតិភោគផ្សេងទៀត (អាសយដ្ឋាន.........................)

គ-គោលបំណងនៃការចុះបញ្ជី.......................(ផ្ទេរហ៊ីប៉ូតែក ឬសិទ្ធិប្រាតិភោគផ្សេងទៀត និងលុបការចុះបញ្ជីអំពីការរឹបអូស )

ឃ-មូលហេតុ..................(អាជ្ញាសាលាបានទទួលប្រាក់ពីការលក់ នៅថ្ងៃទី....... ខែ........ឆ្នាំ........... និងឈ្មោះរបស់តុលាការ.........................)

ង-ឈ្មោះម្ចាស់បំណុលនៃការអនុវត្ត.......................(អាសយដ្ឋាន.............. ................................)

ច-ឈ្មោះកូនបំណុលនៃការអនុវត្ត.........................(អាសយដ្ឋាន............ ................................)

ឆ-ឈ្មោះកូនបំណុលទី ៣...........................(អាសយដ្ឋាន........... ................................)



7 8

ជ-អត្តសញ្ញាណអ្នកទិញ......................................(អាសយដ្ឋាន...........
.......................................)

ឈ-សញ្ញាណនៃសិទ្ធិប្រាតិភោគ និងសិទ្ធិលើបំណុលដែលត្រូវបាត់បង់ ។

ឯកសារភ្ជាប់ជាមួយ:

-ឯកសារចម្លងយថាភូតនៃដីកាសម្រេចបង្គាប់ឱ្យអាជ្ញាសាលាលក់

-ឯកសារចម្លងដែលមានសេចក្តីបញ្ជាក់ពីក្រឡាបញ្ជីថា បានចម្លងត្រឹមត្រូវតាមច្បាប់ដើម នៃកំណត់ហេតុដែលបញ្ជាក់ថា អ្នកទិញបានបង់ថ្លៃលក់ទៅអាជ្ញាសាលារួចហើយ

-ឯកសារចម្លងអត្តសញ្ញាណប័ណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកទិញ ។

## កថាភាគទី ៤

## ការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

**ប្រការ ១៦ : លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នដោយផ្អែកលើកថាខណ្ឌទី៣ និងទី ៤ នៃមាត្រា ៥៦៧ មាត្រា ៤២០ មាត្រា ៤២៤ និងមាត្រា ៤២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី**

នៅពេលដែលតុលាការបានចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ទៅស្ថាប័នមានសមត្ថកិច្ចចុះបញ្ជី ឱ្យចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្ននោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល ។

បើដីកាសម្រេចការរឹបអូសជាបណ្តោះអាសន្នបានអនុវត្តរួចហើយ តែមានពាក្យសុំឱ្យចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីមួយទៀត ចំពោះអចលនវត្ថុដដែលនោះ ហើយតុលាការទទួលស្គាល់ពាក្យសុំថ្មីនោះ តុលាការត្រូវចេញដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នថ្មីទៀត (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នត្រួតគ្នា) ហើយក្រឡាបញ្ជីត្រូវផ្ទុកផ្តាក់ឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការចុះបញ្ជីអំពីការរឹបអូសជាបណ្តោះអាសន្នចំពោះអចលនវត្ថុនោះ តាមពាក្យសុំអនុវត្តរបស់ម្ចាស់បំណុល (ដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នអាចចេញដោយតុលាការផ្សេង យោងតាមមាត្រា ៥៤០ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។

លិខិតផ្ទុកផ្តាក់ដូចមានចែងនៅក្នុងប្រការ ៥ (ទម្រង់នៃលិខិតផ្ទុកផ្តាក់) នៃវាក្យខណ្ឌទី ២ ត្រូវសរសេរបន្ថែមនូវចំណុចដូចខាងក្រោមនេះ :



ᚠ ៥

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំអនុវត្តដោយបង្ខំ

**ម្ចាស់បំណុលនៃការអនុវត្ត ៖** ឈ្មោះ............ ភេទ....... ជាតិខ្មែរ កើតឆ្នាំ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ ............... ចុះថ្ងៃទី....... ខែ.......... ឆ្នាំ......... មានអាសយដ្ឋានបច្ចុប្បន្នស្ថិតនៅ............ ភូមិ.......... សង្កាត់............ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**សហកូនបំណុលនៃការអនុវត្ត ៖** ឈ្មោះ ................ ភេទ............ ជាតិខ្មែរ កើតឆ្នាំ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ .................... និងឈ្មោះ ............... ជាតិខ្មែរ កើតឆ្នាំ.......... កាន់អត្តសញ្ញាណប័ណ្ណលេខ ..................... មានអាសយដ្ឋានរួមគ្នាស្ថិតនៅ................ ភូមិ............ សង្កាត់............ ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងខេត្តបាត់ដំបង**

**កម្មវត្ថុ ៖** សំណើសុំអនុវត្តដោយបង្ខំចំពោះចលនវត្ថុ មានទីតាំងស្ថិតនៅភូមិ............ សង្កាត់............ ក្រុងបាត់ដំបង ខេត្តបាត់ដំបង

**យោង ៖** - ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ។
- សាលក្រមរដ្ឋប្បវេណីលេខ ........... ចុះថ្ងៃទី....... ខែ........... ឆ្នាំ............ របស់សាលាដំបូងខេត្តបាត់ដំបង ។
- រូបមន្តអនុវត្តសាលក្រមលេខ ........... ចុះថ្ងៃទី....... ខែ........ ឆ្នាំ.............របស់សាលាដំបូងខេត្តបាត់ដំបង ។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរព និងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបនូវចំណុចសំខាន់ៗ ដែលជាមូលដ្ឋាននៃការអនុវត្តដូចខាងក្រោម ៖

**១.សញ្ញាណនៃលិខិតអនុវត្ត**

ឯកសារចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្តគឺ**សាលក្រមរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី...........ខែ............. ឆ្នាំ.............** របស់សាលាដំបូងខេត្តបាត់ដំបង ដែលមានខ្លឹមសារ ៖

១.បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ **............** និងឈ្មោះ .................. សងប្រាក់ជាប្រាក់ដុល្លារចំនួន **២៤,០០០ USD (ពីរម៉ឺន បួនពាន់ដុល្លារអាមេរិក)** និងប្រាក់រៀលចំនួន **៥,៥០០,០០០៛ (ប្រាំលាន ប្រាំសែនរៀល)** ទៅឲ្យដើមចោទឈ្មោះ **............** ។

២.សាលក្រមនេះប្រកាសអនុវត្តជាបណ្តោះអាសន្ន មានអនុភាពអនុវត្តបង្ខំតាមច្បាប់ ដូចមានបញ្ជាក់នៅក្នុងរបមន្តអនុវត្តសាលក្រមលេខ ................ ចុះថ្ងៃទី......... ខែ............. ឆ្នាំ............ របស់សាលាដំបូងខេត្តបាត់ដំបង ។

**២.សេចក្តីស្នើសុំឲ្យអនុវត្ត**

សំណើសុំឲ្យស្ថាប័នអនុវត្ត សាលាដំបូងខេត្តបាត់ដំបង អនុវត្តតាមវិធានបង្ខំដោយផ្ទាល់តាមអំណាច **សាលក្រមរដ្ឋប្បវេណីលេខ ............ ចុះថ្ងៃទី............ខែ......... ឆ្នាំ.............របស់សាលាដំបូងខេត្តបាត់ដំបង** ។

**៣.សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត**

ចលនវត្ថុរបស់ឈ្មោះ............ និងឈ្មោះ................ មានទីតាំងស្ថិតនៅភូមិ............ សង្កាត់............. ក្រុងបាត់ដំបង ខេត្តបាត់ដំបង ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងអនុវត្តដោយក្តីអនុគ្រោះ ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ ។

បាត់ដំបង ថ្ងៃទី.........ខែ......... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

..................

ឧបសម្ព័ន្ធ ៣

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យសុំឲ្យអនុវត្តជំនួស

**សូមគោរពជូន**
**ឯកឧត្តមប្រធានសាលាដំបូងខេត្តបន្ទាយមានជ័យ**

**ម្ចាស់បំណុលនៃការអនុវត្ត ៖** ភេទស្រី កើតនៅថ្ងៃទី ខែ ឆ្នាំ១៩៤ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខៈ មានទីលំនៅបច្ចុប្បន្ន៖ ភូមិប៉ាលិលេយ្យ ១ សង្កាត់ប៉ោយ បត ក្រុងបោយ បត ខេត្តបន្ទាយមានជ័យ ទូរស័ព្ទលេខ

**អ្នកតំណាងដោយអាណត្តិ៖** លោកមេធាវី ជាមេធាវីសមាជិកគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា អត្តលេ ជាមេធាវីនៃ មានការិយាល័យផ្ទះលេខ ផ្លូវចេបា ភូមកោះនរាណ៍ សង្កាតនរោង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

**សហកូនបំណុលនៃការអនុវត្ត៖** ភេទស្រី អាយ ឆ្នាំ មានទីលំនៅបច្ចុប្បន្ន៖ រស់នៅផ្ទះប្រកសង្កស ដលសងខុសច្បាប់លើចំ ណកដីរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលស្ថិតនៅភូមិគីឡូលេខ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**<u>កម្មវត្ថុ</u>៖** សំណើរសុំអនុវត្តសាលដីការដ្ឋប្បវេណីស្ថាពរលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០៦ របស់តុលាការកំពូល។

**<u>យោង</u>** ៖ - មាត្រា ៥២៧ និងមាត្រា ៣៤៩ និងមាត្រាពាក់ព័ន្ធផ្សេងទៀតនៃក្រមនីតិវិធីរដ្ឋប្បវេណី។
- សាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០៦ របស់តុលាការកំពូល។
- រូបមន្តអនុវត្តលេខ **គកក-សរម** ចុះថ្ងៃទី ខែ ឆ្នាំ២០១៨ របស់តុលាការកំពូល។
- លិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលដីការដ្ឋប្បវេណីលេខ **គកក-សរម** ចុះថ្ងៃទី ខែ ឆ្នាំ២០១៨ របស់តុលាការកំពូល។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទសូមគោរព និងជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបនូវសញ្ញាណនៃលិខិតអនុវត្ត សេចក្តីស្នើសុំឱ្យអនុវត្ត និងទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្តដូចខាងក្រោម៖

១.សញ្ញាណនៃលិខិតអនុវត្ត៖

លិខិតចម្លងយថាភូតនៃលិខិតអនុវត្ត ដែលមានអានុភាពអនុវត្ត គឺសាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០៦ របស់តុលាការកំពូល ដែលបានសម្រេច៖

១.ប្រគល់ដីទំនាស់ទំហំ ម៉ែត្រការ៉េ ស្ថិតនៅភូមិគីឡូលេ៖ សង្កាត់ ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោយមកមន្ត្រីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត បានចុះវាស់វែងរូបសណ្ឋាន និងប្រវែងជ្រុងក្បាលដីរបស់ ភេទស្រី ដែលជាតំនូសបង្ហាញទីតាំងក្បាលដីលេខកូដ ចុះថ្ងៃទី ខែ ឆ្នាំ២០២០ មានទំហំ ម៉ែត្រការ៉េ

ចុះហត្ថលេខា និងប្រថាប់ត្រាជាផ្លូវការដោយការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលក្រុង ឱ្យមកចុងចម្លើយនៃបណ្តឹងសាទុកឈ្មោះ ។

២.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមបណ្តឹងសាទុកឈ្មោះ ភេទស្រី។

សាលដីកានេះត្រូវបានចូលជាស្ថាពរតាមបញ្ញត្តិនៃមាត្រា ១៩៣ នក្រមនីតិវិធីរដ្ឋប្បវេណី ចាប់តាំងពីថ្ងៃទី ខែ ឆ្នាំ២០០៦ ដូចមាននៅក្នុងលិខិតបញ្ជាក់ការចូលជាស្ថាពរនៃសាលដីកាលេខ **គកក-សរខ** ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ចេញដោយលោក ក្រឡាបញ្ជីនៃតុលាការកពូលេ ដូច្នេះសាលដីកានេះ គឺជាលិខិតអនុវត្តដូចមានចែងក្នុងមាត្រា ៣៥០ កថាខណ្ឌទី ២ ចំណុច "ក" នៃក្រមនីតិវិធីរដ្ឋប្បវេណី។

សាលដីកានេះមានអានុភាពអនុវត្តដោយបង្ខំ តាមបញ្ញត្តិនៃ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដោយមានភ្ជាប់ជាមួយនូវរូបមន្តអនុវត្តលេខ **គកក-ស.៧** ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៨ ចេញដោយលោក ក្រឡាបញ្ជីនៃតុលាការកំពូល។

២.សេចក្តីស្នើសុំឲ្យអនុវត្ត

សំណើរសុំឲ្យស្ថាប័នអនុវត្ត (តុលាការអនុវត្ត) អនុវត្តតាមវិធានបង្ខំដោយជំនួស។

៣.ខ្លឹមសារនៃដីកាសម្រេច ដែលម្ចាស់បំណុលនៃការអនុវត្តសុំ៖

សំណើសុំឱ្យតុលាការអនុវត្តចេញដីកាសម្រេចអនុវត្តជំនួស ដែលមានខ្លឹមសារ "អនុញ្ញាតឱ្យម្ចាស់បំណុលនៃការអនុវត្តឈ្មោះ អាចស្នើសុំទៅអាជ្ញាសាលាប្រចាំសាលាដំបូងខេត្តបន្ទាយមានជ័យ ធ្វើសកម្មភាព ដើម្បីរុះរើតូបលកដូរចំនួន តូប និងផ្ទះមួយប្រក់ស័ង្កសី ដែលបានសង់ខុសច្បាប់ដោយកូនបំណុលនៃការអនុវត្ត លើចំណែកដីរបស់ម្ចាស់បំណុលនៃការអនុវត្ត ដែលធ្វើឱ្យម្ចាស់បំណុលនៃការអនុវត្ត មិនអាចអនុវត្តសិទ្ធិកាន់កាប់ចូលទៅរស់នៅ និងសិទ្ធិអាស្រ័យផលលើដីស្របច្បាប់របស់ខ្លួនបាន តាមអំណាចសាលដីការដ្ឋប្បវេណីលេខ ចុះថ្ងៃទី ខែ ឆ្នាំ២០០៦ របស់តុលាការកំពូល ជំនួសឱ្យម្ចាស់បំណុលនៃការអនុវត្ត។

ខ្ញុំបាទសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា៖ ការអនុវត្តជំនួសដោយបង្ខំ សំរាប់គោលបំណងខាងលើ តាមអំណាចសាលដីការដ្ឋប្បវេ ខែ ឆ្នាំ២០០៦ របស់តុលាការកំពូលនេះត្រូវបានធ្វើឡើងចំនួន ០៣ លើករួចមកហើយដោយស្ថាប័នអនុវត្ត លើកទី១ ធ្វើនៅថ្ងៃទី ខែ ឆ្នាំ២០០៨ លើកទី២ ធ្វើនៅថ្ងៃទី ខែ ឆ្នាំ២០១៧ និងលើកទី៣ ធ្វើនៅថ្ងៃទី ឆ្នាំ២០២០ តែការអនុវត្តទាំងបីលើកមកនេះ មិនទាន់បានទទួលជោគជ័យនៅឡើយទេ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តមប្រធាន** មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

ថ្ងៃព្រហស្បតិ៍ ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី ឆ្នាំ២០២២

**ហត្ថលេខា និងត្រា**

<u>ជូនភ្ជាប់មកជាមួយនូវ៖</u>

-ឯកសារពាក់ព័ន្ធ។

**ឧបសម្ព័ន្ធ ៤**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំឲ្យផ្តល់រូបមន្តអនុវត្ត

**សូមគោរពជូន**

**លោក ....................... ចៅក្រមសាលាដំបូង..................**

ម្ចាស់បំណុលនៃការអនុវត្តៈ ឈ្មោះ................ តំណាងស្របច្បាប់ដោយលោក .......... តួនាទីជា...................... មានអាសយដ្ឋាន ភូមិ...................................................................................។

កូនបំណុលនៃការអនុវត្តៈ ឈ្មោះ .......... ភេទ......... អាយុ......................ឆ្នាំ សញ្ជាតិខ្មែរ មានអាសយដ្ឋាននៅ ភូមិ .............................................................................................................................................។

សញ្ញាណនៃលិខិតអនុវត្តៈ សាលក្រមរដ្ឋប្បវេណីលេខៈ ....... ចុះថ្ងៃទី..... ខែ..... ឆ្នាំ២០........... របស់សាលាដំបូង ខេត្ត/ក្រុង.......................។

ហេតុការណ៍ និងមូលហេតុនៃការសុំឲ្យផ្តល់រូបមន្តនៃការអនុវត្តន៍បណ្តោះអាសន្ន ដោយហេតុថាៈ យោងសេចក្តីសម្រេចបញ្ចប់ក្នុងសាលក្រមលេខ ......... ចុះថ្ងៃទី...... ខែ........ ឆ្នាំ២០...... របស់សាលាដំបូងខេត្ត/ក្រុង.......... ត្រង់ចំណុចទី ........ នៃសេចក្តីសម្រេចបានចែងថាៈ សាលក្រមនេះមានអានុភាពអនុវត្តជាបណ្តោះអាសន្ន ត្រង់ចំណុចទី ..............នៃសេចក្តីសម្រេចបញ្ចប់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោកចៅក្រម** មេត្តាពិនិត្យ និងសម្រេចតាមនីតិវិធីដោយក្តីអនុគ្រោះ។
សូម **លោកចៅក្រម** មេត្តាទទួលនូវការគោរពអំពីខ្ញុំបាទ។

ធ្វើនៅ................. ថ្ងៃទី....... ខែ....... ឆ្នាំ២០.....
ស្នាមមេដៃស្តាំ

**ឈ្មោះ**

**ឧបសម្ព័ន្ធ ៥**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

**លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលដីកា**

យើង.................................. ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** មាត្រា **១៩៣** មាត្រា **២៥៤** និងមាត្រា **២៧៣** នៃក្រមនីតិវិធីរដ្ឋប្បវេណី

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ........... ចុះថ្ងៃទី......... ខែ........ឆ្នាំ......... របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** សាលដីការដ្ឋប្បវេណីលេខ........... ចុះថ្ងៃទី......... ខែ.........ឆ្នាំ......... របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** របាយការណ៍បញ្ជូនសាលដីកា ចុះថ្ងៃទី...........ខែ..........ឆ្នាំ.................... ។

**-បានឃើញ** កាលបរិច្ឆេទដែលភាគីនីមួយៗបានទទួលការបញ្ជូនអនុសារសាលដីកា។

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី......... ខែ.........ឆ្នាំ......... របស់ឈ្មោះ........................ ដែលមានខ្លឹមសារស្នើសុំលិខិតបញ្ជាក់ការចូលស្ថាពរ នៃសាលដីការដ្ឋប្បវេណី លេខ........... ថ្ងៃទី.......... ខែ........ឆ្នាំ........... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**បញ្ជាក់ថា**

១.សាលដីការដ្ឋប្បវេណីលេខ ................ ថ្ងៃទី.............. ខែ...........ឆ្នាំ.............. របស់សាលាឧទ្ធរណ៍ភ្នំពេញ បានចូលស្ថាពរ ចាប់ពីថ្ងៃទី ........... ខែ........ ឆ្នាំ.......... រួចហើយ។

២.លិខិតបញ្ជាក់ការចូលស្ថាពរនៃសាលដីកានេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.............. ឆ្នាំ.............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ឧបសម្ព័ន្ធ ៦**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

## លិខិតបញ្ជាក់ការចូលស្ថាពរនៃដីកាសម្រេច

យើង.................................. ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** មាត្រា **២៥៩** មាត្រា **៣០៣ មាត្រា ៣១៤ និងមាត្រា ៣១៥** នៃក្រមនីតិវិធីរដ្ឋប្បវេណី

**-បានឃើញ** សំណុំរឿងរដ្ឋប្បវេណីលេខ ............... ចុះថ្ងៃទី......... ខែ..........ឆ្នាំ............ របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** ដីកាសម្រេចលើកពាក្យបណ្ដឹងឧទ្ធរណ៍លេខ .................... ចុះថ្ងៃទី........... ខែ...............ឆ្នាំ................. របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** របាយការណ៍បញ្ជូនដីកា ចុះថ្ងៃទី...........ខែ...........ឆ្នាំ..........(របស់គូភាគី ឬ ភាគីណាមួយ)។

**-បានឃើញ** ពាក្យសុំចុះថ្ងៃទី........ខែ........ឆ្នាំ........... របស់ឈ្មោះ....................... ដែលមានខ្លឹមសារ ស្នើសុំលិខិតបញ្ជាក់ការចូលស្ថាពរនៃដីកាសម្រេចលេខ............. ថ្ងៃទី.......... ខែ..............ឆ្នាំ.................. របស់សាលាឧទ្ធរណ៍ភ្នំពេញ។

### បញ្ជាក់ថា

១.ដីកាសម្រេចលេខ .............. ចុះថ្ងៃទី....... ខែ.........ឆ្នាំ........របស់សាលាឧទ្ធរណ៍ភ្នំពេញ បានចូលស្ថាពរ ចាប់ពីថ្ងៃទី .......... ខែ.......... ឆ្នាំ............ រួចហើយ។

២.លិខិតបញ្ជាក់ការចូលស្ថាពរនៃដីកានេះ ចេញឱ្យសាមីខ្លួនដើម្បីយកទៅប្រើប្រាស់តាមច្បាប់។

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ............. ឆ្នាំ............

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ក្រឡាបញ្ជី**

ឧបសម្ព័ន្ធ ៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ....................ក.ប្រ.ឧ/២០

# ការកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី

**-បានឃើញ** សំណុំរឿងលេខ:.................. ចុះថ្ងៃទី..............ខែ.............ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** បញ្ញត្តិមាត្រា ៦៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

**-បានឃើញ** សាលដីកាស្ថាពរលេខ:................. ចុះថ្ងៃទី..............ខែ...........ឆ្នាំ............ របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

**-បានឃើញ** ពាក្យសុំកំណត់ជាស្ថាពរនូវចំនួនប្រាក់ប្រដាប់ក្ដី ចុះថ្ងៃទី..........ខែ........ឆ្នាំ............ របស់ឈ្មោះ.....................។

**-យល់ឃើញថា** ប្រាក់ប្រដាប់ក្ដី មានដូចនៅក្នុងតារាងឧបសម្ព័ន្ធ ដែលភាគី.............................. ឈ្មោះ ........................ បានចំណាយរួចហើយ មានចំនួន..........................រៀល ជាបន្ទុករបស់ភាគី...................... តាមអំណាចសាលដីកាស្ថាពរលេខ:................ ចុះថ្ងៃទី................ខែ..................ឆ្នាំ.................. របស់សាលាឧទ្ធរណ៍ភ្នំពេញ ។

**<u>កំណត់</u>**

ប្រាក់ប្រដាប់ក្ដីចំនួន................................................... ជាបន្ទុករបស់ភាគី.........................។

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.............. ឆ្នាំ.............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ឧបសម្ព័ន្ធ ៨**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

## តារាងឧបសម្ព័ន្ធ

១-បង្កាន់ដៃបង់ប្រាក់លេខ:............... ចុះថ្ងៃទី............ខែ............ឆ្នាំ............ របស់............
ដែលឈ្មោះ ..................................... ជាភាគី.................................. បានបង់ប្រាក់ពន្ធចំនួន
.................................................................................................................................. ។

២-បង្កាន់ដៃបង់ប្រាក់លេខ:............... ចុះថ្ងៃទី...........ខែ............ឆ្នាំ............ របស់............
ដែលឈ្មោះ ..................................... ជាភាគី.................................. បានបង់ប្រាក់ពន្ធចំនួន
.................................................................................................................................. ។

៣-បង្កាន់ដៃបង់ប្រាក់លេខ:................. ចុះថ្ងៃទី.............ខែ.............ឆ្នាំ.................. របស់
សាលាឧទ្ធរណ៍ភ្នំពេញ ដែលឈ្មោះ ..................................... ជាភាគី............................ បាន
បង់ប្រាក់ពន្ធចំនួន.................................................................................................. ។

ថ្ងៃ................................ ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........
រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ.............. ឆ្នាំ.............
**ក្រឡាបញ្ជី**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ

## រូបមន្តអនុវត្ត

យើង..........................................................ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

–បានឃើញបញ្ញត្តិមាត្រា ៣៥៤ និងមាត្រា ៣៥៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦។

–បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.....ចុះថ្ងៃទី.....ខែ......ឆ្នាំ......របស់សាលាដំបូងរាជធានីភ្នំពេញ។

–បានឃើញសាលក្រមរដ្ឋប្បវេណីលេខ....ចុះថ្ងៃទី....ខែ.......ឆ្នាំ......របស់សាលាដំបូងរាជធានីភ្នំពេញ។

–បានឃើញលិខិតបញ្ជាក់សាលក្រមស្ថាពរលេខ....ចុះថ្ងៃទី....ខែ.......ឆ្នាំ......របស់សាលាដំបូងរាជធានីភ្នំពេញ។

–បានឃើញពាក្យសុំចុះថ្ងៃទី....ខែ.......ឆ្នាំ......របស់ឈ្មោះ................ជាភាគីម្ចាស់បំណុលនៃការអនុវត្តដែលមានខ្លឹមសារ ស្នើសុំផ្តល់រូបមន្តអនុវត្តដោយបង្ខំ នៃសាលក្រមរដ្ឋប្បវេណីលេខ....ចុះថ្ងៃទី....ខែ.......ឆ្នាំ......របស់សាលាដំបូងរាជធានីភ្នំពេញ។

### សូមបញ្ជាក់ពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម៖

–ម្ចាស់បំណុលនៃការអនុវត្ត៖ ឈ្មោះ..........ភេទ.....អាយុ.........សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ........ផ្លូវលេខ.............ភូមិ...............សង្កាត់................ខណ្ឌ...................រាជធានីភ្នំពេញ។

–អាចអនុវត្តដោយបង្ខំ នូវសាលក្រមរដ្ឋប្បវេណីលេខ......................ចុះថ្ងៃទី.......ខែ........ឆ្នាំ.......របស់សាលាដំបូងរាជធានីភ្នំពេញ គ្រប់សេចក្តីសម្រេចទាំងមូល។

–ពីកូនបំណុលនៃការអនុវត្ត៖ ឈ្មោះ..........ភេទ.....អាយុ.........សញ្ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ននៅផ្ទះលេខ........ផ្លូវលេខ.............ភូមិ...............សង្កាត់................ខណ្ឌ...................រាជធានីភ្នំពេញ។

សេចក្តីសម្រេចនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមចំណុចស្ថាពរនៃសាលក្រមនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តសាលក្រមនេះឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។

រាជធានីភ្នំពេញ, ថ្ងៃទី....ខែ........ឆ្នាំ.........

**ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធ ១០**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

# រូបមន្តអនុវត្តដីកាសម្រេច

លេខ ដកឧ.២០ យើង.................................. ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** មាត្រា **៣៥៤** មាត្រា **៣៥៥** មាត្រា **៣៥៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**-បានឃើញ** ដីកាសម្រេចលេខ ................ ចុះថ្ងៃទី.......... ខែ............ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** លិខិតបញ្ជាក់ការចូលស្ថាពរលេខ ............ ចុះថ្ងៃទី....... ខែ.......ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** របាយការណ៍បញ្ជូនដីកា ចុះថ្ងៃទី...........ខែ............ឆ្នាំ............(របស់គូភាគី ឬភាគីណាមួយ)។

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី............ ខែ...............ឆ្នាំ................. របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ................................ ដែលមានខ្លឹមសារ ស្នើសុំរូបមន្តអនុវត្តដីកាសម្រេចលេខ.................. ចុះថ្ងៃទី........... ខែ...........ឆ្នាំ............ របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ............................មានអាសយដ្ឋាន.............................. .......................................អាចអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់(ត្រង់ផ្នែកណាមួយ ឬសេចក្តីសម្រេចទាំងមូល) ដីកាសម្រេចលេខ ............................. ចុះថ្ងៃទី......... ខែ.......... ឆ្នាំ............ របស់សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ.............................មានអាសយដ្ឋាន....................... .............................................................................................................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមរូបមន្តអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់។**

ថ្ងៃ................................ ខែ......... ឆ្នាំ.... ....ស័ក ព.ស.២.......

រាជធានីភ្នំពេញ ថ្ងៃទី.......... ខែ............. ឆ្នាំ............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

**ឧបសម្ព័ន្ធ ១១**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

# រូបមន្តអនុវត្តសាលដីកា

យើង................................... ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ មាត្រា ៣៥៤ មាត្រា ៣៥៥ និងមាត្រា ៣៥៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី

**-បានឃើញ** សាលដីការដ្ឋប្បវេណីលេខ ......... ចុះថ្ងៃទី....... ខែ.......ឆ្នាំ......... របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** លិខិតបញ្ជាក់ការចូលស្ថាពរលេខ ..... ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់សាលាឧទ្ធរណ៍ភ្នំពេញ

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី........... ខែ......... ឆ្នាំ.......... របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ................. ដែលមានខ្លឹមសារ ស្នើសុំរូបមន្តអនុវត្តសាលដីការដ្ឋប្បវេណីលេខ..... ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម**

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ.................... មានអាសយដ្ឋាន....................................... អាចអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់(គ្រង់ផ្នែកណាមួយ ឬសេចក្តីសម្រេចទាំងមូល) សាលដីការដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី....... ខែ.....ឆ្នាំ..... របស់សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ..............មានអាសយដ្ឋាន...............................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមរូបមន្តអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់។**

ថ្ងៃ............................... ខែ.......... ឆ្នាំ.... ....ស័ក ព.ស.២........

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.............. ឆ្នាំ.............

**ក្រឡាបញ្ជី**

**ឧបសម្ព័ន្ធ ១២**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាឧទ្ធរណ៍ភ្នំពេញ**

លេខ

# រូបមន្តអនុវត្តពិសេស

យើង.................................... ក្រឡាបញ្ជីនៃសាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** មាត្រា **៣៥៤** មាត្រា **៣៥៥** មាត្រា **៣៥៦** និងមាត្រា **៣៥៧** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**-បានឃើញ** សាលដីការដ្ឋប្បវេណីលេខ ............. ចុះថ្ងៃទី........... ខែ.........ឆ្នាំ............. របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** លិខិតបញ្ជាក់ការចូលស្ពាពរលេខ .......... ចុះថ្ងៃទី.......... ខែ.........ឆ្នាំ.......... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** របាយការណ៍បញ្ជាក់អំពីលក្ខខណ្ឌ ឬពេលវេលាមិនពិតប្រាកដ (បញ្ជាក់អំពីលក្ខខណ្ឌដែលបានបំពេញ ឬពេលវេលាបានមកដល់)។

**-បានឃើញ** ពាក្យសុំ ចុះថ្ងៃទី.......... ខែ..........ឆ្នាំ២០..... របស់ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ.......................(ចំពោះភាគី ឬបុគ្គលក្រៅពីភាគី) ដែលមានខ្លឹមសារស្នើសុំរូបមន្តអនុវត្តសាលដីការដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី........ ខែ......... ឆ្នាំ២០....... របស់សាលាឧទ្ធរណ៍ភ្នំពេញ។

**-បានឃើញ** សេចក្តីអនុញ្ញាតិរបស់តុលាការ ដែលក្រឡាបញ្ជីស្ថិតនៅ។

## សូមបញ្ជាក់អំពីខ្លឹមសារនៃការអនុវត្តដូចខាងក្រោម

ម្ចាស់បំណុលនៃការអនុវត្តឈ្មោះ.......................... មានអាសយដ្ឋាន .................................. .............................. អាចអនុវត្តដោយបង្ខំ តាមខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់(ត្រង់ផ្នែកណាមួយ ឬសេចក្តីសម្រេចទាំងមូល)សាលដីការដ្ឋប្បវេណីលេខ............... ចុះថ្ងៃទី........ខែ........ឆ្នាំ២០....... របស់សាលាឧទ្ធរណ៍ភ្នំពេញ

ចំពោះកូនបំណុលនៃការអនុវត្តឈ្មោះ.........................មានអាសយដ្ឋាន........................ ..........................................................................................................................។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកស្ថាប័ននៃការអនុវត្តដោយបង្ខំ ឱ្យអនុវត្តតាមរូបមន្តអនុវត្តនេះ និងឱ្យអាជ្ញាធរសាធារណៈជួយអនុវត្តឱ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវ តាមច្បាប់។**

ថ្ងៃ.................................. ខែ.......... ឆ្នាំ.... .....ស័ក ព.ស.២.......

រាជធានីភ្នំពេញ ថ្ងៃទី........... ខែ.............. ឆ្នាំ.............

**ក្រឡាបញ្ជី**

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍ភ្នំពេញ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ឧបសម្ព័ន្ធ ១៣**

សាលាដំបូងរាជធានីភ្នំពេញ

# ដីកាសម្រេចរឹបអូសសិទ្ធិលើបំណុល

យើង ចៅក្រមអនុវត្ត នៃសាលាដំបូងរាជធានីភ្នំពេញ

បានឃើញ មាត្រា ៥០២ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រកាសតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

បានឃើញ ពាក្យស្នើសុំអនុវត្តដោយបង្ខំ ចុះថ្ងៃទី ខែ ឆ្នាំ របស់ ក្រុមហ៊ុន តំណាងដោយ ជា ។

បានឃើញ សាលក្រមរដ្ឋប្បវេណី លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមានអានុភាពអនុវត្ត ភ្ជាប់មកជាមួយលិខិតបញ្ជាក់ស្ថាពរ និងរូបមន្តអនុវត្ត។

បានឃើញ សំណុំរឿងអនុវត្តដោយបង្ខំ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ ដែលមាន៖

**-ម្ចាស់បំណុល៖** ក្រុមហ៊ុន តំណាងដោយ ជនជាតិខ្មែរ សញ្ជាតិខ្មែរ ជា កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ចុះថ្ងៃទី ខែ ឆ្នាំ មានអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្ម ស្ថិតនៅផ្ទះលេខ ផ្លូវ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**-មេធាវីតំណាងដោយអាណត្តិ៖** លោក អត្តលេខ ជាមេធាវីនៃក្រុមមេធាវី មានអាសយដ្ឋាននៅ ជាន់ទី បន្ទប់ ផ្លូវលេខ សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**-កូនបំណុល៖** **មហាជនទទួលខុសត្រូវមានកម្រិត** តំណាងដោយលោកស្រី ជាប្រធាននាយកប្រតិបត្តិ មានអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅអាគារលេខ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ។

**-កម្មវត្ថុ៖** សុំអនុវត្តលក់ភាគហ៊ុនដែលជាកម្មសិទ្ធិរបស់កូនបំណុលនៃការអនុវត្ត។

**-សិទ្ធិលើបំណុលដែលទាមទារ៖**

១-ប្រាក់ចំនួន USD ៨ (ប្រាំបីសែន

២-ប្រាក់ចំនួន ៥% ក្នុងមួយឆ្នាំ លើប្រាក់ចំនួន USD ៨ (ប្រាំបី

គិតចាប់ពីថ្ងៃទី ខែ ឆ្នាំ២០ ។

បានឃើញ កំណត់ហេតុសាកសួរ ចុះថ្ងៃទី ខែ ឆ្នាំ២០ ។

## យល់ឃើញថា

១-យោងតាមសាលក្រមរដ្ឋប្បវេណី លេខ ចុះថ្ងៃទី០ ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ មានអានុភាពអនុវត្តលើសេចក្តីសម្រេចបញ្ចប់ទាំងមូលរួចហើយ ដូចមានភ្ជាប់លិខិតបញ្ជាក់ស្ថានភាព និងរូបមន្តអនុវត្ត។

២-តាមពាក្យសុំឱ្យអនុវត្តសាលក្រម ចុះថ្ងៃទី ខែ ឆ្នាំ របស់ក្រុមហ៊ុន តំណាងដោយ ជា ក្រុមហ៊ុន ដោយមានមេធាវីតំណាងដោយអាណត្តិលោក និងកំណត់ហេតុសាកសួរ ចុះថ្ងៃទី ខែ ឆ្នាំ បានស្នើសុំរឹបអូសភាគហ៊ុនទាំងអស់របស់កូនបំណុល មហា**ជនទទួលខុសត្រូវមានកម្រិត** តំណាងដោយលោកស្រី ជាប្រធាននាយកប្រតិបត្តិ ដើម្បីយកប្រាក់មកសងបំណុលប្រាក់ ដូចនេះ គប្បីតុលាការអនុវត្តចាប់ផ្តើមរឹបអូសសិទ្ធិនេះ តាមការស្នើសុំ។

៣-យោងតាមឯកសារចម្លងយថាភូតនៃលិខិតអនុវត្តដែលមានអានុភាព ដើម្បីអនុវត្តសិទ្ធិលើបំណុលខាងលើ គប្បីតុលាការសម្រេចតាមពាក្យសុំដែលម្ចាស់បំណុលនៃការអនុវត្តបានដាក់។

៤-ក្នុងគោលដៅរឹបអូសភាគហ៊ុនសម្រាប់ធានាសងបំណុលដោយមានប្រាក់ចំនួន USD ៨ (ប្រាំបីសែន និងប្រាក់ ៥% ក្នុងមួយឆ្នាំ លើប្រាក់ចំនួន USD ៨ (ប្រាំបីសែន គិតចាប់ពីថ្ងៃទី១១ ខែ ឆ្នាំ និងសោហ៊ុយក្នុងការអនុវត្តជាបន្ទុករបស់កូនបំណុល គប្បីតុលាការសម្រេចរឹបអូសភាគហ៊ុនចំនួន ២០% (ថ្លៃភាគរយ) បន្ថែម លើចំនួនសិទ្ធិលើបំណុលសរុប។

## ហេតុដូច្នេះ សម្រេច

១-ចាប់ផ្តើមនីតិវិធីលក់ដោយបង្ខំ លើសំណុំរឿងអនុវត្តដោយបង្ខំ លេខ ចុះថ្ងៃទី ខែ ឆ្នាំ របស់សាលាដំបូងរាជធានីភ្នំពេញ។

២-រឹបអូសភាគហ៊ុនមានតម្លៃចំនួន USD ១ ) (មួយ ) របស់កូនបំណុលជា **មហាជនទទួលខុសត្រូវមានកម្រិត** មានអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅអាគារលេខ មហាវិថី សង្កាត់ ខណ្ឌ រាជធានីភ្នំពេញ តំណាងដោយលោកស្រី ជាប្រធាននាយកប្រតិបត្តិ។

ថ្ងៃ រោច ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស.២៥

រាជធានីភ្នំពេញ ថ្ងៃទី ខែមិថុនា ឆ្នាំ២

**ចៅក្រមមនុបត្ត**